ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- កម្ពុជាត្រូវតែត្រៀមខ្លួនជាមួយនឹងយុទ្ធសាស្ត្រពហុវិមាត្រ និងដែលមានលក្ខណៈជាច្រើនជំនាន់
- ការពិត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣១៤ ខែកុម្ភៈ ឆ្នាំ២០២៦

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# មាតិកា

## សំបុត្រ

◆ កម្ពុជាត្រូវតែត្រៀមខ្លួនជាមួយនឹងយុទ្ធសាស្ត្រ ពហុវិមាត្រ និងដែលមានលក្ខណៈ............... ១
◆ ក្នុងរូបភាពជាការរក្សាសន្តិសុខជាតិ ............ ៣
◆ ការពិត.................................................. ៤
◆ ច្បាប់អន្តរជាតិ.......................................... ៦
◆ ការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ......... ៧

## ផ្នែកឯកសារ

◆ គោរពជូនអង្គការ ៨៧០ ជាទីគោរព........... ៨
◆ ផែនការរដ្ឋប្រហារនៅរដូវប្រាំង................. ៩

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ......... ៧
◆ ផែនការរដ្ឋប្រហារនៅរដូវប្រាំងឆ្នាំ.............. ៩
◆ សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគោលនយោបាយ ជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើម ...........១៤
◆ អ៊ី ស៊ីដា ៖ តស៊ូរស់ដើម្បីកូននិងប្រទេស ....... ១៧
◆ អតីតប្រធានជំរំណងចាន់ និងជាមេបញ្ជការ ....១៩
◆ ប្តីខ្ញុំបាត់បង់ជីវិតដោយសារគ្រាប់ផ្លោង.......២២
◆ ប៊ូ រីណា ៖ កងដឹកជញ្ជូន........................ ២៥
◆ អ៊ី វឿត៖ អតីតទាហានប៉ារ៉ា និងជា........... ២៨
◆ អ៊ិន ផុន ៖ អតីតឈរជើងនៅអូរស្វាយ ........៣០
◆ ស៊ុម សុផល ៖ អតីតកងទ័ពនៃកងពល....... ៣៣
◆ ប្អូនស្រីបីនាក់ត្រូវបានរថក្រោះបើកកិនស្លាប់... ៣៧
◆ លី ម៉ិច ៖ ស្តុតស្មារតី ពេលឃើញឈ្លប....... ៤២

## ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ ប្រដេញតាមមហិច្ឆតាជាតិនិយមថៃ........... ៤៤
◆ គោលនយោបាយការបរទេសអាមេរិក៖ ..... ៤៤
◆ សិស្សវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ....... ៤៦
◆ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកា ថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជា........... ៤៩



ទាហានថៃរាយលួសបន្លាព័ទ្ធយកដី និងលំនៅឋានប្រជាជនកម្ពុជា នៅប្រកព្រំដែនថ្មដា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ វេទិកាថ្នាក់រៀនស្តីពី «ផលប៉ះពាល់ និងតម្រូវការ ចាំបាច់សម្រាប់ប្រជាជនភៀសសឹក» ......... ៥៣
◆ វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ» នៅមជ្ឈមណ្ឌល ............ ៥៧

## ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ សេចក្តីប្រកាសរកយាយតា និង មីង ដែលបាត់ខ្លួន........................................ ៦១

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ផេង ពង្សរ៉ាស៊ី, ឈុំ រ៉ា, សូ ហ្វារីណា, ទាវ សម្ភស្ស, គាត ស្រីឡែន, ចាន់ ណារិទ្ធ, ឡុង ដានី, ធី គឹមហុង, មឿន ស្រីណុច, ភា រស្មី, ជឹម សុខគា និង លី សុខឃាង
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ិគីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# កម្ពុជាត្រូវតែត្រៀមខ្លួនជាមួយនឹងយុទ្ធសាស្ត្រពហុវិមាត្រ និងដែលមានលក្ខណៈជាច្រើនជំនាន់

ឆាំង យុ




*រដ្ឋមន្ត្រីការបរទេសថៃ សីហសក្តិ ភួងកេតកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ការបោះឆ្នោតនៅប្រទេសថៃគឺជាការប្រទាញប្រទង់ផ្ទៃក្នុងរបស់ថៃ៖ ការបោះឆ្នោតនៅក្នុងប្រទេសថៃគឺជាកត្តាសំខាន់មួយដែលជះឥទ្ធិពលទៅលើជម្លោះព្រំដែនខ្មែរ-ថៃ ប៉ុន្តែវាអាចជារឿងឆោតល្ងង់ក្នុងការដែលលើកឡើងថាការបោះឆ្នោតនេះគឺជាកត្តាជំរុញ ឬជាកម្លាំងចលករតែមួយគត់នៃបញ្ហាជម្លោះព្រំដែននេះ។

ផ្ទុយទៅវិញ ជម្លោះព្រំដែនខ្មែរ-ថៃមិនមែនជាកត្តាកំណត់តែម្យ៉ាងគត់ ចំពោះលទ្ធផលនៃការបោះឆ្នោតរបស់ថៃនោះដែរ។ សរុបមកជម្លោះព្រំដែនខ្មែរ-ថៃគឺជាកត្តាជំរុញនិងជាផលវិបាកនៃការប្រទាញប្រទង់ផ្ទៃក្នុងរវាងបក្សសម្ព័ន្ធនយោបាយថៃ និងទស្សនវិស័យនានាចំពោះអនាគតនៃប្រទេសថៃ ហើយប្រទេសកម្ពុជាចាំបាច់ត្រូវដាក់ចេញនូវយុទ្ធសាស្ត្រឱ្យសព្វជ្រុងជ្រោយ—ដោយប្រើប្រាស់ភាពចាស់ទុំក្នុងការដឹកនាំ និងការរក្សាបានជំហរនឹងនរលើគ្រប់វិស័យនៃអភិបាលកិច្ច ចាប់តាំងពីវិស័យនយោបាយ និងការទូត រហូតដល់វិស័យសេដ្ឋកិច្ច យោធា និងសង្គម-វប្បធម៌។

ភាគីថៃចង់បង្ហាញថាជម្លោះព្រំដែនខ្មែរ-ថៃនេះ គឺគ្រាន់តែជាវិវាទតូចតាចដែលបង្កឡើងដោយភាគីកម្ពុជា ដោយលើកយកឧទាហរណ៍ដូចជាបញ្ហាមីនការប៉ះទង្គិចគ្នា និងព្រឹត្តិការណ៍ផ្សេងៗទៀត ដែលភាគីថៃយល់ថាជាការគំរាមកំហែងដល់សន្តិសុខជាតិរបស់ខ្លួន។ យើងគួរតែគូសបញ្ជាក់ឱ្យច្បាស់ថា បច្ចុប្បន្នយោធាថៃកំពុងកាន់កាប់ទីតាំងចំនួន ១៤ ដែលស្ថិតក្នុងដែនអធិបតេយ្យរបស់កម្ពុជា ហើយទង្វើនេះគឺជាការរំលោភបំពានលើស្មារតីនៃកិច្ចព្រមព្រៀងឈប់បាញ់។ ផ្អែកលើទស្សនយល់ឃើញស៊ីជម្រៅចំពោះជម្លោះព្រំដែនខ្មែរ-ថៃ គឺថាជម្លោះនេះកើតឡើងដោយសារតែការប្រទាញប្រទង់ផ្ទៃក្នុងរបស់ថៃដែលបានទាញយកផលប្រយោជន៍ពីភាពតានតឹងប្រវត្តិសាស្ត្រដ៏រ៉ាំរ៉ៃជាមួយកម្ពុជា ដើម្បីបង្កើតឱ្យមានឯកភាពជាតិគាំពារដោយរបៀបវារៈនយោបាយបុមនោគមវិជ្ជាមួយ។

ដូច្នេះ ការបោះឆ្នោតនៅប្រទេសថៃគឺជាចំណុចរបត់ដ៏សំខាន់មួយនៅក្នុងបញ្ហាប្រទាញប្រទង់នេះ ប៉ុន្តែជាអកុសល ការបោះឆ្នោតនេះនឹងមិនមែនជាទីបញ្ចប់នៃបញ្ហាជម្លោះព្រំដែនខ្មែរ-ថៃនោះទេ វាគ្រាន់តែជាឱកាសថ្មីមួយដើម្បីចាប់ផ្តើមទំនាក់ទំនងឡើងវិញតែប៉ុណ្ណោះ។

សូមកុំយល់ច្រឡំះវិវាទអន្តរជាតិនិងប្រវត្តិសាស្ត្រដែលអូសបន្លាយជាច្រើនជំនាន់ជុំវិញបញ្ហាព្រំដែនគឺមិនអាចដោះស្រាយបានតាមរយៈព្រឹត្តិការណ៍តែមួយ ដូចជាការបោះឆ្នោត ឬកិច្ចព្រមព្រៀងសន្តិភាពនោះទេ។ កម្ពុជាត្រូវតែត្រៀមខ្លួនជាមួយនឹងយុទ្ធសាស្ត្រពហុវិមាត្រ និងដែលមានលក្ខណៈជាច្រើនជំនាន់។



ក្រុមសង្កេតការណ៍អាស៊ានចុះពិនិត្យស្ថានភាពបាក់បែកនៅប្រាសាទព្រះវិហារដោយសារការបាញ់ផ្លោង និងទម្លាក់គ្រាប់បែកពីយោធាថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្នុងរូបភាពជាការរក្សាសន្តិសុខជាតិ

**ឆាំង យុ**



*ទាហានថៃវាយលួសបន្លាព័ទ្ធយកដី និងលំនៅឋានប្រជាជនកម្ពុជានៅច្រកព្រំដែនថ្មដា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ភាគីថៃកំពុងប៉ុនប៉ងដណ្ដើមយកទឹកដីកម្ពុជាខណៈពេលដែលគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកកំពុងមានការប្រែប្រួល។ នេះជារឿងដដែលៗកើតមានឡើងជាច្រើនលើកជាច្រើនសារមកហើយ។ នៅពេលដែលមានការរង្គោះរង្គើនៃអំណាច ភាគីថៃតែងតែគិតថាវាគឺជាឱកាស។ ប្រសិនបើកម្ពុជាដណ្ដើមយកទឹកដីថៃវិញ ក្នុងរូបភាពជាការរក្សាសន្តិសុខជាតិដូចគ្នាដែរនោះ តើភាគីថៃនឹងគិតយ៉ាងដូចម្ដេច? ប្រសិនជាព្រឹត្តិការណ៍នេះកើតឡើងមែននោះ សង្គ្រាមដ៏ក្ដៅគគុកប្រាកដជាកើតមានជាក់ជាមិនខាន។



*កងទ័ពអាកាសថៃទម្លាក់គ្រាប់បែកពីយន្តហោះ F-16 ផ្ដាច់ស្ពានមេទឹក ឬស្ពានជ័យជម្នះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ការពិត

ឆាំង យុ



*ព្រះសម្មាសម្ពុទ្ធកំពុងសមាធិនៅក្រោមដើមពោធិ៍ ដោយមានទេវតាពីរអង្គសំពះប្រណម្យ គោរពបូជាព្រះអង្គដោយសេចក្តីជ្រះថ្លា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

ការពិតគឺជាវត្ថុដែលមិនអាចកាត់ថ្លៃបាននៅក្នុងយុគសម័យព័ត៌មាន ហើយនៅក្នុងទម្រង់ជាច្រើន ការពិតមានតម្លៃជាងមាសទៅទៀត ពីព្រោះថាការពិតគឺពិបាកស្វែងរក រក្សា និងការពារជាងលោហៈធាតុមានតម្លៃណាៗទាំងអស់។

ជម្លោះបច្ចុប្បន្នរវាងកម្ពុជា និងថៃគឺជាជម្លោះដែលកើតឡើងដោយសារការប្រកាន់យកនូវមូលដ្ឋានប្រវត្តិសាស្ត្រ និងតថភាពជាក់ស្តែងខុសពីគ្នា រវាងកងទ័ពទាំងពីរភាគីដែលកំពុងប្រឈមមុខតតាំងជាមួយគ្នា។ មិនមានអ្វីជាកំហុសទេ ទៅលើមតិខុសគ្នាជុំវិញរឿងរ៉ាវប្រវត្តិសាស្ត្រ ប៉ុន្តែបញ្ហានឹងកើតមានឡើង ប្រសិនបើប្រវត្តិសាស្ត្រលេចក្នុងទម្រង់ជាច្រើនសណ្ឋានខុសៗគ្នា។ ទោះបីជាកម្ពុជាមានប្រៀបជាងថៃក្នុងជម្លោះបច្ចុប្បន្នទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ និងតថភាពជាក់ស្តែងយ៉ាងណាក្តី កម្ពុជានៅតែមានវិធីសាស្ត្រជាច្រើនដើម្បីពង្រឹងការគ្រប់គ្រងលើតថភាពទាំងអស់នោះ។

ឧទាហរណ៍គឺកម្ពុជាអាចបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រផ្ទាល់របស់កម្ពុជា ក៏ដូចជាប្រវត្តិសាស្ត្ររបស់ប្រទេសថៃ។ ទីពីរកម្ពុជាអាចផ្តួចផ្តើមគំនិតយ៉ាងសកម្មក្នុងការប្រមែប្រមូលភស្តុតាងស្តីពីព្រឹត្តិការណ៍បច្ចុប្បន្ន និងប្រើប្រាស់ភស្តុតាងទាំងនោះ ដើម្បីជួយ

ដល់សហគមន៍អន្តរជាតិក្នុងការយល់ដឹងអំពីអ្វីដែលកំពុងតែកើតមានឡើងៗ ជាចុងក្រោយ ប្រជាជនកម្ពុជាអាចប្រើប្រាស់ប្រវត្តិសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងការប្រាស្រ័យទាក់ទងទៅកាន់ពិភពលោក។

ការប្រមែប្រមូល ការអភិរក្ស និងការការពារប្រវត្តិសាស្ត្រដែលពិតប្រាកដ និងតថភាពពិតដែលកំពុងកើតមានឡើងសព្វថ្ងៃគឺមិនមែនជាការងារបន្ទាប់បន្សំឡើយ វាគឺជាសមរភូមិយុទ្ធសាស្ត្រនៅក្នុងជម្លោះដែលបានបន្តកើតមានអស់ជាច្រើនជំនាន់មកហើយ។ ជារួម ការបរាជ័យក្នុងការគ្រប់គ្រងលើការពិតនៃប្រវត្តិសាស្ត្រនេះ នឹងញ៉ាំងឱ្យរឿងរ៉ាវដដែលៗនៅតែបន្តកើតមានឡើងទៅលើមនុស្សជំនាន់ក្រោយៗទៀតជាក់ជាមិនខាន។



ទេសភាពវាលស្រែនៅក្នុងរដូវប្រមូលផលនៅប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ច្បាប់អន្តរជាតិ

**ឆាំង យុ**







ទាហានថៃបាញ់ផ្លោង និងទម្លាក់គ្រាប់បែកមកលើផ្ទះសម្បែង ភូមិឋាន និងទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជានៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មិនមានអ្វីខុសឆ្គងឡើយដែលភាគីថៃចូលរួមក្នុងកិច្ចពិភាក្សាដេញដោលអំពីច្បាប់អន្តរជាតិ ពីព្រោះច្បាប់អន្តរជាតិបែកចេញជាច្រើនផ្នែក ហើយក្នុងចំណោមផ្នែកនានានៃច្បាប់អន្តរជាតិទាំងនោះ ថៃគឺជាភាគីពាក់ព័ន្ធ ជាអ្នកជំនាញ និងថែមទាំងជាអ្នកដឹកនាំដ៏សំខាន់ៗ ប៉ុន្តែការចូលរួមរបស់ប្រទេសថៃក្នុងកិច្ចសន្ទនាអំពីច្បាប់អន្តរជាតិបានជំរុញឱ្យមានការរិះគន់ នៅពេលដែលប្រទេសថៃផ្ទាល់បញ្ចេញទស្សនយល់ឃើញចំពោះបញ្ហានានាដោយសម្តែងថាខ្លួនត្រូវជានិច្ច ឬបង្ហាញយ៉ាងច្បាស់អំពីភាពមិនស្មោះត្រង់របស់ខ្លួន។ ប្រទេសមួយអាចទីងកំពុងរំលោភច្បាប់អន្តរជាតិលើផ្នែកណាមួយ ប៉ុន្តែស្របពេលទីងគ្នានោះមិនបានរំលោភលើផ្នែកដទៃទៀតនៃច្បាប់អន្តរជាតិទេ។ ច្បាប់អន្តរជាតិគឺមិនមានភាពស៊ីសង្វាក់គ្នាទេ ពីព្រោះក្នុងទម្រង់ផ្សេងៗគ្នា ច្បាប់អន្តរជាតិមិនត្រឹមតែឆ្លុះបញ្ចាំងអំពីស្ថានភាពពិភពលោកសព្វថ្ងៃប៉ុណ្ណោះទេ ក៏ប៉ុន្តែប្រមើមើលអំពីស្ថានភាពអនាគតរបស់ពិភពលោកថែមទៀតផង។

# ការដាក់ពាក្យបណ្តឹងទៅកាន់តុលាការក្នុងស្រុក

## ស្របពេលដែលការចរចាការទូតកំពុងប្រព្រឹត្តទៅ គឺជាទង្វើមិនថ្លៃថ្នូរ ហើយអាចត្រឹមតែបង្កការបន្តុចបន្ទាក់ដល់កិច្ចការទូតតែប៉ុណ្ណោះ

**ឆាំង យុ**





ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគកម្ពុជា-ថៃ រវាងយោធភូមិភាគទី៤ ភាគីកម្ពុជា ដឹកនាំដោយឧត្តមសេនីយ៍ត្រី និត ណារ៉ុង នាយសេនាធិការរង យោធភូមិភាគទី៤ និងកងទ័ពភូមិភាគទី២ ភាគីថៃ ដឹកនាំដោយឧត្តមសេនីយ៍ត្រី កាំផាក់ណាក វ៉ាផាន់ស៊ុ នាយសេនាធិការ កងទ័ពភូមិភាគទី២ បានជួបប្រជុំគ្នានៅច្រកអន្តរជាតិជាំ-សាង៉ាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្រោមការអង្កេតពីក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) របស់កម្ពុជា និងថៃ នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦។
(រូបថត ៖ ក្រសួងការពារជាតិកម្ពុជា)

ការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីដោយមន្ត្រីជាន់ខ្ពស់ថៃ ប្រឆាំងនឹងមន្ត្រីកម្ពុជានៅក្នុងតុលាការក្នុងស្រុករបស់ថៃ ស្របពេលដែលប្រទេសថៃ និងប្រទេសកម្ពុជាកំពុងបន្តចរចាលើជម្លោះព្រំដែន គឺមិនត្រឹមតែមិនស្របតាមស្មារតីនៃការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះនេះប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាទង្វើដ៏គួរឱ្យអាម៉ាស់មួយ ដោយបង្ហាញថារដ្ឋាភិបាលថៃហាក់ដូចជាមិនមានគោលនយោបាយការបរទេសរួបរួមតែមួយ។ ទំនាក់ទំនងការទូតប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋ និងរដ្ឋ គឺអាស្រ័យលើការឯកភាពរួមគ្នារវាងបញ្ជការយោធា និងគោលនយោបាយការបរទេស។ ប្រសិនបើមានការចេញបញ្ជា និង/ឬគោលនយោបាយដែលមិនឯកភាពគ្នា ដោយផ្នែកម្ខាងនៃរដ្ឋាភិបាលថៃកំពុងស្វះស្វែងរកដំណោះស្រាយតាមវិធានការទូត ហើយផ្នែកម្ខាងទៀតនៃរដ្ឋាភិបាលថៃបែរជាដោះស្រាយដោយប្រើប្រាស់តុលាការក្នុងស្រុកឬអន្តរជាតិ នោះវានឹងចោទជាសំណួរថាតើនរណាជាអ្នកគ្រប់គ្រងរដ្ឋាភិបាលថៃឱ្យពិតប្រាកដ ព្រោះរដ្ឋាភិបាលកម្ពុជាប្រហែលជាត្រូវទាក់ទងផ្ទាល់ទៅកាន់បុគ្គលរូបនោះតែម្តង?

ទូរលេខ៖ ៣៨

២៤៨៖ ខ្ទង់

# គោរពជូនអង្គការ ៨៧០ ជាទីគោរព

ដកស្រង់ចេញពីឯកសារ D០១៩៦៧

**សោម ប៊ុនថន**

១- សភាពការណ៍ខ្មាំងព្រំដែនយប់ថ្ងៃ១០ នឹងថ្ងៃ១១.៨.៧៧ នៅមុខអូរជ្រៅ ថាមានបាញ់កាំភ្លើងដៃមកចូលដីយើងពីលើក ម្តងពី១០គ្រាប់ ទៅ២០គ្រាប់ យន្តហោះ ហោះឆ្វែលជុំវិញអូរជ្រៅ ដល់ថ្ងៃប្រហែលម៉ោង១១ថ្ងៃត្រង់ មកឆ្វែលនិមិត្តពីរជុំទៀត ហោះខ្ពស់មើលឃើញតូចៗ

២- ក្រោយពីនេះ ស្នើមេព្យាធ្វើសេរ៉ូម ឬសេរ៉ូមស្រេចតែម្តងក៏បាន ប៉ុន្តែថ្នាំធ្វើសេរ៉ូមទឹកស្រេចថាមានប្រតិកម្ម គឺមានញាក់ តាអើក តែមិនបញ្ហាគ្រោះថ្នាក់ដែរ នេះចាំពិនិត្យទៀតក្រែងខ្មាំងបំផ្លាញ ឬក៏ថ្នាំបណ្តាលឱ្យខូចៗ

៣- ថ្ងៃ១២.៨នេះ ចុះរៀបចំមុខសញ្ញា អូរ ថ្ងៃ១៣ មុខសញ្ញាថ្មពួក ថ្ងៃ១៤.៨ មុខសញ្ញាខាងភ្នំត្បូងដែរៗ

៤- រឿងទំនប់ស្ទឹងសង្កែដែលកូរ៉េបម្រុងជួយយើងនោះ ស.ម រ៉ាន់បានប្រឹក្សាជាមួយខ្ញុំដែរ ឱ្យគេធ្វើឬយ៉ាងណា? ខ្ញុំសម្រេចថា គេមិនធ្វើក៏បាន តែការនេះស្នើអង្គការពិនិត្យថែមទៀត ក្រែងប៉ះពាល់ដល់ នយោបាយៗ តាមអង្គការសម្រេចចុះៗ

ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្តៅបំផុត

ញឹម

ថ្ងៃ១២.៨.៧៧

ទទួល ថ្ងៃ១៣.៨.៧៧ ម៉ោង៖ ០៨-១៥នាទី



កងទ័ពការពារដែនទឹករបស់ខ្មែរក្រហមៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កងទ័ពខ្មែរក្រហមនៅលើសមរភូមិៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផែនការរដ្ឋប្រហារនៅរដូវប្រាំងឆ្នាំ ១៩៧៨-១៩៧៩ ជំរុញឱ្យ អ៊ា នឹម ហៅ គុន

## អនុប្រធានរោងចក្រតម្បាញ ត-៥ ក្បត់បក្សដោយមិនដឹងខ្លួន

**ផេង ពង្សរ៉ាស៊ី**



*មិត្តនារីកម្មករនៅរោងចក្រផលិតជ័រកៅស៊ូក្រែបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

***«...បញ្ហាក្បត់បក្ស កើតជាទំនាស់មិនអស់មិនហើយនៅក្នុងខ្លួនខ្ញុំៗ ស្មុគស្មាញជាប់! នៅតែមិនដាច់ខាតរាយការណ៍ជូនបក្ស! ចេះតែខំបៀមសម្ងំទុកក្នុងខ្លួនបណ្តោយឱ្យខ្មាំងកៀបសង្កត់ប្រើតទៅទៀតៗ»*** *នេះជាកំណត់ហេតុរបស់ អ៊ា នឹម ហៅ គុន អនុប្រធានរោងចក្រតម្បាញត-៥ សរសេរក្នុងឯកសារមានចំណងជើង «អំពីផែនការរដ្ឋប្រហារនៅរដូវប្រាំងឆ្នាំ ១៩៧៨-១៩៧៩» ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៨។*

*គុន ត្រូវអង្គការឃាត់ខ្លួនបញ្ជូនទៅកាន់មន្ទីរ ស-២១ ដោយមូលហេតុជាប់ពាក់ព័ន្ធក្នុងផែនការក្បត់បក្សជាមួយកម្មាភិបាលក្បត់ដទៃទៀត ដែលជាកម្មាភិបាលគ្រប់គ្រងរោងចក្រតម្បាញរដ្ឋរបស់ខ្មែរក្រហមៗ ប្តីរបស់គុនឈ្មោះ អ៊ិន លន ហៅ សមមិត្តណាត ជាអតីតប្រធានមន្ទីរ ស-២១ និងជាកម្មាភិបាលបម្រើការផ្នែកនយោបាយនៃក្រសួងការបរទេសខ្មែរក្រហម ក៏ត្រូវអង្គការចាប់ខ្លួនដែរ ក្រោម*

មូលហេតុបីផ្សេងគ្នា៖ ១)ធ្វេសប្រហែសក្នុងការអនុវត្តកិច្ចការងាររដ្ឋវិរដ្ឋជាមួយបណ្ដាប្រទេសជាមិត្ត ដែលនាំឱ្យរបបកម្ពុជាប្រជាធិបតេយ្យបាត់បង់ទំនុកចិត្តពីបណ្ដាប្រទេសទាំងនោះ, ២) មិនគោរពបទបញ្ជារបស់ថ្នាក់លើក្នុងការបោសសម្អាតខ្មាំងនៅក្នុងកងពល២៩០ និង ៣) ខកខានមិនបានប្រគល់បញ្ជីឈ្មោះដែលត្រូវកម្ទេចទៅឱ្យ សមមិត្តវ៉ែនតាមបញ្ជារបស់ សុន សេន។ គាត់ត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨ ហើយត្រូវអង្គការសម្លាប់ចោល។

នៅក្នុងឯកសារសរសេរដោយដៃចំនួន៩ ទំព័រ មានចំណងជើង «អំពីផែនការរដ្ឋប្រហារនៅរដូវប្រាំង ឆ្នាំ១៩៧៨-១៩៧៩» គុន បានបង្ហាញពីអារម្មណ៍សោកស្ដាយចំពោះសកម្មភាពរបស់គាត់ ដែលបានចូលរួមពាក់ព័ន្ធក្នុងផែនការក្បត់បក្សដោយមិនដឹងខ្លួន បន្ទាប់ពីបានចូលរួមប្រជុំជាមួយ អន នៅចុងខែឧសភា ឆ្នាំ១៩៧៨ រួចមក។ អន មានឈ្មោះពេញ ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរបស់ខ្មែរក្រហម។

គុន បានរំឭកថា គាត់បានទទួលលិខិតអញ្ជើញមួយច្បាប់ពីនីរសារមន្ទីរឧស្សាហកម្ម នៅវេលាម៉ោង៦កន្លះព្រឹកព្រលឹម ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៨ ប្រាប់ឱ្យទៅចូលរួមប្រជុំនៅក្នុងផ្ទះមួយ ស្ថិតនៅទល់មុខមន្ទីរឧស្សាហកម្ម។ អង្គប្រជុំ បានចាប់ផ្ដើមនៅវេលាម៉ោង៧ ព្រឹកថ្ងៃដដែល។ អន ដែលជាប្រធានអង្គប្រជុំបានសំណេះសំណាល និងសួរសុខទុក្ខដល់សមាជិកអង្គប្រជុំដែលជាប្រធាន និងអនុប្រធានរោងចក្រតម្បាញទាំងអស់ ព្រមទាំងបានចំណាយពេលវេលាបន្តិចបន្តួច ពិភាក្សាអំពីសកម្មភាពការងារនៅក្នុងរោងចក្រនីមួយៗ។ បន្ទាប់មក អន បានចំណាយពេលវេលាយ៉ាងច្រើន ដើម្បីពិភាក្សា បញ្ចុះបញ្ចូល និងណែនាំពីផែនការធ្វើរដ្ឋប្រហារនៅរដូវប្រាំងក្នុងឆ្នាំ១៩៧៨-១៩៧៩ ជាមួយសមាជិកអង្គប្រជុំទាំងអស់។ គុនបានរៀបរាប់ថា ការលើកយកផែនការធ្វើរដ្ឋប្រហារនៅរដូវប្រាំងមកពិភាក្សាក្នុងអង្គប្រជុំបានធ្វើឱ្យសមាជិកអង្គប្រជុំភាគច្រើនភ្ញាក់ផ្អើល និងមិននឹកស្មានដល់។ សមាជិកអង្គប្រជុំខ្លះបានបង្ហាញសេចក្ដីព្រួយបារម្ភខ្លាចបែកការណ៍សម្ងាត់ពីផែនការនេះពុងដល់អង្គការ។ អ្នកខ្លះទៀតព្រួយបារម្ភពីការរៀបចំកម្លាំង សម្ភារ អាវុធយុទ្ធភ័ណ្ឌ និងយុទ្ធសាស្ត្រដើម្បីឱ្យផែនការរដ្ឋប្រហារនេះ ទទួលបានជោគជ័យ។ ចំណែក គុន វិញ ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន គ្រួសារ និងលទ្ធផលចុងក្រោយនៃការចូលរួមក្នុងផែនការក្បត់។

អង្គប្រជុំបានបញ្ចប់ទៅនៅព្រឹកថ្ងៃដដែល។ គុន មានអារម្មណ៍វិលវល់ ស្មុគស្មាញ និងភិតភ័យជាខ្លាំង ព្រោះដឹងច្បាស់ថា គាត់មិនអាចបដិសេធន៍ឬដកខ្លួនចេញពីផែនការនេះបាន។ គុន និយាយថា **«ទោះបីជាខ្ញុំនៅមានជំហរកម្មសិទ្ធិឯកជនក្រាស់យ៉ាងណាក្ដី ក៏ខ្ញុំនៅតែភ័យត្រដាក់ដៃជើងដែរ ព្រោះបញ្ហានេះមិនមែនរឿងតូចតាចទេ។ គឺជារឿងក្បត់ជាតិ ក្បត់បក្ស តែបើបានលង់ខ្លួនទៅហើយ មិនហ៊ានហើបមាត់ទេ។ ម៉្យាងខ្លាចបក្សដឹង! ម៉្យាងខ្លាចកម្លាំងក្បត់! ព្រោះខ្លួននៅក្រោមការដឹកនាំផ្ទាល់របស់ពួកនេះ»**។ ការព្រួយបារម្ភនេះ បានធ្វើឱ្យ គុន នឹកគិតដល់ទំនាក់ទំនងល្អជាមួយមេដឹកនាំជាន់ខ្ពស់បក្ស ដែលធ្លាប់បានផ្ដល់នូវការជឿទុកចិត្ត ការសណ្ដោសប្រណី ផ្ដល់ក្ដីស្រឡាញ់ ការអប់រំណែនាំ និងការបង្ហាត់បង្រៀននាពេលកន្លងមក។ **«...ចាប់តាំងពីថ្ងៃរំដោះមក ខ្ញុំធ្លាប់ទទួលបានការអប់រំពីអ៊ំទី១និងអ៊ំទី២ ដោយផ្ទាល់ក្នុងសាលាបក្ស និងតាមរយៈអង្គមីទីងឬការប្រជុំរៀនសូត្ររយៈពេលមួយព្រឹកក្ដី មួយថ្ងៃក្ដី។ ខ្ញុំឃើញច្បាស់នូវមនោសញ្ចេតនារបស់អ៊ំចំពោះជាតិ ចំពោះប្រជាជន។ [ខ្ញុំ]ឃើញនូវអាកប្បកិរិយារបស់អ៊ំ ចាស់ទុំ នឹងនរស្លូតបូត គួរឱ្យពេញចិត្តក្រៃលែង»**។

ពេលវេលាជាបន្តបន្ទាប់មកទៀត គុន បានចូលរួមប្រជុំពីផែនការក្បត់បក្សជាហូរហែ មុនពេលដែលគាត់ត្រូវអង្គការផ្លាស់ប្ដូរការងារឱ្យទៅធ្វើការនៅក្រសួងការបរទេស។ គុនបាននិយាយថា កិច្ចប្រជុំគ្រប់ពេល គឺផ្ដោតលើការជ្រើសរើសកម្លាំងបន្ថែម ការត្រៀមស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ក្នុងពេលធ្វើរដ្ឋប្រហារ និងការអប់រំសតិអារម្មណ៍ឱ្យស្អប់ខ្ពើមបក្ស ហើយងាកមកជឿទុកចិត្តលើរបបថ្មីមួយដែលដណ្ដើមបានក្រោយពីរដ្ឋប្រហារនាពេលខាងមុខ។ គុន បានសរសេរនៅក្នុងសំណេរដដែលនេះថា គ្រប់ពេលដែលមានការអញ្ជើញឱ្យចូលរួមប្រជុំ គាត់មិនចង់ចូលរួម

ឡើយ ប៉ុន្តែគាត់ក៏មិនអាចគេចវេះបានដែរ។ ទីបំផុត គុន បានស្តាប់ និងអនុវត្តតាមការណែនាំរបស់ អន ទាំងអស់ ទាំងការជ្រើសរើសកម្លាំងក្បត់បន្ថែម ការរៀបចំស្បៀងបម្រុងទុក និងការអនុវត្តផែនការក្បត់នានាជាមួយកម្មាភិបាល និងកម្មករនៅក្នុងរោងចក្រតម្បាញដែលគាត់គ្រប់គ្រង។

នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៧៨ គុន ត្រូវអង្គការផ្លាស់ឱ្យទៅធ្វើការនៅក្រសួងការបរទេសវិញ។ គាត់ត្រេកអរចំពោះការផ្លាស់ប្តូរនេះ និងគិតថាគាត់លែងបានចូលរួមប្រជុំរឿងផែនការក្បត់ទៀតហើយ។ នៅក្នុងក្រសួងការបរទេស គុន ខិតខំបម្រើការងារយ៉ាងពេញដៃពេញជើង និងលះបង់ចោលការចូលរួមឬការអនុវត្តសកម្មភាពនានា ទាក់ទងនឹងផែនការរដ្ឋប្រហារដែលគាត់ធ្លាប់ធ្វើពីមុនមក។ **«ពេលខ្ញុំទៅនៅមន្ទីរប-១ (ក្រសួងការបរទេស) ខ្ញុំរីករាយនិងធូរស្រាលក្នុងចិត្តក្រៃលែង។ ឃើញអ្វីៗដែលនៅជុំវិញខ្លួន ចេះតែល្អទាំងអស់»**។ ប៉ុន្តែក្នុងរយៈពេលដ៏ខ្លីក្រោយមក គុន ឧស្សាហ៍ជួបជជែកគ្នាជាមួយកម្មាភិបាលដឹកនាំនៅរោងចក្រតម្បាញម្នាក់ឈ្មោះ មិត្ត វ៉ុន។ តាំងពីពេលនោះមក គុន គិតថាគាត់នៅតែជាប់ពាក់ព័ន្ធនឹងផែនការក្បត់នេះដដែល។ ឧទាហរណ៍ នៅចុងខែកក្កដា ដើមខែកញ្ញា និងនៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ១៩៧៨ សមមិត្តនារី វ៉ុន ជាប្រធានរោងចក្រតម្បាញ ត១ បានស្កាត់មកជួប គុន ក្នុងពេលដែល គុន ចេញពីធ្វើការនៅក្រសួងការបរទេស។ រាល់ជំនួបទាំងបីលើក វ៉ុន តែងតែលើកយកផែនការរដ្ឋប្រហារមកនិយាយប្រាប់ គុន ហើយបានក្រើនរំឭក គុន កុំឱ្យធ្វេសប្រហែសពីការងារប្រមូលកម្លាំង និងព្យាយាមតភ្ជាប់ខ្សែរយៈឡើងវិញ។ គ្រប់ពេលដែល វ៉ុន ចាកចេញទៅ គុន ព្រួយបារម្ភកាន់តែខ្លាំងពីសុវត្ថិភាពផ្ទាល់ខ្លួន គ្រួសារ និងកូនតូចក្នុងបន្ទុក ព្រោះគាត់បានដឹងព័ត៌មានជាហូរហែពីការចាប់ខ្លួន និងបោសសម្អាតខ្លាំងនៅក្រុងភ្នំពេញ ភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរចាស់ និងភូមិភាគឧត្តរថ្មី។

តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨មក ព្រឹត្តិការណ៍បោសសម្អាតជនក្បត់បក្សនៅភូមិភាគបូព៌ា នៅភ្នំពេញ និងនៅភូមិភាគផ្សេងទៀតបានកើតឡើងជារៀងរាល់ថ្ងៃ។ កម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់ត្រូវបានចាប់ខ្លួននិងបញ្ជូនមកកាន់មន្ទីរ ស-២១ ដើម្បីសួរចម្លើយ និងសម្លាប់យ៉ាងរង្គាល។ ចម្លើយសារភាពរបស់កម្មាភិបាលក្បត់ទាំងនោះ បានធ្វើឱ្យមនុស្សជាច្រើននាក់ជាប់ពាក់ព័ន្ធនឹងខ្លួន ហើយអ្នកទាំងនោះត្រូវបានស្វែងរកចាប់ខ្លួន និងបញ្ជូនជាបន្តបន្ទាប់មកកាន់មន្ទីរ ស-២១។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ គុន បានដឹងដំណឹងតាម ហៀង ជាកម្មាភិបាលនៅមន្ទីរប-១ ថា អន (ចេង អន) និង វន (វន វ៉េត) ត្រូវអង្គការចាប់ខ្លួនបាត់ទៅហើយ។ ដំណឹងនេះ បានធ្វើឱ្យ គុន កាន់តែព្រួយបារម្ភថែមទៀត ព្រោះថា អន ជាថ្នាក់លើរបស់ខ្លួនពីមុនមក ហើយ អន បានស្គាល់កម្មាភិបាលនៅក្នុងរោងចក្រតម្បាញទាំងអស់។ ចេង អន ត្រូវអង្គការចាប់ខ្លួន និងបញ្ជូនទៅដាក់ឃុំឃាំងនៅមន្ទីរ ស-២១ នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ គាត់ត្រូវក្រុមសួរចម្លើយនៅមន្ទីរ ស-២១ សួរចម្លើយពីរលើក។ លើកទីមួយ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ និងលើកទីពីរនៅថ្ងៃទី៥ ខែឆ្នាំដដែល។

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ គុន ត្រូវអង្គការឃាត់ខ្លួន ហើយរហូតដល់ថ្ងៃទី១០ ខែធ្នូ ទើបគាត់ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១។ កន្លះខែក្រោយមក គុន ត្រូវសមមិត្តនារី នី ជាសមាជិកក្រុមសួរចម្លើយនៅមន្ទីរ ស-២១ ស្នើសុំឱ្យសរសេរចម្លើយសារភាព «អំពីផែនការរដ្ឋប្រហារនៅរដូវប្រាំង ឆ្នាំ១៩៧៨-១៩៧៩»។

## អ៊ា នឹម ហៅ គុន ពុំមានឈ្មោះក្នុងបញ្ជីអ្នកទោសដែលត្រូវកម្ទេចរបស់មន្ទីរ ស-២១

ប្រធានមន្ទីរ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានបញ្ជាក់ថា អ្នកទោសដែលជាកម្មាភិបាលខ្មែរក្រហមមានឋានៈមធ្យម និងខ្ពស់ ដែលត្រូវបានចាប់ខ្លួនយកមកដាក់ឃុំឃាំងនៅក្នុងមន្ទីរ ស-២១ គឺមានទាំងប្រពន្ធ និងកូនផង។ ខណៈដែល គុន ត្រូវអង្គការឃាត់ខ្លួននៅដើមខែធ្នូ ឆ្នាំ១៩៧៨ ប្តីរបស់គាត់ឈ្មោះ អ៊ុន លន ហៅ ណាត ក៏ត្រូវអង្គការចាប់ខ្លួននៅរយៈពេលជាង១០ថ្ងៃក្រោយមក គឺនៅ

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨។ ឯកសារបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចចំនួនបីឯកសារ មានជាង ៦០០ទំព័រ បានបង្ហាញឱ្យឃើញពីការចាប់ខ្លួនមនុស្សជាច្រើនពាន់នាក់ ពាក់ព័ន្ធនឹងការរៀបចំផែនការក្បត់អង្គការ ហើយអ្នកទោសខ្លះមានទាំងប្តី និងប្រពន្ធកូនផង។ ឧទាហរណ៍ បញ្ជីរាយនាមកម្មាភិបាលជាន់ខ្ពស់របស់ ប៉ុល ពត និងបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចឆ្នាំ១៩៧៨ បានបង្ហាញឱ្យឃើញពីការចាប់ខ្លួនយោធាជាន់ខ្ពស់ខ្មែរក្រហមជាប្តីនិងប្រពន្ធនៅកងពល៧០៣ ចំនួន១០គូ មកដាក់ឃុំឃាំងនៅក្នុងមន្ទីរ ស-២១ ហើយអ្នកទាំងនោះត្រូវបានកម្ទេចចោលនៅក្នុងឆ្នាំ១៩៧៨។ ឌុច បានបញ្ជាក់នៅក្នុងអង្គសវនាការលើសំណុំរឿង០០១ថា នៅឆ្នាំ១៩៧៨ មន្ទីរ ស-២១ បានទទួលអ្នកទោសដែលជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមដែលបានចាប់ខ្លួននៅភ្នំពេញ ភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរចាស់ និងភូមិភាគឧត្តរថ្មី ចំនួន២៥នាក់ ហើយអ្នកទាំងនោះត្រូវដាក់ឃុំឃាំងនៅក្នុងគុកពិសេសដាច់ពីអ្នកទោសឯទៀតនៅមន្ទីរ ស-២១។ ក្នុងចំណោមប្តីប្រពន្ធទាំង ១០គូ និងអ្នកទោសសំខាន់ៗទាំង២៥នាក់ដែលជាប់ឃុំឃាំង ពុំមានឈ្មោះ អ៊ា នឹម ហៅ គុន នៅក្នុងនោះឡើយ។ ហ៊ុយ វណ្ណៈ បានសន្និដ្ឋាននៅក្នុងសំណេររបស់ខ្លួនថា អ៊ា នឹម ហៅ គុន ជាប្រពន្ធរបស់ អ៊ិន លន ហៅ ណាត និងជា សំអាត ជាប្រពន្ធរបស់ សុន ទី ហៅ ទាញ អតីតភស្តុភាសេនាធិការ គឺមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចក្នុងឆ្នាំ១៩៧៨ ឡើយ។

នៅចុងសន្លឹកទំព័រទី៤៩ នៃចម្លើយសារភាពរបស់ខ្លួន សុន ទី ហៅ ទាញ បានសរសេរអក្សរល្អិតៗនៅចំហៀងលិខិតដែលគាត់សរសេរផ្ញើទៅលេខាបក្សថា «ប្រពន្ធខ្ញុំ និងប្រពន្ធ ណាត អត់ដឹងអីទេបង» សុន ទី ហៅ ទាញ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៨ ជាថ្ងៃដែល គុន ត្រូវអង្គការបញ្ជូនទៅដល់មន្ទីរ ស-២១។ នៅក្នុងអង្គសវនាការសួរដេញដោលក្នុងករណីសំណុំរឿង០០១ ឌុច បានបញ្ជាក់ពីទំនាក់ទំនងការងារនៅក្នុងមន្ទីរ ស-២១ រវាងគាត់ សុន សេន និង នួន ជា ស្តីពីការដាក់បញ្ចូលឈ្មោះអ្នកទោសទៅក្នុងបញ្ជីកម្ទេច និងដកឈ្មោះអ្នកទោសឬអ្នកជាប់ពាក់ព័ន្ធមួយចំនួន ចេញពីបញ្ជីកម្ទេច។ ឌុច បានទទួលបញ្ជាពី សុន សេន និង នួន ជា ឱ្យដកឈ្មោះ ឬលុបឈ្មោះអ្នកទោសណាដែលនៅក្នុងចម្លើយសារភាពរបស់អ្នកនោះ ដែលមាននិយាយពាក់ព័ន្ធឬប៉ះពាល់ដល់កម្មាភិបាលដែលមានឋានៈខ្ពស់ៗដូចជា ខៀវ សំផន, សុន សេន និង អៀង សារី។ ករណីមួយទៀតដែល នួន ជា ព្រមាន ឌុច ឱ្យចេះពីរបៀបរបបធ្វើការនៅក្នុងមន្ទីរ ស-២១ គឺទាក់ទងនឹងការស្នើសុំយោបល់សម្រេចពី នួន ជា ដោយ ឌុច អំពីថាតើគួរដាក់ឈ្មោះបញ្ចូល ឬមិនដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកទោស ចំពោះការឆ្លើយដាក់ឈ្មោះ ឿន ដែលត្រូវជាកូនប្រសាររបស់ អៀង សារី ថាបានជាប់ពាក់ព័ន្ធនឹងផែនការក្បត់បក្ស។ នួន ជា បានប្រាប់ ឌុច ឱ្យដាក់បញ្ជាទៅក្រុមអ្នកសួរចម្លើយ កុំឱ្យរវីរវល់ ឬលុបចោលរាល់ចម្លើយដែលបានឆ្លើយដាក់ ឿន។ ស្រដៀងគ្នានេះដែរ នៅពេលដែល ខៀវ សំផន ត្រូវបានអ្នកទោសផ្សេងទៀតឆ្លើយដាក់នៅក្នុងចម្លើយសារភាព ហើយ ឌុច បានរាយការណ៍ប្រាប់ទៅ នួន ជា ឌុច ត្រូវបានស្តីបន្ទោស ហើយគាត់ក៏ទទួលបញ្ជាឱ្យដកឈ្មោះ ខៀវ សំផន ចេញពីចម្លើយសារភាពដែរ។

អ៊ា នឹម ហៅ គុន គឺជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងរោងចក្រតម្បាញ ត៥។ គាត់បាននិយាយនៅក្នុងឯកសារ «អំពីផែនការរដ្ឋប្រហារនៅរដូវប្រាំង ឆ្នាំ១៩៧៨-១៩៧៩» ថា គាត់មានមនោសញ្ចេតនាជ្រាលជ្រៅជាមួយ ប៉ុល ពត និង នួន ជា ទាំងជីវិតគ្រួសារ និងការងារ។ តាមរយៈឯកសារនេះ គុន បានបង្ហាញថា គាត់មិនមានចេតនាក្បត់អង្គការឡើយ ជាពិសេសក្បត់ ប៉ុល ពត និង នួន ជា។ គុន បានសម្តែងការសោកស្តាយចំពោះការចូលរួមក្នុងសកម្មភាពធ្វើរដ្ឋប្រហារដោយមិនដឹងខ្លួន និងមានគោលបំណងដកខ្លួនចេញពីផែនការនេះទៀតផង។ គុន ត្រូវបានបញ្ជូនខ្លួនទៅដល់មន្ទីរ ស-២១ នៅជិតពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៨។ ក្រៅពីឯកសារខាងលើ និងឯកសារ «ពិនិត្យប្រវត្តិរូបបដិវត្តន៍» របស់ គុន គឺពុំមានឯកសារណាផ្សេងទៀតទេ ដែលត្រូវបានរកឃើញពាក់ព័ន្ធនឹង អ៊ា នឹម ហៅ គុន។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏នៅ

ចំពោះមុខអង្គសវនាការក្នុងសំណុំរឿង ០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឌុច បានទទួលស្គាល់ថា ចំនួនអ្នកទោសដែលយកទៅសម្លាប់មានចំនួនច្រើនជាងអ្នកទោស ដែលមានឈ្មោះនៅក្នុង «បញ្ជីកម្ទេច» ធ្វើឡើងដោយកម្មាភិបាលមន្ទីរ។

តាមរយៈអំណះអំណាងខាងលើ គុន អាចត្រូវបានដោះលែងចេញពីមន្ទីរ ស-២១ វិញ ដោយសារមនោសញ្ចេតនាបុគ្គលរវាងមេដឹកនាំកំពូល ជាពិសេស នួន ជា ជាមួយនឹង គុន និងគាត់អាចត្រូវបានសម្លាប់ចោលនៅជើងឯកជាមួយប្តីគាត់ ដោយពុំមានការសួរចម្លើយ និងពុំបានចុះឈ្មោះក្នុងបញ្ជីកម្ទេច ដោយសារតែពេលវេលាតិចពេកប៉ុន្តែមានអ្នកទោសច្រើនពេក ដែលត្រូវកម្ទេចចោល មុននឹងរបបខ្មែរក្រហមដួលរលំទាំងស្រុងនៅដើមខែមករា ឆ្នាំ១៩៧៩។

## ប្រវត្តិរូបសង្ខេប អ៊ា នឹម ហៅ គុន

អ៊ា នឹម កើតនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៤៣ នៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ។ នឹម មានឪពុកឈ្មោះ អ៊ា ឆួយ និងម្តាយឈ្មោះ ប្រាក់ ហេង។ ឪពុក នឹម មានមុខរបរជាកម្មករក្នុងទីក្រុង និងបានចូលរួមបម្រើបដិវត្តន៍ដោយសារតែការស្រឡាញ់មាគ៌ាបដិវត្តន៍។ នឹម មានបងប្អូនបង្កើតចំនួន៩នាក់។ បងប្រុសស្រីទាំង ៤នាក់របស់គាត់គឺជាសាស្ត្រាចារ្យ គ្រូបង្រៀន ពេទ្យ និងមេផ្ទះ។ នឹម ជានិស្សិតរៀននៅមហាវិទ្យាល័យអក្សរសាស្ត្រ។ គាត់ទទួលបានសញ្ញាបត្រផ្នែកអក្សរសាស្ត្រ សិល្បៈ និងវេយ្យាករណ៍ខ្មែរ ព្រមទាំងបានបម្រើការជាសាស្ត្រាចារ្យទុតិយភូមិ មុនពេលគាត់ចូលបម្រើក្នុងចលនាបដិវត្តន៍ខ្មែរក្រហម។ នឹម បានរៀបការជាមួយ អ៊ិន លន ហៅ សមមិត្ត ណាត ជាអតីតប្រធានកងពល១២ ជាប្រធានមន្ទីរ ស-២១ និងជាកម្មាភិបាលបម្រើការនៅក្នុងផ្នែកនយោបាយនៅក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

មុនចូលបម្រើក្នុងជួរបដិវត្តន៍ នឹម មានអត្តចរិតស្លូតបូត សុភាពរាបសារ អំណត់ ទុយមុយមិនសូវនិយាយស្តី និងចូលចិត្តភាពស្ងប់ស្ងាត់។ គាត់ក៏ជាមនុស្សទន់ខ្សោយ គ្មានកម្លាំង និងមិនចូលចិត្តអំនួត។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៦៨ នឹម បានចូលបម្រើបដិវត្តន៍នៅក្រុងភ្នំពេញ តាមរយៈឈ្មោះ សា ខន ដោយមូលហេតុស្អប់ខ្ពើមពួកសក្តិភូមិ និងឈឺចាប់ចំពោះការកាប់សម្លាប់អ្នកស្នេហាជាតិ។ នឹម មានឈ្មោះបដិវត្តន៍ថា គុន។ តាំងពីបានចូលបម្រើបដិវត្តន៍រួចមក គុនបានកែប្រែអត្តចរិតរបស់ខ្លួនទៅជាមនុស្សរួសរាយរាក់ទាក់រឹងមាំ និងចូលចិត្តការងារពលកម្ម។

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧០ គុន ត្រូវសមមិត្ត អាំ ជ្រើសរើសឱ្យធ្វើជាប្រធានសមាគមនារី កម្ពុជាប្រជាធិបតេយ្យ (សនកប) នៅក្នុងក្រុងភ្នំពេញ។ គុន ឯកភាពធ្វើកិច្ចការនេះ ដោយសារតែគាត់ពិនិត្យឃើញថាសមាគមនេះល្អ និងមានឧត្តមគតិស្នេហាជាតិប្រជាជន។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧២ គុន បានចូលជាសមាជិកអង្គការបក្សនៅក្នុងមន្ទីរ ៣០៥ តាមរយៈការទទួលខុសត្រូវរបស់ សុន ទី ហៅ ទាញ។ ក្រោយមកទៀត គុនបានទទួលតំណែងជាអនុប្រធានរោងចក្រតម្បាញ ត៥ រហូតដល់ថ្ងៃឃាត់ខ្លួននៅចុងឆ្នាំ១៩៧៨។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ អ៊ា នឹម ហៅ គុន ពិតប្រាកដប៉ុណ្ណាណានោះទេ។***



*មិត្តនារីកម្មករនៅរោងចក្រតម្បាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍

## ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការនៃកំណត់អត្តសញ្ញាណសហគមន៍ ជនជាតិដើមភាគតិចស្ទៀង

ឃ្មុំ រ៉ា



មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ បើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគោលនយោបាយជាតិ ទាក់ទងនឹងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការនៃការកំណត់អត្តសញ្ញាណសហគមន៍ ដោយមានការចូលរួមពីប្រជាជន ជនជាតិដើមភាគតិចស្ទៀង មន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ រដ្ឋបាលស្រុកមេមត់ អាជ្ញាធរឃុំទន្លូង និងអាជ្ញាធរភូមិក្តុលលើ ស្ថិតនៅទីតាំងផ្ទះសហគមន៍ស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រសួងអភិវឌ្ឍន៍ជនបទ បានបើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការនៃការកំណត់អត្តសញ្ញាណសហគមន៍ ដោយមានការចូលរួមពីប្រជាជន ជនជាតិដើមភាគតិចស្ទៀង មន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ រដ្ឋបាលស្រុកមេមត់ អាជ្ញាធរឃុំទន្លូង និងអាជ្ញាធរភូមិក្តុលលើ ស្ថិតនៅទីតាំងផ្ទះសហគមន៍ស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ភូមិក្តុលគឺជាទីកន្លែងដែលសម្តេច ហ៊ុន សែន ធ្លាប់រស់នៅមុនពេលសម្តេចរត់គេចខ្លួនទៅប្រទេសវៀតណាម នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីស្នើសុំការគាំទ្រ និងប្រមូលកម្លាំង វាយផ្តួលរំលំរបបខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ជាកិច្ចចាប់ផ្តើម លោក ដាន់ចន្ទី ជំទប់ទី១ឃុំទន្ទឹង បានឡើងមានមតិស្វាគមន៍ ចំពោះមន្ត្រីនៃក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ រដ្ឋបាលស្រុកមេមត់ អាជ្ញាធរភូមិក្តុលលើ និងប្រជាពលរដ្ឋរស់នៅភូមិក្តុលលើ ចំពោះការអញ្ជើញមកចូលរួមនាថ្ងៃនេះ។ លោក ដាន់ចន្ទីបានលើកឡើងថា៖ ខ្ញុំសប្បាយចិត្តបានឃើញលោកតា លោកយាយ អ៊ំ ពូមីង បង និងប្អូនៗបានអញ្ជើញចូលរួមប្រជុំ។ លោកបន្តថា បងប្អូននៅភូមិក្តុលលើភាគច្រើនគឺជាជនជាតិដើមភាគតិចស្ទៀង ដែលមានជីដូន ជីតា ម្តាយ ឪពុក ចេះនិយាយភាសាស្ទៀងរួមទាំងមានប្រពៃណីទំនៀមទម្លាប់ ហើយការប្រជុំនេះគឺផ្តោតលើបងប្អូនជនជាតិដើមភាគតិចស្ទៀងរស់នៅភូមិក្តុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំតែម្តង។



មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ បើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគោលនយោបាយជាតិ ទាក់ទងនឹងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការនៃការកំណត់អត្តសញ្ញាណសហគមន៍ ដោយមានការចូលរួមពីប្រជាជន ជនជាតិដើមភាគតិចស្ទៀង មន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ រដ្ឋបាលស្រុកមេមត់ អាជ្ញាធរឃុំទន្ទឹង និងអាជ្ញាធរភូមិក្តុលលើ ស្ថិតនៅទីតាំងផ្ទះសហគមន៍ស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកទៀត លោក មាស សម្បត្តិ គឺជាអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ បានមានប្រសាសន៍ថា៖ កាលពីលើកមុនខ្ញុំបានចុះមកជួបជាមួយពុកម៉ែបងប្អូននៅភូមិក្តុលលើម្តងរួចមកហើយ ទាក់ទងនឹងការផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ហើយបានសន្យាថាខ្ញុំចុះជួបពុកម៉ែបងប្អូនជនជាតិដើមភាគតិចស្ទៀងម្តងទៀត គឺនៅថ្ងៃនេះតែម្តង។ ចំណែកអ្នកស្រី សំ សុម៉ាលី អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ បានចោទជាសំណួរថា ហេតុអ្វីបានជាត្រូវហៅថាជនជាតិដើមភាគតិចស្ទៀង? អ្នកស្រី សំ សុម៉ាលី បានពន្យល់ថា ៖ ថ្ងៃនេះខ្ញុំលើកឡើងពីប្រធានបទ ការផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការកំណត់អត្តសញ្ញាណសហគមន៍ ព្រោះជនជាតិដើមភាគតិចស្ទៀង គឺជាជនជាតិដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនជាតិទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព និងឯកជនភាព។ អ្នកស្រី សំ សុម៉ាលី បានបន្តថា៖ បងប្អូនជនជាតិដើមភាគតិចមិនហ៊ានទទួលស្គាល់ខ្លួនឯងជាជនជាតិដើមភាគតិចទេ ព្រោះខ្លាចមានការរើសអើង។ អ្នកស្រីលើកឧទាហរណ៍ពីបុរសជនជាតិកួយម្នាក់នៅខេត្តកំពង់ធំ គ្រាន់តែការស្លៀកពាក់សម្លៀកបំពាក់ពណ៌ក្រហម មានការរើសអើងថា «អីចឹង! ឱ្យតែជនជាតិស្លៀកពាក់អ្វីមិនដែលប្រឡំគេ» ទង្វើទាំងនេះបង្ហាញពីការរើសអើងពូជសាសន៍។

អ្នកស្រី សំ សុម៉ាលី ចង់ឱ្យប្រជាជនដែលជាជនជាតិដើមភាគតិចរស់នៅក្នុងភូមិក្តុលលើ កំណត់អត្តសញ្ញាណថា ខ្លួនជាជនជាតិដើមភាគតិចស្ទៀង ដើម្បីរក្សាភាសា ប្រពៃណី ទំនៀមទម្លាប់ និងឈានទៅរកការអភិវឌ្ឍន៍។

កញ្ញា ទី វិចិត្រកញ្ញា មានតួនាទីជាអនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទបានលើកឡើងអំពីដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចជាជំហានៗដូចខាងក្រោម៖

**ជំហានទី១៖** ផ្សព្វផ្សាយការយល់ដឹងនៅក្នុងចំណោមអាជ្ញាធរជាតិថ្នាក់ខេត្ត (មន្ទីរជំនាញពាក់ព័ន្ធ) ស្រុក ឃុំ ភូមិ និងសហគមន៍ជនជាតិដើមភាគតិច។

**ជំហានទី២៖** សហគមន៍ជនជាតិដើមភាគតិចបង្ហាញឆន្ទៈក្នុងការចាប់ផ្តើមដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច។



មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ បើកសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលនយោបាយជាតិ ទាក់ទងនឹងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នីតិវិធី និងទម្រង់ឯកសារដំណើរការនៃការកំណត់អត្តសញ្ញាណសហគមន៍ ដោយមានការចូលរួមពីប្រជាជន ជនជាតិដើមភាគតិចស្ទៀង មន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ រដ្ឋបាលស្រុកមេមត់ អាជ្ញាធរឃុំទន្លូង និងអាជ្ញាធរភូមិក្តុលលើ ស្ថិតនៅទីតាំងផ្ទះសហគមន៍ស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**ជំហានទី៣៖** ធ្វើការផ្សព្វផ្សាយដល់សហគមន៍គោលដៅ។

**ជំហានទី៤៖** សហគមន៍ជនជាតិដើមភាគតិចបោះឆ្នោតជ្រើសរើសតំណាងគណៈកម្មការ និងប្រកាសសុ័យអត្តសញ្ញាណខ្លួនជាជនជាតិដើមភាគតិច និង

**ជំហានទី៥៖** ការដាក់ពាក្យការវាយតម្លៃ និងទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ។

ចុងបញ្ចប់នៃសិក្ខាសាលាអ្នកស្រីសំ សុម៉ាលី ថ្លែងអំណរគុណដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ អាជ្ញាធរស្រុកមេមត់ ព្រមទាំងប្រជាជនដែលបានចូលរួមស្តាប់ការប្រជុំនៅថ្ងៃនេះដោយយកចិត្តទុកដាក់ និងជូនពរឱ្យមានសុខភាពល្អ ជួបតែសេចក្តីសុខ ហើយត្រឡប់ទៅផ្ទះវិញប្រកបដោយសុវត្ថិភាព។





មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ ទស្សនាផ្ទះសហគមន៍ស្ទៀងភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានឈុំ រ៉ា គឺជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មធ្វើបទបង្ហាញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ី ស៊ីដា ៖ តស៊ូរស់ដើម្បីកូននិងប្រទេសកម្ពុជា

**សូ ហ្វារីណា**

អ្នកស្រាវជ្រាវប្រចាំមជ្ឈមណ្ឌលចងចាំជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី បានចុះសួរសុខទុក្ខជនភៀសសឹកមកពីភូមិពង្រ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យជាលើកទី២ នៅឯផ្ទះរបស់គាត់ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦។ នៅពេលទៅដល់ផ្ទះរបស់គាត់នៅវេលាម៉ោង៨ព្រឹក អ៊ី ស៊ីដា កំពុងមើលថែកូនភ្លោះតូចៗទាំងពីររបស់គាត់ ចំណែកប្តីរបស់គាត់ទទួលបានការងារជាជាងសំណង់នៅក្នុងភូមិ និងរកកម្រៃបាន៤០,០០០រៀល ក្នុងមួយថ្ងៃ។ នៅពេលសាកសួរអំពីស្ថានភាពសុខភាព ស៊ីដា បាននិយាយថា កូនតូចៗទាំងពីរទើបចេញមកពីមន្ទីរសម្រាកព្យាបាល ដោយសារមានជំងឺគ្រុនផ្តាសាយ ដោយសារអាកាសធាតុត្រជាក់ខ្លាំងកាលពីពីរសប្តាហ៍កន្លងទៅ។ ចំណែកកូនប្រុសច្បងរបស់គាត់ទៅរៀននៅសាលាបឋមសិក្សាពូតាំងធម្មតា។ អស់រយៈពេល៥០ថ្ងៃហើយ ចាប់តាំងពី ស៊ីដា និងក្រុមគ្រួសារ មករស់នៅភូមិពូតាំង ដោយសារការឈ្លានពានរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា។ ក្រុមគ្រួសារ ស៊ីដា គឺជាគ្រួសារមួយក្នុងចំណោមមនុស្សប្រហែល១សែននាក់ទៀតដែលកំពុងរស់នៅជាជនភៀសសឹក ចាប់តាំងពីការឈ្លានពានរបស់ទាហានថៃមកលើប្រទេសកម្ពុជាក្នុងដំណាក់កាលទីពីរកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥។


អ៊ី ស៊ីដា និងកូនស្រី ភៀសខ្លួនពីភូមិពង្រ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ មករស់នៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលសាកសួរអំពីរយៈពេលនៃការស្នាក់នៅបន្តក្នុងភូមិពូតាំង ស៊ីដា បានរៀបរាប់ថា៖ «ខ្ញុំចង់ត្រឡប់ទៅស្រុកកំណើតនៅភូមិពង្រ ខេត្តឧត្តរមានជ័យវិញ ប៉ុន្តែមិនទាន់ដឹងថ្ងៃណាទេ។ ខ្ញុំបានទូរសព្ទទៅសួរម៉ែ គាត់ប្រាប់ថា «កុំអាលត្រឡប់មកផ្ទះវិញ ព្រោះប្រជាជនថៃបានបោះឆ្នោតឱ្យអ្នកដឹកនាំចាស់ [អានុទីន ឆានវីរៈគុល] ដែលធ្លាប់បានឈ្លានពានយើង។ ស្ថានភាពហាក់ដូចជាមិនសូវស្រួលសោះ។ បើកូនអាចបន្តនៅខេត្តមណ្ឌលគិរីបាន ចូរនៅទីនោះសិនចុះ ដោយសារកូនមានកូនតូចៗ។ រង់ចាំស្រុកមានសុវត្ថិភាព ១០០ភាគរយ ចាំម៉ែទូរសព្ទឱ្យកូនវិលត្រឡប់មកផ្ទះយើងវិញ»។ ព្ទដូច្នេះ ខ្ញុំក៏មិនទាន់ហ៊ានត្រឡប់ទៅវិញដែរ។ ប្រហែលជាខ្ញុំរស់នៅក្នុងភូមិពូតាំងហ្នឹងយូរបន្តិចហើយមើលទៅ។ ខ្ញុំរង់ចាំឱ្យមានសុវត្ថិភាពពេញលេញសិន និងទម្រាំតែកូនប្រុស

របស់ប្អូនរបស់ខ្ញុំ រៀនដល់ថ្នាក់ទី៦ ឬទី៧ នៅខេត្តមណ្ឌលគិរីនេះសិនហើយមើលទៅ។ នៅពេលយើងដូរកន្លែងរស់នៅច្រើនពេក ធ្វើឱ្យកូនគ្មានអារម្មណ៍ប្តេជ្ញាក្នុងការសិក្សារៀនសូត្រទេ។ ដូច្នេះប្តីប្រពន្ធរបស់ខ្ញុំទាំងពីរនាក់បានពិភាក្សាគ្នា សុំរស់នៅក្នុងភូមិពូតាំងបន្តទៀតនេះ។ បងរបស់ខ្ញុំបានយល់ព្រមឱ្យក្រុមគ្រួសារខ្ញុំ រស់នៅជាមួយគាត់ក្នុងផ្ទះរបស់គាត់បន្តទៀត»។

នៅពេលសួរអំពីផលវិបាកនៃការកៀសសឹកនិងការឈ្លានពានរបស់ទាហានថៃមកលើក្រុមគ្រួសារគាត់ ស៊ីដា ឆ្លើយថា «ការលំបាកប៉ុណ្ណេះ មិនស្មើនឹងការលំបាករបស់មនុស្សជំនាន់មុនដែលបានតស៊ូឆ្លងកាត់សង្គ្រាម និងរស់រានមកដល់សព្វថ្ងៃនេះឡើយ។ ឪពុករបស់ខ្ញុំអាយុ៥៨ឆ្នាំ។ គាត់ធ្លាប់ត្រូវបានជម្លៀសកាលពីក្មេង ធ្លាប់រស់នៅឆ្លងកាត់សម័យសង្គ្រាម និងអាចរស់រានរហូតដល់សព្វថ្ងៃ។ យើងមានការស្ងើចសរសើរនិងអាណិតដល់វីរកងទ័ពកម្ពុជាដែលបានការពារយើងនិងទឹកដីយើង។ ខ្ញុំសូមសរសើរដោយស្មោះចំពោះក្រុមគ្រួសាររបស់វីរកងទ័ពដែលសុខចិត្តរស់នៅបែកគ្នា និងផ្តល់កម្លាំងចិត្តដល់វីរកងទ័ពដើម្បីការពារដែនដីរបស់យើង។ ទោះបីអាកាសធាតុនៅទីនេះត្រជាក់ខ្លាំងសម្រាប់ខ្ញុំ និងមានបញ្ហាខ្វះខាតខាងសេដ្ឋកិច្ច យើងអាចសម្របខ្លួនបន្តិចម្តងៗ។ សម្រាប់យើងជាឪពុកម្តាយវ័យក្មេងជំនាន់នេះ ត្រូវតស៊ូដើម្បីកូនៗបន្តទៀតនិងដើម្បីប្រទេសយើង»។ គាត់បានបន្ថែមថា «ខ្ញុំសង្ឃឹមថា យើងនឹងទទួលបានយុត្តិធម៌ ហើយពិភពលោកនឹងមិនឈរឱបដៃមើលយើងលំបាកឡើយ»។


កូនប្រុសច្បងរបស់ អ៊ី ស៊ីដា (រូបខាងស្តាំ) និងមិត្តភក្តិ បានមកអានសៀវភៅនៅមជ្ឈមណ្ឌលសហគមន៍ជនជាតិភាគតិច ក្រោយពេលសម្រាកពីការរៀនសូត្រនៅក្នុងថ្នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អតីតប្រធានជំរំណងចាន់ និងជាមេបញ្ជាការ តំបន់ប្រតិបត្តិការសឹក (តំបន់៥)

ផាង សម្ភស្ស



ឡៃ វីរៈ (រូបខាងស្តាំ) ផ្តល់បទសម្ភាសន៍ដល់ ឡុង ដានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡៃ វីរៈ អាយុ៧៣ឆ្នាំ មានស្រុកកំណើតនៅភូមិសីផ្លលិចឃុំសីផ្ល ស្រុកអូរជ្រៅ ខេត្តបាត់ដំបង។ បច្ចុប្បន្ន ឡៃ វីរៈ រស់នៅភូមិសីផ្លលិច ឃុំសីផ្ល ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានរៀបរាប់ថា៖ ខ្ញុំមានឪពុកឈ្មោះ ឡៃ សារ៉ូ ស្លាប់នៅក្នុងរបបខ្មែរក្រហម និងម្តាយឈ្មោះ អឿ ហាច ស្លាប់នៅក្នុងឆ្នាំ២០១១។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ក្នុងនោះមានស្រី៣នាក់ និងប្រុស៣នាក់។ បងប្អូនខ្ញុំស្លាប់ម្នាក់ ហើយខ្ញុំគឺជាកូនទីពីរនៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ដា លាភសព្វថ្ងៃអាយុ៦៦ឆ្នាំ។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានឈប់រៀនបន្ទាប់ពីប្រឡងចប់ថ្នាក់ឌីប្លូម (ថ្នាក់ទី៣សង្គមចាស់) នៃវិទ្យាល័យស៊ីសុផុន។

នៅពេលខ្មែរក្រហមចូលមកដល់ក្នុងឆ្នាំ១៩៧៥ ខ្ញុំរស់នៅភូមិសីផ្លលិច និងបានប្តូរឈ្មោះពី ឡៃ វីរៈ មកឈ្មោះ ខុល ដើម្បីកុំឱ្យខ្មែរក្រហមដឹងពីប្រវត្តិរូប។ ពេលនោះខ្ញុំស្ថិតនៅក្នុងកងយុវជនធ្វើការងារលើកទំនប់ និងជីកប្រឡាយនៅក្នុងឃុំសីផ្ល។

នៅឆ្នាំ១៩៧៧ ខ្ញុំបានរត់ទៅថៃព្រោះបានឮការនិយាយតៗគ្នាថា ក្រុមខ្មែរសេរីនៅតាមជាយដែនខ្មែរ-ថៃ។ ខ្ញុំមិនចង់រស់នៅជាមួយក្រុមខ្មែរក្រហមទេ។ ពេលរត់ទៅប្រទេសថៃ ខ្ញុំមានគ្នា៦នាក់ រួមជាមួយកាំភ្លើង៦ដើម ដែលលួចពីឈ្លបភូមិ។ ក្រុមរបស់ខ្ញុំបានធ្វើដំណើររហូតទៅដល់តាសៀវក្នុងស្រុកថ្មពួក ក៏មានទាហានសេរីកាជាតិខ្មែរ ដឹកនាំដោយ ជា រិទ្ធីឈុត នាំក្រុមរបស់ខ្ញុំទៅផ្ញើនៅជំរំទាហានអ្នកតស៊ូក្នុងភូមិសាង៉ែក្នុងប្រទេសថៃ។ ខ្ញុំរស់នៅភូមិសាង៉ែរយៈពេល៤ទៅ៥ខែ ក៏ត្រឡប់មកស្រុកខ្មែរវិញ។ ក្រុមខ្ញុំមានគ្នាឡើងដល់១២នាក់ ប៉ុន្តែមានកាំភ្លើងតែ៦ដើមតែប៉ុណ្ណោះ និងមានម៉ាស៊ីនថត២គ្រឿង។ ក្រុមរបស់ខ្ញុំដើរស្វែងរករណ្ដៅសាកសពដែលខ្មែរក្រហមបានសម្លាប់ប្រជាជន ដើម្បីថតរូបយកទៅឱ្យ ជា រិទ្ធីឈុត នៅប្រទេសថៃ សម្រាប់ធ្វើការផ្សព្វផ្សាយដល់អន្តរជាតិ។ ក្រុមខ្ញុំទាំង១២នាក់បានធ្វើដំណើររហូតដល់ស្រុកស្វាយស៊ីសុផុន ហើយជួបជាមួយប្រជាជន ដើម្បីស្វែងរកទីតាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម។ ក្រុមរបស់ខ្ញុំបានស្រាវជ្រាវរយៈពេលប្រហែល១ខែទើបថតបានទីតាំងរណ្ដៅសាកសពដែលខ្មែរក្រហមបានសម្លាប់ប្រជាជន។ បន្ទាប់មកក្រុមខ្ញុំបានត្រឡប់ទៅភូមិសាង៉ែវិញ ដើម្បីប្រគល់រូបថតឱ្យ ជា រិទ្ធីឈុត។

ក្រោយមក ជា រិទ្ធីឈុត និងខ្ញុំបានដឹកនាំកម្លាំង១៥០នាក់ចុះមកស្រុកខ្មែរ។ ក្រុមខ្ញុំបានមកស្នាក់នៅប្រាសាទស្តុកកក់ធំ។ ពេលក្រុមខ្ញុំស្នាក់នៅប្រាសាទស្តុកកក់ធំបានរយៈពេលប្រហែល២សប្តាហ៍ ក៏មានក្រុមលោក ជា ឆៃយ៉ា និង អ៊ិន សាខន មកដល់ប្រាសាទស្តុកកក់ធំដែរ។ ជា រិទ្ធីឈុត និងខ្ញុំបានដឹកនាំកម្លាំង១៥០នាក់មកបង្កើតជំរំណងចាន់ដែលស្ថិតនៅក្បែរបង្គោលឡាក់ព្រំដែនលេខ៤៣។ បង្គោលឡាក់ព្រំដែនលេខ៤៣ មានទីតាំងនៅជិតវត្តណងម៉ាក់មុន ហៅវត្តភូមិថ្មីរបស់ថៃ ដោយរបងវត្តណងម៉ាក់មុននៅជាប់អូរ។ ចំណែកបង្គោលឡាក់ព្រំដែនលេខ៤៣ ស្ថិតនៅខាងកើតអូរប្រហែល៥០ម៉ែត្រ។ រីឯជំរំចាស់ហៅជំរំរាហូចាប់ច័ន្ទ ស្ថិតនៅចន្លោះជំរំណងចាន់ និងជំរំឫទ្ធិសែន(ជំរំ០០៧)។ ជំរំចាស់ដឹកនាំដោយលោកតា វ៉ាន់ សារ៉ែន និង អង់គ្រេ អ៊ុកថុល។ ជំរំណងចាន់ដឹកនាំដោយជា រិទ្ធីឈុត និងខ្ញុំ(ឡូវីរៈ)។ ក្រោយមកជំរំណងចាន់កាន់តែមានប្រជាជនមករស់នៅច្រើន ហើយអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាបានរៀបចំរចនាសម្ព័ន្ធ ដូចជា សាលារៀន មន្ទីរពេទ្យ និងស្ថាប័ននានានៅក្នុងជំរំណងចាន់។

ពេលលោកគង់ ស៊ីលាស់អតីតនាយទាហានជើងទឹកដែលធ្លាប់បានសិក្សានៅប្រទេសបារាំងធ្វើដំណើរមកដល់ជំរំណងចាន់នៅឆ្នាំ១៩៧៩ ពេលនោះក៏មានអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាចូលមកផ្តល់អង្ករ និងស្បៀងអាហារដល់ប្រជាជននៅក្នុងជំរំណងចាន់ដែរ។ បន្ទាប់ពីរស់នៅជំរំណងចាន់បានប្រហែល២ឆ្នាំ លោក គង់ ស៊ីលាស់ បានស្លាប់ដោយសារជំងឺគ្រុនចាញ់ ទោះបីជាមានវេជ្ជបណ្ឌិតជនជាតិបារាំងជួយព្យាបាលគាត់ក៏ដោយ ក៏មិនអាចជួយសង្គ្រោះបានដែរ។ លោក គង់ ស៊ីលាស់ បានស្លាប់នៅបន្ទាយអូរបុស្សីស្រុក។

នៅឆ្នាំ១៩៨៣ កងទ័ពវៀតណាមបានវាយបែកជំរំណងចាន់។ ជំរំណងចាន់ត្រូវបានផ្លាស់មកតាំងនៅតំបន់ព្រៃចាន់ ហើយពេលនោះមានប្រជាជនមួយចំនួនធំបានចេញពីជំរំណងចាន់ទៅរស់នៅជំរំដងរែក។ បន្ទាប់មក ជំរំណងចាន់ ត្រូវបានរើចេញពីតំបន់ព្រៃចាន់ត្រឡប់មកកន្លែងដើមវិញ គឺជំរំណងចាន់ចាស់វិញ។ ចំណែកខ្ញុំបានមកបោះទីតាំងនៅអូរបីជាន់ ដែលភាគច្រើនគឺជាទាហានប៉ារ៉ា និងគ្រួសារទាហានប៉ារ៉ា។ ខ្ញុំរស់នៅជំរំអូរបីជាន់រហូតសង់បានផ្ទះ ផ្លូវ និងស្រះទឹកនៅតំបន់អូរបីជាន់។

នៅចន្លោះឆ្នាំ១៩៨៦ និងឆ្នាំ១៩៨៧ មេដឹកនាំរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរបានដក ជា រិទ្ធីឈុត ត្រឡប់មកដឹកនាំនៅខាងលើ ហើយខ្ញុំត្រូវបានតែងតាំងជាមេដឹកនាំទាំងទាហានប៉ារ៉ា និងប្រជាជននៅជំរំណងចាន់។ ខ្ញុំបានក្លាយជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹក (តំបន់៥) នៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។

បន្ទាប់ពីបោះឆ្នោតសកលឆ្នាំ១៩៩៣ ទាហាននៅតំបន់ប្រតិបត្តការសឹក (តំបន់៥) ទាហាននៅតំបន់ប្រតិបត្តិការសឹក (តំបន់១) នៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងកងទ័ពនៅអគ្គភាព អ-៤២ របស់រដ្ឋកម្ពុជា បានប្រាប់បញ្ចូលគ្នាបង្កើតជាកងពលលេខ១២នៃកងយោធពលខេមរភូមិន្ទឈរជើងនិងប្រចាំការនៅកូនដំរី ក្នុងភូមិសាស្ត្រស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ មេបញ្ជាការកងពលលេខ១២ គឺ ខ្ញុំ (ឡៃ វីរៈ)។ ចំណែកមេបញ្ជាការរងកងពលលេខ១២ រួមមាន៖ លោក ងួន ហៅ ការ៉ៃ និងលោក ព្រំ មរណៈ។

បើតាមខ្ញុំដឹង ដីខ្មែរនៅតាមតំបន់បង្គោល ឡាក់ព្រំដែនលេខ៤៣ នៅអូរបីជាន់ទល់មុខភូមិណងម៉ាក់មុន (ភូមិថ្មី) របស់ថៃតំបន់បង្គោល ឡាក់ព្រំដែនលេខ៤២ រួមទាំងប្រាសាទស្តុកកក់ធំ និងតំបន់ព្រំដែនដទៃទៀត ត្រូវបានប្រទេសថៃលួចបង្កិតចូលមកជ្រៅក្នុងទឹកដីខ្មែរ និងទន្ទ្រានចូលកាន់កាប់ទឹកដីខ្មែរថែមទៀត បន្ទាប់ពីទាហាននៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរបានប្រាប់បញ្ចូលគ្នាក្នុងកងយោធពលខេមរភូមិន្ទ និងបានចាកចេញអស់ពីតំបន់ព្រំដែនខាងលើ។



ឡៃ វីរៈ អតីតប្រធានដំរំណាងចាន់ និងជាអតីតមេបញ្ជាការតំបន់ប្រតិបត្តិការសឹក (តំបន់៥) សព្វថ្ងៃរស់នៅភូមិសឹង្ហលិច ឃុំសឹង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ខ្លោងទ្វារសាលាបឋមសិក្សាព្រៃចាន់ ស្ថិតនៅក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្តីខ្ញុំបាត់បង់ជីវិតដោយសារគ្រាប់ផ្លោងរបស់ទាហានថៃ

**គាត ស្រីឡែន**



*ពិធីបុណ្យសពវីរនគរបាល ឃ្លាំង ធឿន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ឌុច ភារុន អាយុ៤៤ឆ្នាំ ត្រូវជាប្រពន្ធរបស់ ឃ្លាំង ធឿន។ ខ្ញុំមានស្រុកកំណើតនៅភូមិគោកមន ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំមានកូនចំនួន២នាក់ គឺប្រុសម្នាក់ និងស្រីម្នាក់។ កូនប្រុសច្បងរបស់ខ្ញុំមានអាយុ១៥ឆ្នាំ និងកូនស្រីពៅអាយុ១៣ឆ្នាំ។ ខ្ញុំជាមួយប្តីរបស់ខ្ញុំបានស្គាល់គ្នាតាំងពីនៅក្មេងមកម្ល៉េះ។ ខ្ញុំ និងប្តីរស់នៅភូមិក្បែរគ្នា គឺខ្ញុំរស់នៅភូមិគោកមន ចំណែកឯប្តីខ្ញុំរស់នៅភូមិតានេស ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ យើងបានចូលរៀនថ្នាក់ជាមួយគ្នា ប៉ុន្តែក្រោយមកខ្ញុំបានផ្លាស់ទៅរៀននៅក្រុងសិរីសោភ័ណវិញ។ ខ្ញុំរៀននៅក្រុងសិរីសោភ័ណមួយរយៈ ទើបខ្ញុំត្រឡប់មករស់នៅភូមិគោកមនវិញ។ ក្រោយពេលខ្ញុំត្រឡប់មករស់នៅភូមិកំណើតវិញ ប្តីខ្ញុំក៏ឈប់រៀនដែរ ហើយគាត់បានចូលធ្វើការជាប៉ូលិសនៅក្រុងសំរោង។ ពេលយើងទាំងពីរជួបគ្នាម្តងទៀត ខ្ញុំនិងគាត់ក៏ស្រឡាញ់គ្នា ហើយបានរៀបការនៅក្នុងឆ្នាំ២០១០។ បន្ទាប់ពី

រៀបការរួច ប្តីខ្ញុំបានផ្លាស់មកធ្វើការនៅប៉ូលីសប៉ុស្តិ៍រដ្ឋបាលឃុំគោកមនវិញ ចំណែកខ្ញុំបានរកស៊ីលក់បាយនិងលក់គុយទាវ។ ខ្ញុំបានសម្រេចចិត្តឈប់លក់បាយនិងលក់គុយទាវ នៅពេលខ្ញុំមានកូន ហើយបានប្តូរមកលក់អីវ៉ាន់ចាប់ហួយបន្តិចបន្តួចវិញ។

ខ្ញុំបានប្រកបមុខរបរលក់អីវ៉ាន់ចាប់ហួយរហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែក្នុងរយៈពេលថ្មីៗនេះ ខ្ញុំមិនបានប្រកបរបររកស៊ីទេ ដោយសារទាហានថៃបានឈ្លានពានទឹកដីខ្មែរ ធ្វើឱ្យខ្ញុំនិងប្រជាជនផ្សេងទៀតត្រូវភៀសខ្លួនចេញពីផ្ទះទៅរស់នៅជំរំជនភៀសសឹក។

ចាប់តាំងពីការផ្ទុះអាវុធលើកទី១ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំបានភៀសខ្លួនចេញពីផ្ទះសម្បែងទៅស្នាក់នៅផ្ទះបងប្អូននៅខេត្តសៀមរាប។ ពេលនោះខ្ញុំភៀសខ្លួនទៅជាមួយកូនៗ ចំណែកប្តីខ្ញុំនៅចាំផ្ទះ។ ប្តីខ្ញុំតែងតែនិយាយទូរសព្ទជាមួយខ្ញុំជារៀងរាល់ថ្ងៃ។ ប្តីខ្ញុំគឺជាប៉ូលីសប៉ុស្តិ៍រដ្ឋបាល ដូច្នេះគាត់ត្រូវដើរល្បាតមើលការខុសត្រូវតាមភូមិ និងការពារសុវត្ថិភាពក្នុងភូមិ។ អំឡុងពេលរត់ភៀសខ្លួនខ្ញុំមិនបានរកស៊ីលក់ដូរ ហើយកូនៗមិនបានរៀនដែរ។

បន្ទាប់ពីមានបទឈប់បាញ់រវាងកម្ពុជា-ថៃ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំនិងកូនបានត្រឡប់មកភូមិគោកមនវិញ ប៉ុន្តែមិនបានប៉ុន្មានខែផង ទាហានថៃបំពានបទឈប់បាញ់ជាមួយកម្ពុជា និងបំពានច្បាប់អន្តរជាតិ។ ទាហានថៃបានធ្វើការបាញ់ផ្លោងចូលមកទឹកដីកម្ពុជាម្តងទៀតកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ សារជាថ្មីម្តងទៀតនៅតំបន់អានសេះ។

ពេលឃើញសភាពការណ៍មិនស្រួល នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំ និងកូនទាំងពីរនាក់បានភៀសខ្លួនចេញពីភូមិគោកមនម្តងទៀត។ ចំណែកប្តីខ្ញុំមិនបានទៅជាមួយខ្ញុំដូចកាលលើកទី១ដែរ ដោយសារគាត់ត្រូវនៅធ្វើការថែរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខក្នុងភូមិឃុំ។ ខ្ញុំបានទៅស្នាក់នៅក្នុងវត្តគោកប៉ាទ្រី ស្ថិតនៅក្នុងក្រុងសៀមរាប។ ពេលស្នាក់នៅក្នុងជំរំជនភៀសសឹកក្នុងវត្តគោកប៉ាទ្រី ខ្ញុំនិងប្តីតែងតែនិយាយទូរសព្ទជាមួយគ្នាដូចរាល់ដង គឺក្នុងមួយថ្ងៃ២ដង ដូចជាសួរសុខទុក្ខគ្នាទៅវិញទៅមក ខ្ញុំក៏តែងតែប្រាប់ប្តីរបស់ខ្ញុំឱ្យប្រយ័ត្នប្រយែង និងមើលថែខ្លួន។ នៅវេលាម៉ោង៥ល្ងាច ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ប៉ូលីសប៉ុស្តិ៍រដ្ឋបាលឃុំគោកមនម្នាក់ (ប៉ូលីសស្រី) បានហៅទូរសព្ទមកខ្ញុំ និងប្រាប់ថាប្តីខ្ញុំត្រូវគ្រាប់ផ្លោងរបស់ទាហានថៃរងរបួសធ្ងន់បានបញ្ជូនទៅកាន់មន្ទីរពេទ្យនៅស្រុកចុងកាល់ហើយ។ បន្ទាប់មកបងប្រុសខ្ញុំឈ្មោះ ឌុច ប៉ាង គឺជាប្រធានភូមិគោកមន បានរៀបរាប់ប្រាប់ខ្ញុំពីហេតុការណ៍ដែលបានកើតឡើងលើប្តីខ្ញុំថា ពេលនោះមានបងៗកងទ័ពខ្មែរចំនួន៣នាក់ចង់ទិញអំពូលសូឡា ហើយប្តីខ្ញុំបាននាំបងៗកងទ័ពទាំងនោះមកតូបលក់អំពូលសូឡា ដែលជាតូបបងប្រុសខ្ញុំ ( ឌុច ប៉ាង) ស្ថិតនៅជាប់ផ្ទះខ្ញុំ។ ពេលមកដល់ ប្តីខ្ញុំបានឈប់ម៉ូតូនៅមុខតូបបងប្រុសខ្ញុំ ភ្លាមៗនោះស្រាប់តែមានគ្រាប់ផ្លោងរបស់ទាហានថៃបានធ្លាក់មកចំកណ្តាលផ្លូវ នៅខាងមុខតូបបងប្រុសខ្ញុំ ជាហេតុធ្វើឱ្យប្តីខ្ញុំត្រូវអំបែងគ្រាប់ផ្លោងស៊ុះខ្លួនតែម្តង។ ពេលខ្ញុំបានឮដំណឹងនេះ ខ្ញុំស្លុតចិត្តខ្លាំងណាស់ ហើយកាន់តែរន្ធត់ខ្លាំងថែមទៀត។ នៅខណៈពេលខ្ញុំកំពុងតែរៀបចំអីវ៉ាន់ដើម្បីទៅមើលប្តីនៅមន្ទីរពេទ្យចុងកាល់ ខ្ញុំបានទទួលដំណឹងថា ប្តីខ្ញុំបានស្លាប់នៅតាមផ្លូវពេលបញ្ជូនទៅមន្ទីរពេទ្យបាត់ទៅហើយ។ នៅវេលាម៉ោងប្រហែល៧យប់ថ្ងៃដដែល សពប្តីខ្ញុំត្រូវបានបញ្ជូនមកជំរំជនភៀសសឹកក្នុងវត្តគោកប៉ាទ្រី ដើម្បីធ្វើបុណ្យតាមប្រពៃណីសាសនា។ ចំណែកពិធីបុណ្យគម្រប់៧ថ្ងៃ ខ្ញុំមិនបានរៀបចំពិធីបុណ្យឱ្យសមរម្យជូនប្តីខ្ញុំទេ ខ្ញុំគ្រាន់តែធ្វើបាយម្ហូបយកទៅវត្តប៉ុណ្ណោះ។

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ ទើបខ្ញុំ និងកូនៗត្រឡប់មកផ្ទះវិញ។ អ្វីដែលខ្ញុំចង់ចាំពីប្តីខ្ញុំ គឺគាត់ជាមនុស្សស្លូតបូត មិនដែលឈ្លោះជាមួយខ្ញុំទេ។ ប្តីខ្ញុំឱ្យតម្លៃខ្ញុំជាប្រពន្ធណាស់។ ប្តីខ្ញុំតែងតែជួយខ្ញុំ នៅពេល

ខ្ញុំត្រូវការអ្វីមួយ។ ប្ដីខ្ញុំតែងទូន្មានកូនឱ្យខំប្រឹងរៀន ពីព្រោះប្ដីខ្ញុំចង់ឱ្យកូនធ្វើជាប៉ូលីសដូចគាត់ដែរ។ ប្ដីខ្ញុំមានបំណងចង់ទិញរថយន្តមួយគ្រឿងសម្រាប់ខ្ញុំនិងកូន ប៉ុន្តែប្ដីខ្ញុំមិនទាន់បានសម្រេចបំណងឥឡូវគាត់បានលាចាកលោកហើយ។

ទាហានថៃបានបន្តសង្គ្រាមក្នុងគោលបំណងចង់បានទឹកដីខ្មែរបានធ្វើឱ្យប្ដីខ្ញុំស្លាប់ ហើយខ្ញុំប្រែជាស្ត្រីមេម៉ាយ កូនខ្ញុំកំព្រាឪពុក និងបាត់បង់ភាពកក់ក្ដៅក្នុងគ្រួសារ។ ខ្ញុំពិតជាចង់បានយុត្តិធម៌សម្រាប់ប្ដីខ្ញុំណាស់ និងចង់ឱ្យទាហានថៃទទួលខុសត្រូវនូវអ្វីដែលខ្លួនបានបង្កឡើង។ ខ្ញុំបានបាត់បង់ប្ដីជាទីស្រឡាញ់ និងខូចខាតទ្រព្យសម្បត្តិដែលបានខិតខំរកជាយូរឆ្នាំមកហើយ។



វីរនគរបាល ឃ្លាំង ធឿន ស្លាប់ដោយសារគ្រាប់ផ្លោងរបស់ថៃបាញ់ចូលមកក្នុងភូមិគោកមន ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឌុច ភារុន ត្រូវជាប្រពន្ធរបស់ ឃ្លាំង ធឿន សព្វថ្ងៃរស់នៅភូមិគោកមន ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ូ រីណា ៖ កងដឹកជញ្ជូន

**ចាន់ ណារិទ្ធ**

ខ្ញុំឈ្មោះ ប៉ូ រីណា អាយុ៦៣ឆ្នាំ សព្វថ្ងៃប្រកបរបរធ្វើចម្ការ។ ខ្ញុំកើតនៅភូមិតាស្រី ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍-សាត់។ ។ ខ្ញុំមានឪពុកឈ្មោះ ប៉ូ ខេង ( ស្លាប់ឆ្នាំ២០១៦ ដោយសារជំងឺចាស់ជរា ) និងម្ដាយឈ្មោះ គាំ យ៉េត ( ស្លាប់ឆ្នាំ២០០០ ដោយសារជំងឺមហារីកសួត)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ គឺប្រុស២នាក់ ស្រី៥នាក់។ ខ្ញុំមានប្អូនស្រីម្នាក់ស្លាប់ ដោយសារជំងឺគាំងបេះដូង។ ខ្ញុំគឺជាកូនទី២ នៅក្នុងគ្រួសារ។ ប្ដីខ្ញុំឈ្មោះ ម៉ាច ភណ្ឌ (ស្លាប់ឆ្នាំ២០១៦ ដោយសារជំងឺ)។ ខ្ញុំមានកូនចំនួន៤នាក់គឺ ប្រុសចំនួន៣នាក់ និងស្រីម្នាក់។



ប៉ូ រីណា ប្រកបរបរធ្វើចម្ការ បច្ចុប្បន្នរស់នៅភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

កាលពីក្មេង ខ្ញុំរៀនបានត្រឹមថ្នាក់មត្តេយ្យនៅសាលាបឋមសិក្សាមហាមន្ត្រី។ មូលហេតុដែលខ្ញុំឈប់ដោយសារតែឆ្នាំ១៩៧២ ទាហានអាមេរិកាំងបានបើកយន្តហោះមកទម្លាក់គ្រាប់បែកបេ-៥២ លើភូមិរបស់ខ្ញុំ។ គ្រាប់បែកធ្លាក់ចំផ្ទះរបស់ខ្ញុំបណ្ដាលឱ្យឆាបឆេះ និងខូចខាតផ្ទះទាំងស្រុង។ បន្ទាប់ពីផ្ទះត្រូវបានខូចខាត ឪពុកម្ដាយរបស់ខ្ញុំបាននាំខ្ញុំនិងប្អូនៗធ្វើដំណើរចាកចេញពីស្រុកកំណើត មកសាងសង់ផ្ទះស្នាក់នៅលើដី ឡូបឹងជប៉ុនដែលគាត់បានទិញទុកពីមុនមក។ បន្ទាប់ពីសាងសង់ផ្ទះរួចរាល់ ឪពុកម្ដាយ ខ្ញុំបានឱ្យខ្ញុំចូលរៀននៅក្នុងសាលាវត្តសន្សំកុសល ដែលមានទីតាំងនៅជិតផ្សារដើមថ្កូវ។ ខ្ញុំរៀនបានរហូតដល់ថ្នាក់ទី៩ សង្គមចាស់។ ពេលមករស់នៅបឹងជប៉ុន ម្ដាយខ្ញុំបានប្រកបរបរលក់បន្លែ និងលក់ផ្លែឈើ។ ចំណែកឪពុកខ្ញុំធ្វើជាជាងអគ្គិសនីទី២ នៅសង្កាត់ចាក់អង្រែក្រោម។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកវាយរំដោះទីក្រុងភ្នំពេញ។ បន្ទាប់ពីទទួលបានជ័យជម្នះនៅ ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមដែលស្លៀកពាក់សម្លៀកបំពាក់ឈុតខ្មៅបានដើរកាន់ទង់ជាតិ ហើយបានដើរប្រកាសប្រាប់ប្រជាជនដែលរស់នៅបឹងជប៉ុនឱ្យធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញទៅតាមជនបទ។ គោលបំណងដែលកងទ័ពខ្មែរក្រហមបណ្ដេញប្រជាជនចេញពីទីក្រុងភ្នំពេញគឺចង់បោសសម្អាតក្រុមចារកិច្ចដែលពាក់ព័ន្ធជាមួយលោកសេនាប្រមុខ លន់ នល់ និងរៀបចំទីក្រុងភ្នំពេញសារឡើងវិញ។ នៅក្នុងអំឡុងពេលនោះខ្ញុំនិងក្រុមគ្រួសារបានបររទេះគោធ្វើដំណើរចេញពីបឹងជប៉ុនត្រឡប់ទៅស្រុកកំណើតវិញ។ ពេលធ្វើដំណើរ

តាមផ្លូវមកស្រុកកំណើត ខ្ញុំបានប្រទះឃើញសាកសពកងទ័ពជាច្រើនបានដេកស្លាប់នៅតាមផ្លូវជាហូរហែ។ ពេលត្រឡប់មកដល់ស្រុកកំណើត ឪពុកម្តាយខ្ញុំបាននាំគ្នាប្រកបរបរដាំបន្លែដើម្បីចិញ្ចឹមជីវិត។ ពេលខ្ញុំមករស់នៅស្រុកកំណើតបានប្រហែលកន្លះខែ ឪពុកខ្ញុំដែលជាជាងអគ្គិសនី ត្រូវបានហៅឱ្យឡើងទៅតភ្លើងនៅចាក់អង្រែក្រោមវិញ។ ក្រោយពីឪពុកខ្ញុំធ្វើការនៅចាក់អង្រែបានរយៈពេលមួយខែ ឪពុកខ្ញុំបានត្រឡប់មកយកប្រពន្ធនិងកូនៗទៅរស់នៅជាមួយគាត់ដើម្បីឱ្យខ្ញុំបានរៀនសូត្រ។ ពេលខ្ញុំមករស់នៅចាក់អង្រែក្រោម ខ្ញុំត្រូវបានខ្មែរក្រហមបំបែកចេញពីគ្រួសារឱ្យទៅនៅក្នុងមន្ទីរកុមារ ដែលគ្រប់គ្រងដោយឈ្មោះ នី មានស្រុកកំណើតនៅខេត្តកណ្តាល។ ចំណែកបងស្រីខ្ញុំ ត្រូវបានខ្មែរក្រហមបំបែកឱ្យទៅនៅមន្ទីរនារី ហើយប្អូនៗរបស់ខ្ញុំត្រូវបានខ្មែរក្រហមបំបែកឱ្យទៅនៅមន្ទីរកុមារនៅស្ទឹងមានជ័យ។ ពេលខ្ញុំរស់នៅក្នុងមន្ទីរកុមារ ព្រឹកឡើងខ្ញុំត្រូវបានប្រធានមន្ទីរហៅឱ្យទៅរៀនសូត្រ បន្ទាប់ពីចប់ម៉ោងរៀនសូត្រ ខ្ញុំត្រូវបានប្រធានមន្ទីរប្រាប់ឱ្យទៅដេញចាបនៅតាមវាលស្រែឃ្វាលគោ និងឃ្វាលក្របី។ លុះដល់រដូវច្រូតកាត់ ខ្ញុំត្រូវបានប្រធានមន្ទីរបញ្ជូនឱ្យទៅជួយច្រូតស្រូវ និងជញ្ជូនកណ្តាប់ចេញពីក្នុងស្រែ។ សម្រាប់អាហារហូបចុករបស់ខ្ញុំគឺមិនសូវបានគ្រប់គ្រាន់ប៉ុន្មានទេ ថ្ងៃខ្លះហូបបបរ និងថ្ងៃខ្លះទៀតហូបបាយលាយដំឡូង លាយសណ្តែក និងលាយពោតក្រហម។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានប្រធានមន្ទីរជ្រើសរើសឱ្យមកកសិដ្ឋានចិញ្ចឹមជ្រូក ដែលគ្រប់គ្រងដោយឈ្មោះ ចែ។ ពេលខ្ញុំចូលមករស់នៅកសិដ្ឋានចិញ្ចឹមជ្រូកដំបូង ខ្ញុំមានតួនាទីហាន់ដើមចេក លាយជាមួយកន្ទក់ធ្វើជាចំណីជ្រូក និងបោសសម្អាតអាចម៍ជ្រូកនៅក្នុងកសិដ្ឋាន។ ចំណែកឪពុកម្តាយខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើស្រែអំបិលនៅខេត្តកោះកុង។ បន្ទាប់ពីដឹងថាឪពុកម្តាយត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើស្រែអំបិលនៅខេត្តកោះកុង ខ្ញុំគិតតែអង្គុយយំ ព្រោះតែនឹកឪពុកម្តាយខ្លាំងពេក។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានដឹកនាំកម្លាំងសំដៅមកវាយរំដោះនៅទីក្រុងភ្នំពេញ។ ពេលនោះខ្ញុំនិងបងស្រីត្រូវបានដឹកតាមរថយន្តក្រុមអគ្គិសនីមកគោរពទង់ជាតិនៅផ្សារថ្មីរួចបានបន្តដំណើរចេញពីផ្សារថ្មីសំដៅទៅប្រែកឡែម ដែលស្ថិតនៅក្នុងខេត្តបាត់ដំបង។ លុះរថយន្តធ្វើដំណើរដល់ខេត្តកំពង់ស្ពឺក៏អស់សាំង។ ខ្ញុំនិងបងស្រីបានបន្តដំណើរដោយថ្មើរជើងចេញពីខេត្តកំពង់ស្ពឺសំដៅមកកាន់ខេត្តកំពង់ឆ្នាំង ហើយបានបន្តដំណើរចេញពីខេត្តកំពង់ឆ្នាំងទៅកាន់ខេត្តបាត់ដំបងបន្តទៀត។ លុះធ្វើដំណើរមកដល់ស្រែសាម៉ន ខេត្តបាត់ដំបង ខ្ញុំនិងបងស្រីបាននាំគ្នាដើរបូតស្រូវទុកសម្រាប់បុកហូប និងដើររកត្រី។ ពេលបានត្រីមកខ្ញុំប្រឡាក់ទុកសម្រាប់ហូបតាមផ្លូវបន្តដំណើរទៅកាន់ខេត្តបន្ទាយមានជ័យ។ នៅពេលធ្វើដំណើរមកដល់ខេត្តបន្ទាយមានជ័យ ខ្ញុំនិងបងស្រីជួបការលំបាកជាខ្លាំង ដោយសារតែគ្មានអាហារហូបចុកគ្រប់គ្រាន់ ហេតុនេះខ្ញុំនិងបងស្រីបាននាំគ្នាដើរកាប់គល់ចេក គល់ល្ហុង ទំពាំង ដើម្បីស្ងោរហូប ទើបអាចរស់រានមានជីវិតរហូតមកដល់បន្ទាយឡែម ស្ថិតក្នុងដីថៃ។

បន្ទាប់មកអង្គការកាកបាទក្រហមអន្តរជាតិដែលហៅកាត់ថា យូអ៊ិន បានដឹកខ្ញុំនិងប្រជាជនផ្សេងទៀតឱ្យទៅរស់នៅជំរំកាំពុធ។ បន្ទាប់ពីខ្ញុំរស់នៅជំរំកាំពុធបានរយៈពេលមួយខែ អ្នករស់នៅក្នុងជំរំបានឃោសនាស្ងាត់ៗប្រាប់ប្រជាជននៅក្នុងជំរំថា «តើមានអ្នកណាចង់ទៅរស់នៅខេត្តកោះកុងឬទេ ព្រោះទៅនៅទីនោះសប្បាយ និងមានអាហារហូបចុកគ្រប់គ្រាន់»។ បន្ទាប់ពីស្តាប់ការឃោសនារួចមក ខ្ញុំនិងបងស្រីបានចុះឈ្មោះ។ លុះដល់យប់ឡើង ខ្ញុំនិងបងស្រីលួចរត់ចេញពីជំរំ ហើយបានធ្វើដំណើរតាមរថយន្តទាហានដែលមានឃ្លុបបិទជិតឈឹងមកចុះនៅស្រុកសុផាន់ហ៊ិន

ខេត្តត្រាត ប្រទេសថៃ ដែលមានព្រំប្រទល់ជាប់ខេត្តកោះកុង។ បន្ទាប់មកខ្ញុំត្រូវបាន តាវ៉ែន ដែលជាប្រធានកងពលទី២ទៅយក ហើយបាននាំខ្ញុំធ្វើដំណើរចេញពីកោះកុងដោយឆ្លងកាត់ថ្មដា អូរចោទ រហូតមកដល់ផ្ទះ២ខ្នង ដែលជាកន្លែងប្រជាជនរស់នៅ។ ពេលមកដល់ផ្ទះ២ខ្នង ខ្ញុំនិងបងស្រីត្រូវបានតាវ៉ែនបញ្ចូលទៅក្នុងកង៥០ ជាកងសម្រាប់ដឹកជញ្ជូនដែលគ្រប់គ្រងដោយ នារី វឿន។ សម្ភារដែលខ្ញុំត្រូវដឹកជញ្ជូនមានដូចជា ស្បៀងអាហារ គ្រាប់កាំភ្លើងដែលត្រូវដឹកជញ្ជូនចេញពីប្រកច១ មានទីតាំងស្ថិតក្រោមជើងភ្នំ យកទៅ ទុកនៅច២ក្រោម និងច២លើ ដែលមានទីតាំងស្ថិតនៅលើភ្នំ។ ក្នុងមួយថ្ងៃខ្ញុំត្រូវដឹកជញ្ជូនឱ្យបាន២ទៅ៣ជើង។

នៅចុងឆ្នាំ១៩៨៤ និងដើមឆ្នាំ១៩៨៥ កងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រួមជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានដឹកនាំកម្លាំងជាច្រើនមកវាយជាមួយកងទ័ពខ្មែរក្រហមនៅតំបន់ថ្មដា។ លុះធ្វើដំណើរមកដល់តំបន់ថ្មដា កងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រួមជាមួយកងទ័ពវៀតណាម បានសាងសង់ទីបញ្ជាការធំនៅត្រើយខាងកើតស្ទឹងមេទឹក ដែលមានទីតាំងនៅផ្ទះ៧ខ្នង។ ពេលនោះកង៥០ និងកងដឹកជញ្ជូនលេខ៣២ ដែលគ្រប់គ្រងដោយឈ្មោះ វើន បាននាំគ្នាដឹកជញ្ជូនគ្រាប់ជាច្រើនយកទៅឱ្យកងទ័ពដែលឈរជើងចាំទប់ទល់ជាមួយកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមនៅស្ពានមេទឹក។ ក្រោយមកកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រួមជាមួយកងទ័ពវៀតណាម បានបើកប្រតិបត្តិការទ្រង់ទ្រាយធំវាយកាន់កាប់តំបន់ថ្មដា។ ពេលនោះខ្ញុំនិងកងដឹកជញ្ជូនទាំងអស់ បាននាំគ្នាសម្រុកដឹកជញ្ជូនទាំងយប់ទាំងថ្ងៃ ដើម្បីដឹកជញ្ជូនគ្រាប់កាំភ្លើងយកទៅឱ្យកងទ័ពដែលឈរជើងប្រយុទ្ធជាមួយកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម។ ពេលកំពុងតែដើរដឹកជញ្ជូនគ្រាប់ ខ្ញុំបានដើរ ទាក់មីនកន្ត្រាក់ ដែលបង្កប់ដោយកងទ័ពវៀតណាម បណ្តាលឱ្យរងរបួសជើងយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់មក ខ្ញុំត្រូវកងដឹកជញ្ជូនសែងយកទៅសម្រាកព្យាបាលនៅជាំស្វារ ដែលប្រធានពេទ្យឈ្មោះ ង៉ាយ។ បន្ទាប់ពីសម្រាកព្យាបាលអស់ជាច្រើនខែ ខ្ញុំបានជាសះស្បើយ ហើយខ្ញុំត្រូវបានបញ្ជូនឱ្យទៅចូលរួមក្នុងកងដឹកជញ្ជូនវិញ។

នៅឆ្នាំ១៩៨៦បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ កងពលទី២ និងកងពលទី៣ត្រូវបានមេដឹកនាំខ្មែរក្រហមរំលាយ។ ពេលនោះខ្ញុំនិងបងស្រីបាននាំធ្វើដំណើរចេញពីតំបន់ថ្មដា មករស់នៅស្រុកសំឡូត ខេត្តបាត់ដំបង។ ពេលមករស់នៅស្រុកសំឡូត ខ្ញុំបានស្គាល់ជាមួយប្តីខ្ញុំ ហើយខ្ញុំបានរៀបការជាមួយប្តីខ្ញុំដែលជាគ្រូពេទ្យ នៅក្នុងអង្គភាពតាធី។

នៅឆ្នាំ១៩៩៦ កងទ័ពរាជរដ្ឋាភិបាលកម្ពុជា និងកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្មស្រុះស្រួលគ្នា។ បន្ទាប់ពីស្រុះស្រួលគ្នា ខ្ញុំនិងប្តីបានសម្រេចចាកចេញពីស្រុកសំឡូតមករស់ភូមិចំការជ្រៃ ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយប្រកបមុខរបរធ្វើចម្ការ។ នៅឆ្នាំ២០០០ ដោយសារតែភូមិចំការជ្រៃឆ្ងាយពីផ្លូវ ឆ្ងាយពីមន្ទីរពេទ្យនិងឆ្ងាយពីសាលារៀន ប្រជាជនដែលរស់នៅក្នុងភូមិចំការជ្រៃ ត្រូវបានមេឃុំឈ្មោះ ឆន ដឹកនាំឱ្យចូលមករស់នៅក្នុងភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ ដើម្បីឱ្យបាននៅជិតផ្លូវ ជិតមន្ទីរពេទ្យ និងជិតសាលារៀន ងាយស្រួលកូនចៅបានរៀនសូត្រ។ ពេលចូលមករស់នៅភូមិក្រាំងរងៀង ខ្ញុំនិងប្តីនាំគ្នាប្រកបរបរធ្វើចម្ការរហូតមកដល់សព្វថ្ងៃ។ បន្ទាប់ពីស្រុកទេសបានស្រួលបួល ខ្ញុំខំសង្វាហ៍នាំកូននាំចៅចូលទៅលេងសមុទ្រប្រាកានស្ថិតនៅក្នុងប្រទេសថៃ។ ពេលដែលធ្វើដំណើរចូលទៅក្នុងដីថៃ ខ្ញុំបានឃើញប៉ុស្តិ៍ត្រួតពិនិត្យរបស់ថៃបានរំកិលចូលមកក្នុងដីខ្មែរប្រហែល ៧គីឡូម៉ែត្រព្រោះ ដើមឡើយព្រំប្រទល់ថៃគឺនៅជាប់តាមជើងភ្នំ។

# អ៊ី រឿត៖ អតីតទាហានប៉ារ៉ា និងជាកងការពារប្រធានជំរំឫទ្ធិសែន

**ផាច សម្ភស្ស**

ខ្ញុំឈ្មោះ អ៊ី រឿត អាយុ៦២ឆ្នាំ កើតនៅភូមិអន្លង់ទ្រព្យ ឃុំបុស្សក្រាំង ស្រុកមង្គលបុរី ខេត្តបាត់ដំបង។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ខ្ញុំមានឪពុកឈ្មោះ ជូ អ៊ី (ស្លាប់) និងម្តាយឈ្មោះ យ៉ុន រស់នៅស្រុកកំណើត។ ខ្ញុំមានបងប្អូនចំនួន៩ នាក់ គឺស្រី២នាក់ និងប្រុស៧ នាក់។ ខ្ញុំគឺជាកូនទី៣ក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ យៀន មុំ អាយុ៥៦ឆ្នាំ និងមានកូនចំនួន៦នាក់ ក្នុងនោះមានប្រុស៤នាក់ និងស្រី២នាក់។ សព្វថ្ងៃខ្ញុំធ្វើការជាប្រជាការពារភូមិព្រៃចាន់។



អ៊ី រឿត អតីតទាហានប៉ារ៉ា និងជាកងការពារប្រធានជំរំឫទ្ធិសែន សព្វថ្ងៃរស់នៅភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីកុមារភាព ខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ ចាស់។ នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ខ្ញុំមានអាយុ១០ឆ្នាំ ត្រូវខ្មែរក្រហមចាត់តាំងឱ្យចូលក្នុងកងកុមារ ធ្វើការងាររែកដី និងលើកភ្លឺស្រែ។ ពេលនោះ ខ្មែរក្រហមបំបែកខ្ញុំពីឪពុកម្តាយ និងបងប្អូន។ ឪពុកខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហមដោយសារជំងឺគ្រាំក្នុង។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមកដល់ភូមិខ្ញុំ ពេលនោះបងរបស់ខ្ញុំឈ្មោះ យ៉ាន់បាននាំម្តាយ ខ្ញុំ និងបងប្អូនខ្ញុំដើរពីស្រុកមង្គលបុរី មករស់នៅជំរំឫទ្ធិសែន។ ខ្ញុំស្នាក់នៅជិតប្រាសាទស្តុកកក់ធំ។ នៅទីនោះ ទាហានថៃបានជីកប្រឡាយ និងសង់ទំនប់តាមបណ្តោយព្រំដែនពីជំរំឫទ្ធិសែន រហូតទៅដល់ភ្នំដងរែក។ ទំនប់ដែលទាហានថៃសង់នោះ បានបែងចែកទឹកដីកម្ពុជា និងថៃ ដោយស្ថិតនៅខាងកើតទំនប់គឺជាដីខ្មែរ ចំណែកដីដែលស្ថិតនៅខាងលិចទំនប់គឺជាដីថៃ។ ចម្ងាយពីប្រឡាយព្រំដែនមកជំរំឫទ្ធិសែនមានប្រវែង៣គីឡូម៉ែត្រចូលជ្រៅក្នុងដីខ្មែរ។ ពេលនោះមានផ្សារមួយឈ្មោះថា ផ្សារទួលគោកស៊ូង ដែលមានចម្ងាយប្រមាណ៣គីឡូម៉ែត្រពីជំរំឫទ្ធិសែន។ ផ្សារនោះស្ថិតនៅខាងកើតប្រឡាយក្នុងដីខ្មែរ ហើយប្រជាជនថៃតែងតែយកអីវ៉ាន់មកលក់ឱ្យប្រជាជនខ្មែរ។

នៅឆ្នាំ១៩៨២ ខ្ញុំមានអាយុ១៩ឆ្នាំ ខ្ញុំចូលធ្វើទាហានប៉ារ៉ា និងជាកងការពាររបស់អនុប្រធានជំរំបុទ្ធិសែនឈ្មោះ សាញ់ ណេ។ បន្ទាប់ពីខ្ញុំធ្វើជាកងការពារសាញ់ ណេ បានរយៈពេល៣ខែ ប្រធានជំរំបុទ្ធិសែនឈ្មោះ តា លួត ត្រូវបានបាញ់សម្លាប់ពេលគាត់ទៅប្រជុំនៅជំរំបឹងអំពិល។ បន្ទាប់មក សាញ់ ណេ បានឡើងជាប្រធានជំរំបុទ្ធិសែន។ កងការពាររបស់សាញ់ ណេ មានចំនួន៣០នាក់ ត្រូវតាមការពារគាត់ពេលចុះទៅធ្វើការនៅតាមជំរំ និងតាមខ្សែត្រៀមនានា។ ប្រជាជនរស់នៅជំរំបុទ្ធិសែនមានចំនួនរាប់ម៉ឺននាក់ ដែលភៀសខ្លួនមកពីតាមបណ្តាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា។ នៅជំរំបុទ្ធិសែនមានវត្តមួយស្ថិតនៅក្បែរប្រាសាទស្តុកកក់ធំ។ នៅក្នុងវត្តនោះក៏មានព្រះសង្ឃគង់នៅដែរ។ នៅពេលនោះអង្គការសហប្រជាតិ និងអង្គការអន្តរជាតិបានចូលមកជំរំបុទ្ធិសែន និងបានសាងសង់សាលារៀនមន្ទីរពេទ្យ និងចែកស្បៀងដល់ស្ត្រីដែលរស់នៅក្នុងជំរំក្នុងមួយសប្តាហ៍ម្តង។

នៅអំឡុងឆ្នាំ១៩៨៤ និងឆ្នាំ១៩៨៥ កងទ័ពវៀតណាមវាយចូលមកជំរំបុទ្ធិសែន ពេលនោះប្រជាជនរស់នៅក្នុងជំរំ ត្រូវបានជម្លៀសចូលក្នុងប្រទេសថៃ។ ចំណែកខ្ញុំ និងទាហានដទៃទៀតត្រូវបញ្ជូនទៅហ្វឹកហាត់យុទ្ធសាស្ត្រនៅក្នុងប្រទេសថៃរយៈពេល២ខែ ទើបត្រឡប់មកជុំគ្នានៅក្វាងដុងប្រទេសថៃ។ បន្ទាប់មក ខ្ញុំត្រូវផ្លាស់មកនៅក្នុងកងពលរបស់លោក ផ្លួន ហៅ ការ៉េ និងបានបញ្ជូនចូលមកធ្វើប្រតិបត្តិការនៅស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ ស្រុកស្ទឹងត្រង់ និងស្រុកមួយចំនួនទៀតក្នុងខេត្តកំពង់ចាម រយៈពេល៣ឆ្នាំ។

នៅចន្លោះឆ្នាំ១៩៨៨ និងឆ្នាំ១៩៨៩ អង្គភាពរបស់ខ្ញុំត្រូវបញ្ជូនត្រឡប់មកព្រំដែនកម្ពុជា-ថៃវិញ។ ពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពីព្រោះទាហានថៃបានមកឈរជើងនៅប្រាសាទស្តុកកក់ធំ។ ចំណែកបង្គោលឡាក់ព្រំដែនស្ថិតនៅខាងលិចឈៀងខាងជើងប្រាសាទស្តុកកក់ធំ ប្រហែល២គីឡូម៉ែត្រ ត្រូវបានប្តូរទីតាំងមកប៉ែកខាងកើតប្រាសាទស្តុកកក់ធំប្រមាណ២គីឡូម៉ែត្រវិញ។ ទាហានថៃមិនអនុញ្ញាតឱ្យអង្គភាពខ្ញុំទៅឈរជើងនៅក្បែរប្រាសាទស្តុកកក់ធំឡើយ។ អង្គភាពខ្ញុំបានមកឈរជើងនៅតំបន់៥ (បច្ចុប្បន្នភូមិព្រៃចាន់) ជំនួសវិញ រហូតដល់ធ្វើសមាហរណកម្ម ជាមួយកងយោធពលខេមរភូមិន្ទនៅឆ្នាំ១៩៩៣។



ខ្លោងទ្វារវត្តជោគជ័យ ស្ថិតនៅក្នុងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ិន ផុន ៖ អតីតឈរជើងនៅអូរស្ពស្តី

ឡុង ដានី

ខ្ញុំឈ្មោះ អ៊ិន ផុន អាយុ៧៥ឆ្នាំ កើតនៅក្នុងភូមិពន្ធរាំង ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានប្រពន្ធឈ្មោះ គីម លឹម អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិអង្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ ខ្ញុំមានកូន៤នាក់ ក្នុងនោះមានប្រុស៣នាក់ និងស្រីម្នាក់។ ខ្ញុំមានឪពុកឈ្មោះ អ៊ិន ថៅ ស្លាប់នៅឆ្នាំ១៩៩១ និងម្ដាយឈ្មោះ អ៊ុយ វ៉ាត ស្លាប់នៅឆ្នាំ២០០០។ ខ្ញុំមានបងប្អូន១០នាក់ ក្នុងនោះមានប្រុស៥នាក់ និងស្រី៥នាក់។ ខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។

កាលពីកុមារ ខ្ញុំរៀននៅវត្តសម្ដេចពាន់ ស្ថិតនៅក្នុងភូមិក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ចាស់។ ខ្ញុំធ្វើដំណើរដោយថ្មើរជើងដើម្បីទៅរៀនរាល់ថ្ងៃ ដែលពីផ្ទះខ្ញុំទៅវត្តសម្ដេចពាន់មានចម្ងាយ២គីឡូម៉ែត្រ។ ខ្ញុំរៀនមិនទាន់បានប្រឡងបានសញ្ញាបត្រឡើយ ស្រាប់តែនៅឆ្នាំ១៩៧០ មានរដ្ឋប្រហារ ហើយមិត្តភក្ដិខ្ញុំខ្លះផ្លាស់ទៅរៀននៅភ្នំពេញ និងខ្លះទៀតគ្មានលទ្ធភាពបានសម្រេចចិត្តឈប់រៀនរួមទាំងរូបខ្ញុំ។ ក្រោយមកខ្ញុំបាននៅផ្ទះជួយធ្វើស្រែចម្ការឪពុកម្ដាយបានរយៈពេលមួយឆ្នាំ។

នៅឆ្នាំ១៩៧១ ខ្ញុំចូលធ្វើកងទ័ព តាមរយៈការឃោសនាបំផុសគំនិតក្នុងការទាមទារយកសម្ដេចឪមកគ្រប់គ្រងតំណែងវិញ។ ខ្ញុំនៅកងអនុសេនាធំលេខ១២៤ នៅខេត្តតាកែវ។ ខ្ញុំឈរជើងនៅខេត្តតាកែវ និងខេត្តកណ្ដាល។

នៅឆ្នាំ១៩៧២ ខ្ញុំនៅប្រយុទ្ធផ្លាស់នៅសមរភូមិតាក្រហឹម និងទួលក្រសាំង។ នៅឆ្នាំ១៩៧៣ ខ្ញុំបានចូលធ្វើជាគ្រូពេទ្យ និងត្រូវបម្រើការងារនៅក្នុងអង្គភាព



អ៊ិន ផុន អាយុ៧៥ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេទ្យរហូត។ ខ្ញុំបានទៅរៀនសូត្រ និងបណ្ដុះបណ្ដាលពីលោកគ្រូ ជួន ជឿន។ ខ្ញុំរៀនបណ្ដើរ និងអនុវត្តផ្ទាល់បណ្ដើរ។ ក្រុមខ្ញុំមើលថែ និងព្យាបាលអ្នកជំងឺនៅក្នុងកងពលលេខ១១២។

នៅដើមឆ្នាំ១៩៧៤ កងពលលេខ១១២ ត្រូវរៀនហ្វឹកហាត់នៅកោះខែល ស្រុកស្អាង ខេត្តកណ្ដាល។ ខ្ញុំនៅជាមួយតាណាត បងពិន តា ឡាវ និងតាសោម។ កងអនុសេនាធំលេខ១២៤ មានខ្មែរភាគខាងជើងជាអ្នកហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ។ បងណាត គឺជាប្រធានវរសេនាតូចលេខ១១២។

ក្រោយមក បងពិន ឡើងជាប្រធានវរសេនាតូចលេខ ១៦។ វរសេនាតូចលេខ១១៧ មានបងគីម ជាប្រធាន។ លុះពេលក្រោយមកទៀត វរសេនាតូចលេខ១១២, វរសេនាតូចលេខ១១៦ និងវរសេនាតូចលេខ១១៧ ត្រូវបូកបញ្ចូលគ្នាបង្កើតជាវរសេនាធំលេខ២៦៧។ ចំណែកតាគីម ត្រូវដកចេញ និងបញ្ជូនទៅខេត្តរតនគិរី។

នៅឆ្នាំ១៩៧៤ អង្គភាពបានបង្កើតកងពលលេខ១១២ មានវរសេនាធំ៦៨ វរសេនាធំ៦៧ និងវរសេនាធំនាវីជាចំណុះរួមមានកងស៊ើបការណ៍ កាំភ្លើងធំ និងស្បៀង។ កងពលលេខ១១២ មានមុខព្រួញនិងទិសប្រតិបត្តិការចាប់ពីផ្លូវជាតិលេខ១១២, ផ្លូវជាតិ២១ និងមេគង្គក្រោម។ កងពលលេខ១១១ មានបងសាវឿន ហៅ០៥ អ្នកគ្រប់គ្រងមើលការខុសត្រូវ។ កងពលលេខ១១ បង្កើតនៅស្ពានកោះធំ តំណាលកងពលលេខ១១២ដែរ។ ក្នុងឆ្នាំនោះដែរ ខ្ញុំត្រូវទៅប្រចាំនៅទីតាំងទន្លេមេគង្គ ក្ដួមសំណលើ ក្ដួមសំណក្រោម កោះកន្ធាយ កោះពាមរាំង ព្រែកទម្លាប់ និងមានអ្នកខ្លះហែលទឹកទៅវាយនៅស្ពានអ្នកលឿង។ ចំណែកនៅខាងកើតទន្លេមេគង្គ គឺជាបក្សពួកចាន់ ចក្រី។ ខ្ញុំនៅខាងបងណាត។ ប្រធានភូមិភាគឈ្មោះ វន វេត ។ វន វេត និងតាណាត កាន់ឈើច្រត់ទៅបញ្ជូផ្ទាល់នៅទន្លេមេគង្គ ព្រោះពេលនោះខ្ញុំនៅវះកាត់អ្នកជំងឺនៅមន្ទីរពេទ្យ។ វន វេត បានចូលកន្លែងខ្ញុំសួរសុខទុកអ្នកជំងឺ។ កាលនោះខ្មែរក្រហមបាញ់ផ្ដាច់កប៉ាល់ដឹកសាំងនៅកោះពាមរាំង។ កាលនោះមានកងទ័ពខាងធីវគីបានមកឈរជើងនៅកោះចម្រើន។ ខ្ញុំចាំបានថាកោះកន្ធាយមានអ្នកស្លាប់ច្រើនណាស់។ ក្រោយមក លន់ នល់ បានបញ្ជូកងទ័ពវាយយកកោះពាមរាំងមកវិញ។ ខ្ញុំប្រចាំការនៅមន្ទីរពេទ្យផ្នែកវះកាត់។ នៅឆ្នាំ១៩៧៥ ខ្ញុំនៅភ្នំពេញ។ អង្គភាពខ្ញុំប្រចាំការចាប់ពីស្ពានតាខ្មៅ ទៅដល់អគ្គសេនាធិការ (វត្តភ្នំ)។ ខ្ញុំរៀនវះកាត់នៅពេទ្យមុន្នីវង្ស។ ចំណែកតាណាត ឡើងជាសេនាធិការកងទ័ពនៅជិតគុក ដាំ ដេង ។ អង្គភាពខ្ញុំត្រូវដាក់ពង្រាយគ្នាចាប់ពីស្ពានថ្មតាខ្មៅរហូតដល់ព្រែស។ ខ្ញុំធ្លាប់ទៅយកអ្នកជំងឺដល់ព្រែស។

នៅខែមិថុនា ឆ្នាំ១៩៧៥ កងពលលេខ១១២ បានប្ដូរទៅជាកងពលលេខ៧០៣វិញ។ តាណាតនៅបានមួយរយៈ លុះក្រោយមកតាណាតបានចេញទៅអគ្គសេនាធិការ ហើយតាពិនឡើងមកជំនួស។ ចំណែកតាឌី ឡើងមកបន្ត។ តាណាតបានដាច់ចេញពីកងពលលេខ៧០៣។ ខ្ញុំនៅក្នុងអង្គភាពពេទ្យមើលការខុសត្រូវនៅពេទ្យកងពល។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបញ្ជូនទៅមើលការខុសត្រូវនៅវរសេនាធំលេខ៦៨ ខេត្តស្វាយរៀង។ ខ្ញុំនៅខេត្តស្វាយរៀងបានរយៈពេលប្រហែលជាមួយឆ្នាំ។

នៅឆ្នាំ១៩៧៨ តាម៉ុក និងតាវ៉ែន បានបញ្ចូលមួយវរសេនាធំលេខ៦៨ទៅក្នុងកងពល៣៤០។ ចំណែកកងពល៧០៣ នៅដដែល ប៉ុន្តែក្រោយមកវរសេនាធំលេខ៦៨ ត្រូវបញ្ចូលទៅក្នុងកងពល៣៤០។ កងពល៣៤០មានកម្លាំងវរសេនាធំលេខ៦៨ កម្លាំងមកពីនិរតី និងមជ្ឈិម។ កងពល៣៤០ដឹកនាំដោយតាធី។ ខ្ញុំមកនៅឈរជើងនៅអូរស្វស្តី។

នៅឆ្នាំ១៩៨០ ខ្ញុំបានមកដល់ខេត្តកំពង់ឆ្នាំង។ អង្គភាពខ្ញុំនៅសល់ប្រហែលមួយក្រុម១០នាក់ ជាង រួមទាំងអ្នកវះកាត់។ លុះក្រោយមកពេលធ្វើដំណើរឡើងលើភ្នំ ខ្ញុំគ្មានអាហារសម្រាប់បរិភោគឡើយ។ ពេលធ្វើដំណើរតាមផ្លូវក្រុមខ្ញុំឃើញសត្វស្វាកំពុងបេះផ្លែឈើស៊ី ក៏គិតថាផ្លែឈើនេះប្រហែលជាមិនពុលទេ។ ក្រោយពេលក្រុមពេទ្យបេះផ្លែឈើនោះហូប ស្រាប់តែបែកពពុះមាត់ស្លាប់ភ្លាមៗ ទោះបីខ្ញុំព្យាយាមចាក់ថ្នាំបន្សាបយ៉ាងណាក៏មិនជាដែរ។ ជាសំណាងដែលខ្ញុំមិនបានហូប។ តាធី និង ពូសេ បានមកព្រំដែនកម្ពុជា-ថៃ។ ចំណែកតាឌីនៅភ្នំដំរាយជាមួយក្រុមខ្ញុំ។ ខ្ញុំនៅកំពង់ឆ្នាំងរយៈពេល១ឆ្នាំ ក្នុងកងពល៣៤០។ ក្រោយមកកងពល៣៤០ ដឹកនាំដោយតាធី និងតាឌី។

នៅឆ្នាំ១៩៨១ ខ្ញុំចេញមកព្រំដែនជាមួយសមាជិកនៅអង្គភាពពេទ្យប្រមាណជា៥០ទៅ៦០នាក់។ ខ្ញុំមកដល់ដំបូងនៅមូលដ្ឋានពេទ្យចំការស្រូវ ចំណែកវាលក្ដួចគឺជាកន្លែងមូលដ្ឋានទ័ពមានមេបញ្ជាការ

ឈ្មោះ តាឌួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាវ៉ែន។ លុះក្រោយមកខ្ញុំមកនៅតំបន់ថ្មដា។ នៅឆ្ងាយពីកន្លែងតាវ៉ែនបន្តិចហៅថាច១។ តាង៉ែយគឺជាប្រធានពេទ្យនៅក្បាលដំរី។ នៅពេទ្យចំការស្រូវមានពេទ្យពីរ គឺ ពេទ្យរបស់រដ្ឋហៅពេទ្យច២ និងពេទ្យរបស់កងពល។ លុះក្រោយមក ខ្ញុំឈប់ធ្វើជាគ្រូពេទ្យហើយមកធ្វើជាកងទ័ពវិញ។ ខ្ញុំបានចូលសមរភូមិតាមបណ្ដោយស្ទឹងមេទឹក, ផ្កាត្រកួន, ហាន់ត្រឡោក និង ពាក់ស្បែក។ កាលនោះខ្ញុំមានតួនាទីជាប្រធានអនុសេនាតូច។ ខ្ញុំភាគច្រើននៅតាមដងស្ទឹងមេទឹក។ ខ្ញុំនៅបានរយៈពេល៦ខែ។

នៅឆ្នាំ១៩៨២ ខ្ញុំចេញទៅកំពង់ឆ្នាំង។ ខ្ញុំនៅក្នុងអង្គភាព៣៨០ដដែល។ ក្រុមខ្ញុំបូកជាមួយក្រុមអ៊ឹមយឹមប្រចាំការនៅស្រុកបរិបូណ៌ ស្រុករលាប្អៀរ និងស្រុកកំពង់ត្រឡាច។ ខ្ញុំត្រូវនៅអង្គភាពពេទ្យនៅលើភ្នំក្បាលទឹកចាំព្យាបាលអ្នករបួស។ តាយឹមគឺជាពេទ្យអង្គភាពភូមិភាគ។

នៅឆ្នាំ១៩៨៥ ខ្ញុំរៀបការនៅលើភ្នំជីរាយខេត្តកំពង់ឆ្នាំង។ ពេលរៀបការរួចប្រពន្ធខ្ញុំមកនៅវរ៣ ចំណែកខ្ញុំរយៈពេល៣ទៅ៤ឆ្នាំទើបមកលេងប្រពន្ធម្ដង។ ខ្ញុំកម្របានមកជួបប្រពន្ធណាស់ ព្រោះខ្ញុំមិនសូវពូកែហែលទឹក។

នៅឆ្នាំ១៩៩៦ កងពល កែវ ពង្ស បានចូលសមាហរណកម្ម រួចហើយចាប់ផ្ដើមធ្វើសកម្មភាពអូសទាញខ្មែរក្រហម។ សមាហរណកម្មលើកទី១ ខ្ញុំមកនៅចំការជ្រៃ។ ខ្ញុំបានឡើងទៅខៅភ្លួជាមួយតាមុត។ លុះក្រោយមក អៀង ផាន ចាត់តាំងឱ្យតាឪ ទៅខេត្តកំពង់ឆ្នាំង។ ចំណែកតាយ៉ង់ទៅចូលរួមជាមួយរាជរដ្ឋាភិបាល។ ក្រុមខ្ញុំខឹងតាឪខ្លាំងណាស់។ តាយ៉ង់ ផ្ញើមីមកនិងចង់ជួបកងទ័ព ដើម្បីអូសទាញកងទ័ពឱ្យដើរស្របគាត់។ តាយ៉ង់ ផ្ញើអីវ៉ាន់តាមរយៈអ្នកកាប់ឈើយកមកឱ្យកងទ័ព។ សមាហរណកម្មលើកទី២ ខ្ញុំមកនៅចំការជ្រៃ។

នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលបានចូលមកធ្វើផ្លូវ ចំណែកប្រជាជនក៏ចែកដីគ្នាធ្វើផ្ទះតាមថ្នល់។ ខ្ញុំបន្តធ្វើពេទ្យទាហាននៅកងពលលេខ៧១។ បន្ទាប់មកកងពលលេខ៧១ បានរំលាយ ហើយឈ្មោះខ្ញុំត្រូវបានបញ្ចូលទៅកងពលលេខ១៤។ កងពលលេខ៧១ មានប្រធានឈ្មោះបងប៉ា និងតាពៅ។ កងពល៧១ រំសាយឈ្មោះខ្លះបញ្ជូនទៅព្រំដែន ខ្លះទៅខេត្តបាត់ដំបង ក្រុមខ្ញុំទៅកងពល១៤និងខ្លះមកធ្វើកងទ័ពសឹករងប្រចាំនៅស្រុកវាលវែង។ ចំណែកខ្ញុំមកប្រចាំការនៅកងពលអន្តរាគមន៍លេខ១៤ នៅបាតខ្លះ។ នៅឆ្នាំ២០១៥ ខ្ញុំចូលនិវត្តន៍។

ខ្ញុំផ្ទាល់គិតថា ទីតាំងទឹកដីកម្ពុជាដែលថៃទាមទារគឺជាទឹកដីខ្មែរយើង។ ខ្ញុំសម្គាល់លើភ័ស្តុតាងតាំងពីសង្គ្រាមមក គឺប្រជាជនខ្មែរនិងវីរកងទ័ពកម្ពុជាបានរស់នៅលើទឹកដីនេះយូរណាស់មកហើយ។ ក្នុងជំនាន់ខ្មែរក្រហម គឺមានកងទ័ពខ្មែរក្រហមឈរជើង។ ក្រោយមកកងទ័ពរាជរដ្ឋាភិបាលបានទៅឈរជើងបន្តទៀត។ ខ្ញុំមិនដែលឃើញទាហានថៃចេញមកតវ៉ាទេ។

នៅឆ្នាំ២០២៣ ខ្ញុំទៅលេងប្រទេសថៃ។ ខ្ញុំចាប់អារម្មណ៍ថាប៉ុស្តិ៍ត្រួតពិនិត្យថៃ និងប៉ុស្តិ៍ត្រួតពិនិត្យខ្មែរនៅជាប់គ្នា។ ខ្ញុំគិតក្នុងចិត្តថា ថ្ងៃណាមួយថៃអាចរំកិលព្រំដែនទៀត។

អំឡុងខែកក្កដា ឆ្នាំ២០២៥ ខ្ញុំពិតជាមានការព្រួយបារម្ភជាខ្លាំង ព្រោះមានការផ្ទុះអាវុធខ្លាំង។ ខ្ញុំចេះតែព្រួយបារម្ភពីកូនចៅ និងទឹកដី។ ជាពិសេសកូនចៅបងប្អូននៅព្រំដែនដែលលំបាកវេទនា។ ចំពោះខ្ញុំផ្ទាល់គឺខ្លាចតែយន្តហោះទម្លាក់គ្រាប់របស់ទាហានថៃ។ បើតាមបទពិសោធន៍ខ្ញុំធ្លាប់ជាអតីតកងទ័ពខ្មែរក្រហមឈរជើងនៅថ្មដា ខ្ញុំគិតថាទាហានថៃគឺឈ្លានពានទឹកដីខ្មែរ។ ក្រោយពេលខ្ញុំឃើញទាហានថៃធ្វើបែបនេះ ខ្ញុំពិតជាមានអារម្មណ៍អន់ចិត្តខ្លាំងណាស់ ព្រោះខ្ញុំធ្លាប់ចូលរួមការពារទឹកដីកម្ពុជា។ ខ្ញុំពិតជាសោកស្ដាយ និងមានការអាណិតអាសូរដល់ជនរងគ្រោះជាខ្លាំង។ ទោះបីជាខ្ញុំមានអាយុច្រើនក្ដី បើសិនជាជាតិត្រូវការខ្ញុំក៏ ខ្ញុំមិនព្រមនៅស្ងៀមដែរ។ លុះត្រាតែខ្ញុំវ៉ារលែងរួច បើខ្ញុំអាចទៅរួច ខ្ញុំនិងជួយឱ្យអស់ពីសមត្ថភាព។ ចំពោះខ្ញុំគឺយល់ស្របតាមរាជរដ្ឋាភិបាល ជ្រើសរើសការដោះស្រាយតាមរយៈការទូត។

# ស៊ុម សុផល ៖ អតីតកងទ័ពនៃកងពលលេខ៤ នៃរបបសាធារណរដ្ឋប្រជាមានិត

## កម្ពុជាធ្លាប់វាយកាន់កាប់ជំរំណាងចាស់ និងជំរំឫទ្ធិសែន

**ធី គឹមហុង**

ខ្ញុំឈ្មោះ ស៊ុម សុផល អាយុ៦៥ឆ្នាំ កើតនៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ។ ខ្ញុំរៀបការនៅឆ្នាំ១៩៨៧ ជាមួយប្រពន្ធឈ្មោះ សឹង ចាន់ អាយុ៥៨ឆ្នាំ និងមានកូនស្រីចំនួន២នាក់។ សព្វថ្ងៃខ្ញុំប្រកបអាជីវកម្មលក់ទឹកសុទ្ធ។



ស៊ុម សុផល អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេងខ្ញុំរៀនត្រឹមថ្នាក់ទី៧ចាស់ នៅសាលាបឋមសិក្សាភ្នំដូនពេញ។ ខ្ញុំមានឪពុកឈ្មោះ ស៊ុម សយ (ស្លាប់) និងម្ដាយឈ្មោះ ហេង សុឃីម (ស្លាប់)។ ខ្ញុំមានបងប្អូនចំនួន៥នាក់គឺស្រី២នាក់ និងប្រុស៣នាក់។ ខ្ញុំគឺជាកូនទី២ក្នុងគ្រួសារ។ នៅឆ្នាំ១៩៧៦ ឪពុកម្ដាយ និងបងប្អូនខ្ញុំទាំងអស់ត្រូវបានខ្មែរក្រហមសម្លាប់ ដោយសារអង្គការដឹងថា ឪពុកខ្ញុំ ធ្លាប់ធ្វើជានាយទាហានលន់ នល់។ នៅក្នុងរបបសាធារណរដ្ឋខ្មែរឪពុកខ្ញុំបម្រើការងារជានាយទាហាន និងបាននាំគ្រួសារខ្ញុំមករស់នៅទីក្រុងភ្នំពេញជុំគ្នា។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅស្រុកព្រែកប្រាស ខេត្តតាកែវ។ បន្ទាប់មកខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំ និងប្រជាជនថ្មីជាច្រើនទៅខេត្តបាត់ដំបង។ មធ្យោបាយធ្វើដំណើរគឺជិះរថភ្លើង។ ប្រជាជនទាំងអស់អង្គុយជាជួរៗទល់មុខគ្នា។ គ្រួសារខ្ញុំបានចេញដំណើរពីស្ថានីយរថភ្លើងខេត្តតាកែវមកឈប់នៅស្វាយស៊ីសុផុនខេត្តបាត់ដំបង។ នៅខណៈពេលកំពុងធ្វើដំណើររយៈពេល៣យប់៤ថ្ងៃ ក្នុងរថភ្លើងខ្មែរក្រហមបានចែកនំប៉័ងធំៗ ឱ្យម្នាក់មួយដើមសម្រាប់បរិភោគតាមផ្លូវ។ នៅពេលមកដល់ស្ថានីយរថភ្លើងស្វាយស៊ីសុផុន ខ្មែរក្រហម

បានបែងចែកប្រជាជនតាមផែនការ និងទិសដៅផ្សេងៗគ្នា។ គ្រានោះ ក្រុមគ្រួសារខ្ញុំនិងប្រជាជនមួយចំនួនត្រូវបានខ្មែរក្រហមឱ្យធ្វើដំណើរតាមត្រាក់ទ័រទៅស្រុកព្រះនេត្រព្រះ។ គ្រួសារខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនមកភូមិព្រះនេត្រព្រះ ដោយស្នាក់នៅក្នុងវត្តព្រះនេត្រព្រះបានមួយរយៈ ទើបខ្មែរក្រហមបញ្ជូនគ្រួសារខ្ញុំតាមទូកបន្តទៅភូមិស្រះកើត និងចាត់ឱ្យស្នាក់នៅផ្ទះជាមួយអ្នកភូមិម្នាក់ឈ្មោះ មីង ឈិត។

នៅចុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៨ឆ្នាំ ត្រូវបានអង្គការបញ្ចូលក្នុងកងចល័ត និងចាត់តាំងឱ្យទៅលើកទំនប់អូររន្ទះបាញ់។ ប្រធានកងចល័តឈ្មោះតាវ៉ាល់។ បន្ទាប់មក កងចល័តរបស់ខ្ញុំត្រូវបន្តទៅលើកទំនប់អាងត្រពាំងថ្ម។ នៅពេលនោះ ខ្មែរក្រហមបានបែកចបឱ្យយុវជនកងចល័តជ្រើសរើសម្នាក់មួយសម្រាប់កាប់ដីលើកទំនប់ប្រឡាយម្នាក់៣ម៉ែត្រគុបក្នុងមួយថ្ងៃ។ នៅពេលកាប់ដីលើកទំនប់នៅអាងត្រពាំងថ្ម ប្រធានសហករណ៍ណាំតាវ បាននាំខ្ញុំទៅជួបឪពុកម្តាយខ្ញុំតែម្តងគត់។ ក្រោយមក មីង ឈិត ដែលជាម្ចាស់ផ្ទះដែលគ្រួសារខ្ញុំធ្លាប់ស្នាក់នៅជាមួយ មកប្រាប់ថាឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំទាំងអស់ត្រូវបានឈ្លបខ្មែរក្រហមយកទៅសម្លាប់ ព្រោះស៊ើបដឹងថាឪពុកខ្ញុំជាអតីតនាយទាហាន លន់ នល់។

នៅចុងឆ្នាំ១៩៧៧ មិត្តនារីម្នាក់ដែលនៅកងចល័តជាមួយគ្នា បានរាយការណ៍ទៅអង្គការ ថាឪពុកខ្ញុំគឺជាទាហាន លន់ នល់។ បន្ទាប់មក មិត្តណាក់ មកចាប់ចងខ្ញុំបម្រុងយកទៅវាយចោល ប៉ុន្តែសំណាងល្អប្រធានកងចល័តឈ្មោះរ៉ាក់ដែលស្រឡាញ់រាប់អានខ្ញុំ និងធ្លាប់រស់នៅស្រុកកំណើតជាមួយខ្ញុំបានបញ្ជាឱ្យមិត្តណាក់ ដោះលែងខ្ញុំវិញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវរស់នៅកំព្រាតែម្នាក់ឯង។ នៅខែឧសភា ឆ្នាំ១៩៧៩ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ពនៅក្នុងអង្គភាពកងទ័ពវៀតណាមនៅស្រុកព្រះនេត្រព្រះ។ ពីរខែក្រោយមក កងទ័ពវៀតណាមបានផ្លាស់ខ្ញុំមកស្រុកស្វាយស៊ីសុផុន។ ខ្ញុំបានមកជាមួយអង្គភាពកងទ័ពវៀតណាមបម្រើការងារផ្នែកចុងភៅ។

នៅឆ្នាំ១៩៨០ ខ្ញុំត្រូវបានបញ្ជូនទៅស្រុកចំការលើ ខេត្តកំពង់ចាម ដើម្បីចូលបម្រើកងទ័ពនៅក្នុងកងពលលេខ៤ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ កងពលលេខ៤ មានពាកងវរសេនាធំជាចំណុះ គឺកងវរសេនាធំលេខ៩ កងវរសេនាធំលេខ១០ និងកងវរសេនាធំលេខ១១។ ប្រធានកងពលលេខ៤មានឈ្មោះ នាង សាបុន។ ខ្ញុំស្ថិតនៅក្នុងកងអនុសេនាធំដឹកជញ្ជូនចំណុះឱ្យកងវរសេនាធំលេខ១០។ ប្រធានកងដឹកជញ្ជូនមានឈ្មោះ ឈុន អ៊ុន និង អនុប្រធានវរសេនាធំលេខ១០ មានឈ្មោះមាស សំបិន។

ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨២ កងពលលេខ៤ត្រូវបានផ្លាស់មកឈរជើងនៅសាលាវិស័យ ក្នុងខេត្តកំពង់ធំ ដើម្បីវាយប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមនៅតំបន់នោះ។ នៅដើមឆ្នាំ១៩៨៣ កងពលលេខ៤បានផ្លាស់មកឈរជើងនៅស្រុកពួក ខេត្តសៀមរាប ដើម្បីវាយរុញច្រានកងទ័ពខ្មែរក្រហម ដឹកនាំដោយតាម៉ុក ដែលធ្វើប្រតិបត្តិការនៅដូនស៊ា និងចារឈូកក្នុងភូមិសាស្ត្រស្រុកពួក ខេត្តសៀមរាប។ នៅចុងឆ្នាំ១៩៨៣ កងពលលេខ៤ បានផ្លាស់មកឈរជើងនៅស្វាយស៊ីសុផុន ដោយបញ្ជាការដ្ឋានកងពលលេខ៤ស្ថិតនៅលើភ្នំស្វាយ។ ពេលនោះថ្នាក់ដឹកនាំកងពលលេខ៤រួមមាន៖ ទឹម ជាសាខឿន, ជា ម៉ន, ងិន សំអាន និង ស សារឿន។ ចំណែក កងវរសេនាធំលេខ១០ ឈរជើងនៅភូមិយាងថ្មី ដែលមានថ្នាក់នាំឈ្មោះ ពែក សារ៉ាន, ប៉ែន ពុធ និង មាស សំបិន។ នៅខណៈពេលនោះអង្គភាពកងទ័ពវៀតណាមបានឈរជើងនៅកូនដំរី គឺចាប់ពីនិមិត្តរហូតដល់ប៉ោយប៉ែត។ កងពលលេខ៤ និងកងទ័ពវៀតណាម

បានប្រយុទ្ធនៅសមរភូមិស៊ីសុផុនខាងជើងជាមួយទាហានប៉ារ៉ារបស់ ឡៃ វីរៈ ប្រចាំនៅជំរំណងចាន់ៗ ចំណែកសមរភូមិស៊ីសុផុនខាងត្បូងកងពលលេខ៤ និងកងទ័ពវៀតណាមបានប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមកងពលលេខ៤៥០របស់ សុក ភាព ប្រចាំនៅតំបន់ម៉ក់ហ៊ឺន ភ្នំដាប់ និងភ្នំមៃឡូ។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៨៥ កងពលលេខ៤ សហការជាមួយកងទ័ពវៀតណាមបើកយុទ្ធនាការបោសសម្អាតទាហានប៉ារ៉ានៅតាមជំរំចាស់ ជំរំថ្មី និងជំរំណងចាន់ ដែលស្ថិតនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ចន្លោះបង្គោលឡាក់លេខ៤២ ដល់៤៧។ កងអនុសេនាតូចដឹកជញ្ជូនរបស់ខ្ញុំត្រូវបានបញ្ចូលជាមួយកងវរសេនាតូចលេខ១៦បានចុះទៅភូមិយាងដង្កំ និងចូលទៅព្រៃបឹងខ្នោ ដែលមានចម្ងាយប្រមាណពី២គីឡូម៉ែត្រពីជំរំចាស់(ជំរំណងម៉ាកមុន) ដែលមានអូរមួយ ប្រវែងប្រហែលមួយគីឡូម៉ែត្រ។ នៅមុខជំរំចាស់ក្បែរអូរមានបង្គោលឡាក់ព្រំដែនលេខ៤៣។

បន្ទាប់ពីត្រៀមរយៈពេលមួយសប្ដាហ៍នៅបឹងខ្នោរ ទើបកងវរសេនាតូចលេខ១៦ នៃកងវរសេនាធំលេខ១០ កងវរសេនាតូច៣៤ កងវរសេនាតូច៤៨ និងអង្គភាពផ្សេងទៀតនៃកងវរសេនាធំលេខ៩ ចំណុះកងពលលេខ៤បានបើកប្រតិបត្តិការវាយកាន់កាប់ជំរំចាស់ និងជំរំថ្មី (ជំរំឫទ្ធិសែនដែលមានប្រាសាទស្តុកកក់ធំ) ទាំងស្រុង។ បន្ទាប់ពីកងវរសេនាតូចលេខ១៦កាន់កាប់ជំរំចាស់ កងវរសេនាតូចលេខ៣៤ និង៤៨កាន់កាប់នៅជំរំថ្មីបានរយៈពេលប្រហែលមួយសប្ដាហ៍ ទើបកងវរសេនាតូចលេខ៣២ និងអង្គភាពផ្សេងទៀតនៃកងពលលេខ៤ និងកងទ័ពវៀតណាមវាយដណ្ដើមយកជំរំណងចាន់បន្ថែមទៀត។

បន្ទាប់ពីកងពលលេខ៤ និងកងទ័ពវៀតណាមកាន់កាប់ជំរំណងចាន់ ជំរំចាស់ និងជំរំថ្មីបានទាំងស្រុង អង្គភាពកងវរសេនាតូចលេខ១៦របស់ខ្ញុំ កងវរសេនាតូចលេខ៣៤ កងវរសេនាតូចលេខ៤៨ ចំណុះកងពលធំលេខ៤ និងកងទ័ពវៀតណាមបានល្បាតនៅតាមបណ្ដោយ ទំនប់ព្រំដែនកម្ពុជា- ថៃ ក្នុងទឹកដីកម្ពុជា។ ចំណែកទីតាំងជំរំទាំង៣ខាងលើស្ថិតនៅជ្រៅក្នុងទឹកដីខ្មែរទាំងអស់។ នៅពេលនោះខ្ញុំធ្លាប់បានទៅផ្ទុតទឹកអណ្ដូងនៅក្នុងកសិណប្រាសាទសេរី (ប្រាសាទស្តុកកក់ធំ) ដែលស្ថិតនៅក្នុងជំរំឫទ្ធិសែន។ ខ្ញុំ និងកងទ័ពដទៃទៀតក៏ធ្លាប់ទៅសែងទឹកពីអណ្ដូងប្រាសាទសេរីយកមកប្រើប្រាស់នៅជំរំចាស់ ពីព្រោះនៅជំរំចាស់មិនមានប្រភពទឹកប្រើប្រាស់ឡើយ។ ក្រោយមកកងពលធំលេខ៤ ត្រូវបានប្ដូរឈ្មោះជាកងពលធំ១៧៩វិញ។ នៅខែសីហា ឆ្នាំ១៩៨៥ ខ្ញុំ និងកងទ័ពអង្គភាពដឹកជញ្ជូនប្រមាណ១០នាក់ទៀតបានដកត្រឡប់មកនៅអង្គភាពដឹកជញ្ជូនចំណុះកងវរសេនាធំលេខ១០វិញ។

នៅចុងឆ្នាំ១៩៨៦ ឬឆ្នាំ១៩៨៧ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបញ្ជូនពលករមកពីខេត្តស្វាយរៀងកាប់ឆ្ការព្រៃតាមបណ្ដោយព្រំដែនពីប៉ោយប៉ែតរហូតដល់ទីតាំងជំរំថ្មី (តំបន់ព្រៃចាន់) ដើម្បីសាងសង់របងយុទ្ធសាស្ត្រ និងទំនប់ការពារព្រំដែន (ទំនប់ក-៥)។ កងទ័ពវៀតណាម និងកងទ័ពនៃកងពល១៧៩ បានដឹកបង្គោលរបងស៊ីម៉ង់ និងលួសបន្លាមកដាំធ្វើរបងយុទ្ធសាស្ត្រតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ដាក់មីន និងវាយចម្រូងដែកជាច្រើនជាន់។

នៅឆ្នាំ១៩៨៧ ថ្នាក់ដឹកនាំបានបញ្ជូនកងទ័ពនៃកងពលធំ១៧៩ ទាំងអស់វាយខ្មែរក្រហមនៅស្រុកស្វាយលើ ខេត្តសៀមរាប។ នៅចុងឆ្នាំ១៩៨៧ អង្គភាពខ្ញុំបានត្រឡប់មកនៅស្វាយស៊ីសុផុនវិញ។ បន្ទាប់មកថ្នាក់លើបានផ្លាស់ខ្ញុំមកនៅក្នុងកងវរសេនាតូចលេខ៣៦ និងឈរជើងនៅសីធ្លូចផ្កា។ ថ្នាក់ដឹកនាំកងវរសេនាតូចលេខ៣៦ រួមមាន៖ ម៉ុកដន, ធុន សឿន និង ពេជ្រ ស៊ីថា។ ក្រោយមកអង្គភាព

កងវរសេនាតូចលេខ៣៦ បានផ្លាស់មកឈរជើងនៅតំបន់ប៉ោយប៉ែត។ ពេលនោះខ្ញុំមានតួនាទីជាប្រធានអនុសេនាធំលេខ៤ ចំណុះកងវរសេនាតូចលេខ៣៦ ឈរជើងនៅចំណុចអតីតជំរំណងចាន់ ដែលមានវត្តមួយនៅទីនោះ។ បន្ទាប់មកអង្គភាពអនុសេនាធំលេខ៤ របស់ខ្ញុំបានផ្លាស់មកឈរជើងនៅក្បាលទំនប់ក៥នៃតំបន់ប៉ោយប៉ែត។

នៅថ្ងៃមួយក្នុងឆ្នាំ១៩៨៨ ទាហានថៃបានយកគ្រឿងចក្រមកឈូសឆាយចម្ការស្វាយក្នុងទឹកដីកម្ពុជា និងត្រូវអង្គភាពរបស់ខ្ញុំបាញ់ឱ្យឆេះ និងស្លាប់អ្នកបើកបរគ្រឿងចក្រជនជាតិថៃចំនួន២នាក់។ បន្ទាប់មកទាហានថៃបានដឹកនាំកងកម្លាំងចូលមកប្រយុទ្ធជាមួយកងកម្លាំងរបស់ខ្ញុំរយៈពេលប្រហែល២ម៉ោងទើបដកថយត្រឡប់ចូលទៅប្រទេសថៃវិញ។

នៅឆ្នាំ១៩៨៩ ខ្ញុំត្រូវបានផ្លាក់លើផ្លាស់មកនៅកងវរសេនាតូចពិសេស យោធភូមិភាគទី៤ ឈរជើងនៅតំបន់ប៉ោយប៉ែត។ ពេលនោះខ្ញុំមានតួនាទីជាអនុប្រធានយោធាកងវរសេនាតូចពិសេស។

នៅឆ្នាំ១៩៩១ យន្តហោះស៊ើបការណ៍របស់ទាហានថៃមួយគ្រឿងបានហោះចូលមកក្នុងទឹកដីកម្ពុជា និងត្រូវកម្លាំងខ្ញុំបាញ់ធ្លាក់នៅតំបន់និមិត្ត។ ខ្ញុំបានបញ្ជាឱ្យកម្លាំងខ្ញុំចាប់អ្នកបើកយន្តហោះទាំងរស់បញ្ជូនទៅទីបញ្ជាការដ្ឋានយោធភូមិភាគទី៤ នៅខេត្តសៀមរាប។ បន្ទាប់មកខ្ញុំបានបញ្ជាកម្លាំងឱ្យរុញយន្តហោះថៃនោះឡើងលើថ្នល់។ ប៉ុន្មានថ្ងៃក្រោយមក ទាហានថៃទាក់ទងមកភាគីកម្ពុជាសុំយកអ្នកបើកបរ និងយន្តហោះនោះត្រឡប់ទៅប្រទេសថៃវិញ។



ស៊ុម សុផល អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្អូនស្រីបីនាក់ត្រូវបានរថក្រោះបើកកិនស្លាប់

**មឿន ស្រីណុច**



ប៊ុន គីមអេង អាយុ៦៩ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិទួលកកោះ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គីមអេង កើតក្នុងគ្រួសារមានឪពុកម្តាយ និងបងប្អូនជាច្រើនរស់នៅជួបជុំគ្នា ដោយសុខសុភមង្គលពេញបរិបូរណ៍ ថែមទាំងមានជីវភាពធូរធារតាំងពីឆ្នាំ១៩៥៥។ ចូលដល់របបខ្មែរក្រហម គ្រួសាររបស់ គីមអេង ត្រូវរស់នៅព្រាត់ប្រាសគ្នា និងប្អូនៗចំនួន៣នាក់ បានស្លាប់ក្នុងពេលប្រទេសកើតមានសង្គ្រាម។

ប៊ុន គីមអេង អាយុ៦៩ឆ្នាំ កើតនៅភូមិអន្លង់ក្រូច ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បច្ចុប្បន្នគីមអេងរស់នៅក្នុងភូមិទួលកកោះ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងមានមុខរបរធ្វើចម្ការ។ គីមអេងមានឪពុកឈ្មោះ ប៊ុន (ស្លាប់) និងម្តាយឈ្មោះ វេនអន់ (ស្លាប់)។ គីមអេង មានបងប្អូនបង្កើតចំនួន៧នាក់ ហើយសព្វថ្ងៃនៅរស់រានមានជីវិតតែពីរនាក់តែប៉ុណ្ណោះ។ គីមអេង គឺជាកូនទី៣ក្នុងគ្រួសារ។ គីមអេងមានប្តីឈ្មោះ ខៀវ ហ៊ឹម អាយុ៧១ឆ្នាំ។ ក្រោយរៀបការគីមអេងមានកូនស្រីចំនួន៤នាក់។

នៅចន្លោះឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៩ ស្ថានភាពរស់នៅរបស់ប្រជាជនខ្មែរ និងជនជាតិភាគតិចព័រ មានភាពសុខសាន្ត និងសម្បូរសប្បាយ។ គីមអេង បានរៀបរាប់ថា **«ជនជាតិភាគតិចព័រ មានប្រពៃណី និងទំនៀមទម្លាប់ស្រដៀងគ្នានឹងជនជាតិខ្មែរ ទាំងរៀងព្រេងនិទាន ពិធីបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ល្បែងប្រជាប្រិយ និងពិធីផ្សេងៗទៀត។ ដោយឡែកមានកម្មពិធីមួយចំនួនខុសពីជនជាតិខ្មែរដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ គឺមានភ្លេងប្រពៃណីបុរាណរបស់ជនជាតិភាគតិចព័រ មានស្គរដៃ ការប្រគំបទភ្លេងអ្នកចម្រៀងច្រៀងរាំខុសពីភ្លេងមង្គលការបច្ចុប្បន្ននេះ។ ពិធីកាត់ខាន់ស្លា រៀបមនុស្សមួយវង់មានកូនកំលោះ កូនក្រមុំ និងសាច់ញាតិ ហើយប្រគំភ្លេងប្រពៃណី។ ភ្ញៀវចូលរួមហូបអាហារដោយក្រាលកន្ទេលនៅលើដី។ ពិធីរៀបការមានរយៈពេលមួយយប់មួយថ្ងៃ។ សម្លៀកបំពាក់កូនក្រមុំកូនកំលោះគឺស្លៀកពាក់ចងក្បិន សំពត់ និងកូនក្រមុំតុបតែងលម្អខ្លួនដោយគ្រឿងប្រដាប់ចាស់ៗបុរាណរបស់ជនជាតិព័រ»**។

គឹម អេង បានបន្ថែមទៀតថា ***«ជនជាតិព័រមានជំនឿលើការគោរពបូជាអ្នកតាម្ចាស់ស្រុកៗ អ្នកភូមិបានរៀបចំពិធីឡើងម្ចាស់ស្រុកក្នុងមួយឆ្នាំម្តង គឺក្នុងខែផល្គុន និងកំណត់យកថ្ងៃអង្គារឬថ្ងៃសៅរ៍ ដើម្បីរំឭកដល់អ្នកតាម្ចាស់ស្រុកឱ្យតាមជួយថែរក្សាការពារ សុំសេចក្តីសុខ សុខភាពល្អ ជៀសឆ្ងាយពីជំងឺកាចសាហាវទាំងក្នុងសមាជិកគ្រួសារ និងសហគមន៍ជនជាតិភាគតិចព័រទាំងអស់»***។ សម្រាប់មុខរបរជនជាតិភាគតិចព័រគឺ រកខ្ទឹម បេះផ្លែក្រវាញ និងធ្វើស្រែចម្ការប្រវាស់ដៃគ្នាជាមួយអ្នកភូមិទៅវិញទៅមក ហើយមិនមានការស៊ីឈ្នួលគ្នានោះទេ។ អ្នកភូមិស្វែងរកអាហារត្រី សាច់ រួចចែករំលែកឱ្យគ្នាទៅវិញទៅមកដោយគ្មានការលក់ដូរ។ ការរស់នៅជាសហករណ៍ មានប្រធានសហករណ៍ឈ្មោះ ស៊ីម ជនជាតិខ្មែរ ជាអ្នកភូមិកំពែង ស្រុកភ្នំក្រវាញ។ ស៊ីម បានចូលមករកស៊ីជួញដូរ និងរស់នៅក្នុងភូមិអន្លង់ក្រូចជាមួយប្រពន្ធ និងកូនស្រី២នាក់ ដែលកូនស្រីពៅមានវ័យប្រហាក់ប្រហែលជាមួយ គឹម អេង ។ រាល់ពេលគ្រួសាររបស់ ស៊ីម ត្រឡប់ទៅផ្ទះនៅស្រុកកំណើត កូនស្រីច្បងរបស់ ស៊ីម ឈ្មោះ ផាត តែងតែបបួល គឹម អេង ធ្វើដំណើរដោយថ្មើរជើងទៅលេងផ្ទះជាមួយខ្លួនជាញឹកញាប់។ គឹម អេង ធ្លាប់បានទៅលេង និងរស់នៅភូមិកំពែងជាមួយគ្រួសារ ស៊ីម អស់រយៈពេល២ឆ្នាំ ទើបត្រឡប់មករស់នៅជាមួយឪពុកម្តាយនៅអន្លង់ក្រូចវិញ។

គឹម អេង ចងចាំបានថា «មានថ្ងៃមួយ សម្តេចព្រះ នរោត្តម សីហនុ បានយាងមកភូមិអន្លង់ក្រូចដើម្បីសម្ពោធសមិទ្ធផល។ អ្នករួមដំណើររួមមាន ស៊ីសុវត្ថិ សិរិមតៈ, សេនាប្រមុខ លន់ នល់, ចេង ហេង, ហ៊ូ យន់ និង ហ៊ូ នឹម។ ក្នុងដំណើរនេះរួមមានទាំងតារាចម្រៀងជាច្រើនរូបទៀតដូចជា ឈួន ម៉ាឡៃ, ឈុន វណ្ណា, ម៉ៅ សារ៉េត, ឌី សារ៉េត និងអ្នកផ្សេងទៀតច្រៀងរាំលេងយ៉ាងសប្បាយរីករាយ។ បន្ទាប់មកសម្តេចបានយាងទៅសាលារៀនក្នុងភូមិអន្លង់ក្រូច»។ គឹម អេង និងកុមារដទៃទៀតបាននៅចាំទទួលសម្តេចនៅមុខដងទង់ជាតិ។ មានប្រជាជនពីភូមិឃុំមួយចំនួនចាំទទួលសម្តេចយាងមក យ៉ាងច្រើនកុះករ។ ឪពុករបស់ គឹម អេង បានរាំរបាំស្នែងទន្សោងថ្វាយសម្តេចទស្សនា។ នៅក្នុងភូមិអន្លង់ក្រូចមានសាលារៀន មន្ទីរពេទ្យ និងមានបន្ទាយទាហានដ៏ធំមួយរបស់សម្តេចព្រះ នរោត្តម សីហនុ។ គឹម អេង បានចូលរៀននៅសាលារៀនក្នុងភូមិអន្លង់ក្រូច ដែលមានលោកគ្រូៗចំនួន៣នាក់ មកពីខេត្តស្វាយរៀង។ គ្រូបានបង្រៀន គឹម អេង និងក្មេងៗនៅភូមិឱ្យចេះសរសេរ និងចេះអានបន្តិចបន្តួច។

កាលនោះ សាលារៀនភូមិអន្លង់ក្រូច មិនសូវបានជាប់លាប់ឡើយ ព្រោះគ្រូទាំង៣នាក់ត្រឡប់ទៅស្រុកកំណើត ក្នុងរយៈពេល២ទៅ៣ខែ ទើបមកបង្រៀនម្តង។ ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយគឺត្រូវជិះរទេះក្របី ឬជិះដំរី។ ជំនាន់នោះក៏មានឈ្មួញជនជាតិចិន ប៉ុន្តែមានប្រពន្ធជាជនជាតិខ្មែរ បានដឹកសម្ភារប្រើប្រាស់តាមត្រាក់ទ័រ មកពីស្រុកភ្នំក្រវាញមកលក់ឱ្យសហករណ៍ក្នុងភូមិអន្លង់ក្រូច ដូចជា៖ គ្រឿងបរិភោគ អំបិល ប៊ីចេង ស្ករ ម្សៅស៊ុប រួមទាំងរបស់របរប្រើប្រាស់ផ្សេងៗជាច្រើនទៀត។ បន្ទាប់មក ជនជាតិចិនទាំងនោះបានប្រមូលទិញខ្ទឹម ទិញផ្លែក្រវាញ និងរបស់ផ្សេងៗទៀតត្រឡប់ទៅវិញ។ ក្រៅពីរបរធ្វើស្រែចម្ការ ម្តាយរបស់ គឹម អេង លក់អីវ៉ាន់បន្តិចបន្តួចនៅផ្ទះ។ ចំណែកឪពុករបស់ គឹម អេង ត្រូវបានប្រជាពលរដ្ឋ រួមទាំងជនជាតិភាគតិចព័រទាំងអស់គោរព និងចាត់ទុកថាជាដផ្ទៅព្រៃក្រវាញ។

នៅចន្លោះឆ្នាំ១៩៧០ ដល់ចុងឆ្នាំ១៩៧៤ បន្ទាប់ពី លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ មានសំឡេងកងរំពងពេញភូមិ ដោយសារការបាញ់គ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ ប្រជាជន ភ័យខ្លាចបង្កទៅជាភាពច្របូកច្របល់រត់បែកខ្ញែកកូនចៅ នាំគ្នារត់ទៅពួនក្នុងព្រៃជ្រៅ រហូតស្ងាត់សំឡេងកាំភ្លើង ទើបហ៊ាននាំកូនចៅត្រឡប់មកផ្ទះវិញ។ ថ្ងៃមួយអំឡុងពេល

គ្រួសារ គីម អេង កំពុងហូបបាយជុំជាមួយ ស្រាប់តែមានគ្រាប់កាំភ្លើងបាញ់មកពីក្រោយខ្នង។ គីម អេង បានរត់កាន់ឆ្នាំងបាយ សំដៅចូលក្នុងព្រៃ ព្រោះឆ្នាំងបាយមានសារសំខាន់ក្នុងពេលមានសង្គ្រាម។ រាល់ពេលយន្តហោះ ហោះមកទម្លាក់គ្រាប់បែក គឺមិនដែលបង្កឱ្យប្រជាជនក្នុងភូមិអន្ទង់ក្រូចរងរបួសឡើយ ប៉ុន្តែប្រជាជនរស់នៅមានភាពភ័យខ្លាច គ្មានសុវត្ថិភាព ព្រោះត្រូវរត់គេចខ្លួនចូលក្នុងព្រៃ។

នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើទាហាន លន់ នល់ រួចក៏ចូលមកគ្រប់គ្រងក្នុងភូមិ ហើយបានដើរប្រមែប្រមូលទ្រព្យសម្បត្តិរបស់របរមានតម្លៃ រុះរើតូបលក់អីវ៉ាន់របស់ប្រជាជនមួយចំនួនដែលមានជីវភាពធូរធារអស់គ្មានសល់។ ចំណែកប្រជាកសិករ ខ្មែរក្រហមមិនប្រមែប្រមូលរបស់ទ្រព្យសម្បត្តិទេ។ ដំបូង អ្នកភូមិរួមទាំងគ្រួសាររបស់ គីមអេងបាននាំគ្នារត់គេចខ្លួនចូលទៅក្នុងព្រៃអស់។ រយៈពេល៣ទៅ៤ថ្ងៃ ទើប គីមអេងហ៊ាននាំគ្នាត្រឡប់មករស់នៅក្នុងភូមិវិញ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងឱ្យអ្នកភូមិរួមទាំង គីម អេង ឱ្យទៅធ្វើការងារ។ បងប្រុសរបស់ គីម អេង ត្រូវអង្គការចាត់តាំងឱ្យចូលធ្វើជាកងទ័ព។ គីម អេង ត្រូវចូលធ្វើជាកងចល័ត ផ្នែករែកគ្រួស រែកថ្ម ជាមួយក្មេងៗស្រីៗ រួមទាំងអ្នកដែលមានវ័យស្រករគ្នាជាច្រើននាក់ ទាំងមិនដឹងថាអ្នកទាំងនោះមកពីភូមិណា។ គីម អេង ត្រូវចល័តទៅធ្វើការងារនៅទីតាំងមានដូចជា ម៉ុងរី ដូងឃ្មៀង សាលារកគោ ហើយនាំគ្នាដេកតាមព្រៃបែកពីឪពុកម្តាយបងប្អូន។

នៅឆ្នាំ១៩៧៦ គីមអេង នៅធ្វើការចល័តពីកន្លែងមួយទៅកន្លែងមួយទៀត។ រាល់រដូវធ្វើស្រែចម្ការ គីម អេង និងនារីដទៃទៀតត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅដក ស្ទូង គ្មានពេលឈប់សម្រាកឡើយ។ ដល់រដូវច្រូត ខ្មែរក្រហមបញ្ជូនខ្ញុំឱ្យទៅច្រូតស្រូវ រួចបែនស្រូវយកទៅហាលឱ្យស្ងួត រៀបចំកើបទុកដាក់ឱ្យបានរួចរាល់ ទើបអាចត្រឡប់មកផ្ទះនៅតាមភូមិវិញបាន។ ចំណែកឪពុកម្តាយ បងប្អូនខ្ញុំធ្វើការងារចល័តទៅទីកន្លែងផ្សេងៗ មិនដែលបានជួបគ្នាឡើយ។ សម្រាប់របបអាហារគឺហូបបបររាវៗក្នុងមួយថ្ងៃ២ពេលគឺ ពេលថ្ងៃនិងពេលល្ងាច។

នៅឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ គីមអេង ក៏ដូចជាអ្នកភូមិជនជាតិចាមទាំងអស់ចេញពីស្រុកកំណើត ដោយឱ្យដើរដោយថ្មើរជើងទៅកាន់ភូមិលាចក្នុងស្រុកភ្នំក្រវាញ។ ក្នុងពេលជម្លៀស គីមអេងមានការលំបាកដោយសាររែកចាន ឆ្នាំង និងរបស់ប្រើប្រាស់ផ្សេងៗហើយត្រូវធ្វើដំណើរផ្លូវឆ្ងាយ។ មួយវិញទៀត មានចាស់ជរារួមទាំងកុមារតូចៗ មួយចំនួនបានស្លាប់នៅតាមផ្លូវជាបន្តបន្ទាប់ដោយសារដើរឆ្ងាយអស់កម្លាំង និងដាច់បាយ។ នៅដល់ភូមិលាច ខ្មែរក្រហមបានឱ្យប្រជាជនសាងសង់រោងសម្រាប់ស្នាក់នៅរៀងៗខ្លួន រួចចាប់ផ្តើមចាត់ចែងឱ្យ គីមអេង នៅក្នុងកងចល័តនារី។ រីឯប្អូនស្រីៗ៣នាក់ទៀតត្រូវអង្គការចាត់តាំងឱ្យចូលធ្វើកងទ័ពស្រួច ជាកងដឹកជញ្ជូនកងទ័ពដែលរងរបួស និងសាកសពរបស់កងទ័ពខ្មែរក្រហម។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានបញ្ជូនប្អូនរបស់ គីមអេង ទាំង៣នាក់បន្តទៅកាន់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ចំណែក ម្តាយនិងឪពុករបស់ គីមអេង មានវ័យចំណាស់ត្រូវបានខ្មែរក្រហមបញ្ជូនទៅឃ្វាលគោក្របី នៅតាមស្រែស្តៅ តាមភូមិរកាត ក្នុងស្រុកភ្នំក្រវាញដោយមិនបានចល័តទៅទីកន្លែងឆ្ងាយៗដូចក្មេងៗឡើយ។ បន្ទាប់ពីចូលក្នុងកងចល័ត គីមអេង និងនារីដទៃទៀតធ្វើស្រែនៅភូមិលាច។ បន្ទាប់មក គីមអេង ត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅលើកទំនប់ដីទាលលំហែរ និងទំនប់សាច់ពូកក្នុងស្រុកភ្នំក្រវាញ។ គីមអេង ត្រូវបានបង្ខំឱ្យធ្វើការងារយ៉ាងខ្លាំងទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាក និងរស់នៅក្នុងរោងប្រក់ស្លឹកស្បូវដែលលំបាកវេទនាជាពន់ពេក។ ជារៀងរាល់ថ្ងៃ គីមអេង ត្រូវមុជកាយខ្សាច់ក្នុងទឹកនិងរែកដី ដើម្បីយកទៅចាក់បិទទំនប់។ សម្រាប់របបអាហារមានតែបបរលាយសុទ្ធតែទឹក មួយកូនចាន

តូចៗ ក្នុងអំឡុងពេលធ្វើការ គីមអេង បានដឹងថា ខ្មែរក្រហមបានយកមនុស្សទៅវាយសម្លាប់ចោលអស់ជាច្រើននាក់ ដោយសារចោទថា អ្នកទាំងនោះលាក់កម្លាំងខ្ជិលច្រអូស មួយចំនួនត្រូវចោទថាបានធ្វើខុសសីលធម៌ ឯមួយចំនួនបានសុំសម្រាកឈឺជាញឹកញាប់។ ខ្មែរក្រហមបានវាយសម្លាប់ប្រជាជនមកពីទីក្រុងភ្នំពេញ និងខេត្តបាត់ដំបង។

ឆ្នាំ១៩៧៨ គីមអេង ត្រូវបានផ្លាស់ចេញពីសាច់ពូកទៅលើកទំនប់ដំណាក់ឈើក្រម ក្នុងភូមិព្រែក។ គីមអេង នៅដំណាក់ឈើក្រមបានមួយរយៈ ត្រូវប្តូរទៅលើកទំនប់នៅសាច់ពូកវិញ ដោយត្រូវធ្វើការងារធ្ងន់ធ្ងរខ្លាំងណាស់។ រយៈពេល១ខែក្រោយមក គីមអេង បានត្រឡប់មកដំណាក់ឈើក្រមវិញ។ គីមអេង ចេញទៅរែកដីពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបឈប់សម្រាកហូបបបរម្នាក់មួយចាន។ នៅម៉ោង១រសៀលគីមអេងចុះធ្វើការងារបន្តរហូតដល់ម៉ោង៥ល្ងាច ទើបឈប់សម្រាកហូបបបរ១កូនចានទៀត។ ខ្មែរក្រហមកំណត់ក្នុងមួយថ្ងៃឱ្យគីមអេងកាប់ដី១ម៉ែត្រគុប។ ពេលយប់ គីមអេង នៅរែកដីចាក់លើទំនប់រហូតដល់ម៉ោង៩ទៅម៉ោង១០ ទើបបានចូលសម្រាក។ គីមអេង អាចកាប់ដីបានតាមការកំណត់ ព្រោះមានកងយុវជនមកជួយកាប់ដីឱ្យគាត់រែកយកទៅចាក់ឱ្យបានលឿន។ បើមិនដូច្នោះទេ ខ្មែរក្រហមនឹងចោទថាធ្វើការងារលាក់ពុតអសកម្មរួចបញ្ជូនទៅសម្លាប់ចោល ប៉ុន្តែទោះបីជាគីមអេង ខំប្រឹងធ្វើការឱ្យបានលឿនយ៉ាងណា ក៏មានការងារបន្ថែមនៅពេលយប់ដែរ។ ថ្ងៃមួយ ទំនប់ដំណាក់ឈើក្រមបានបាក់សង្កត់លើយុវជន យុវនារីដែលនៅលើកដីក្បែរមាត់ទំនប់ស្លាប់ជាច្រើននាក់។ រាល់ពេលទំនេរពីការងារ គីមអេង និងមិត្តនារីផ្សេងទៀតបបួលគ្នាដើរតាមទំនប់ទៅលេងនៅទំនប់ព្រហស្តក្បាល ស្ថិតក្នុងឃុំផ្ទះរុង លុះរសៀលទើបនាំគ្នាត្រឡប់មកវិញ។ ចុងឆ្នាំ១៩៧៨ គីមអេង បានឮដំណឹងពីអ្នកស្គាល់គ្នាថា «ប្អូនស្រីទាំងបីនាក់បានស្លាប់នៅលើផ្លូវរថក្រោះ ពេលនាំគ្នារត់គេចខ្លួនមិនបានប្រយ័ត្ន ព្រោះភាពភ័យខ្លាច ក្នុងអំឡុងពេលកងទ័ពខ្មែរក្រហមប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាម ហើយរថក្រោះបានបើកកិនប្អូនស្រីស្លាប់ទាំង៣នាក់ភ្លាមៗ»។ គីមអេង ពិតជាមានអារម្មណ៍នឹកស្រណោះប្អូនទាំង៣នាក់ ដោយមូលហេតុពីមុនមក គីមអេង ធ្លាប់បានដឹងថាប្អូនទាំង៣នាក់ត្រូវបានខ្មែរក្រហមប្រើឱ្យសែងសាកសពកងទ័ព និងប្រជាជនដែលស្លាប់យកទៅកប់ចោលជារៀងរាល់ថ្ងៃ។ ប្អូនស្រីរបស់គីមអេងត្រូវធ្វើការហត់នឿយ ទាំងយប់ទាំងថ្ងៃ ហើយអ្នកទាំង៣មានភាពភ័យខ្លាចណាស់។ គីមអេងមិននឹកស្មានថាប្អូនត្រូវស្លាប់បាត់ជីវិតនោះឡើយ។

នៅឆ្នាំ១៩៧៩ ក្នុងពេលដែលកងទ័ពវៀតណាមជិតចូលមកដល់ភូមិព្រែក គីមអេងរួមទាំងប្រជាជនដទៃទៀតរត់កាត់តាមព្រៃភ្នំ ព្រោះខ្មែរក្រហមបានប្រាប់ថាកងទ័ពវៀតណាមចូលមក រួចចាប់ធ្វើបាប។ គីមអេង មានបំណងរត់ទៅស្រុកកំណើត ព្រោះគិតថាឪពុកម្តាយត្រឡប់មកភូមិកំណើតវិញ។ គីមអេង រត់មិនទាន់បានឆ្ងាយប៉ុន្មានផង ស្រាប់តែកងទ័ពវៀតណាមរត់មកព័ទ្ធរួចប្រាប់ឱ្យត្រឡប់ក្រោយ ហើយសន្យាថាមិនធ្វើបាបទេ។ បន្ទាប់មកគីមអេង និងប្រជាជនដទៃទៀត យល់ព្រម ហើយធ្វើដំណើរត្រឡប់ទៅរស់នៅភូមិព្រែកវិញ។ ទៅដល់ភូមិ គីមអេងដាំបាយ ហូបជាមួយកងទ័ពវៀតណាម។

នៅឆ្នាំ១៩៨១ គីមអេង បានជួបគ្នាជាមួយឪពុកម្តាយ និងបងប្អូនដែលនៅរស់រានមានជីវិត ប៉ុន្តែមិនទាន់អាចរស់នៅជុំគ្នាបានទេ។ នៅឆ្នាំ១៩៨៦ ពេលគីមអេង រៀបការប្តី ទើបឪពុកម្តាយគាត់ប្តូរមករស់នៅភូមិអូរហេងជាមួយគ្នា។ រៀបការបានរយៈពេលមួយឆ្នាំ គីមអេង សម្រាលបានកូនស្រីច្បងម្នាក់។ នៅឆ្នាំ១៩៨៨ គីមអេង សម្រាលបានកូនស្រីម្នាក់ទៀត។ គីមអេងប្រកបមុខរបរធ្វើស្រែចម្ការ ចំណែកប្តីរបស់គាត់ធ្វើជាគ្រូបង្រៀន។ គីមអេង និងជនជាតិព័រមួយចំនួនមិនហ៊ានវិលត្រឡប់មកភូមិកំណើតវិញទេ ព្រោះក្នុងភូមិមានសភាពស្ងប់ស្ងាត់ និងសម្បូរទៅដោយគ្រាប់មីនមិនទាន់ផ្ទុះ។

នៅឆ្នាំ១៩៩៥ ម្តាយ គីមអេងបានស្លាប់ដោយ

សារជំងឺចាស់ជរា។ រហូតឆ្នាំ១៩៩៧ គឹម អេង និងប្តីបាននាំកូនៗត្រឡប់មករស់នៅភូមិអន្លង់ក្រូចវិញ ដោយប្រកបរបរធ្វើស្រែចម្ការ ហើយប្តីដូរទៅធ្វើជាប៉ូលីស។ បច្ចុប្បន្ននេះគឹម អេង នៅតែមានការឈឺចាប់ និងបានចងចាំរឿងរ៉ាវដែលខ្លួនបានជួបប្រទះ និងបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវដែល គឹម អេង មិនអាចបំភ្លេចបាននោះគឺការរស់នៅបែកបាក់ឪពុកម្តាយ បងប្អូនធ្វើការងារធ្ងន់ធ្ងរគ្មានអាហារហូបគ្រប់គ្រាន់ អស់រយៈពេលជាច្រើនឆ្នាំ។ ជាពិសេស គឹម អេង នៅតែនឹកដល់ប្អូនស្រីទាំង៣នាក់ ដែលបានស្លាប់ក្នុងសង្គ្រាម និងមិនអាចវិលត្រឡប់មករស់នៅជួបជុំគ្នាបាន។







ពិធីឡើងអ្នកតារបស់ជនជាតិដើមភាគតិចព័រ នៅទួលគ្រុស និងទួលកកោះក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លី មិច ៖ ស្មុគស្មាញ ពេលឃើញឈ្លប សម្លាប់មនុស្សទម្លាក់ចូលរណ្តៅ

**ភា វស្ន៍**

លី មិច ភេទស្រី អាយុ៧៨ឆ្នាំ (២០២១) រស់នៅភូមិតានប់ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។ មិច មានឪពុកឈ្មោះ ឈិន លី និងម្តាយឈ្មោះ ហ៊ង ម៉ុកមុត។ មិច មានបងប្អូនចំនួន៧ នាក់ គឺស្រី៣នាក់ និងប្រុស៤នាក់។ នៅឆ្នាំ១៩៦១ មិច រៀបការជាមួយ មាស ធ្វើជាប៉ូលីសមានស្រុកកំណើតនៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ បន្ទាប់ពីរៀបការរួច មិច និងប្តី ផ្លាស់ទៅរស់នៅខេត្តមណ្ឌលគិរី។ មិចមានកូនចំនួន៧ នាក់ក្នុង នោះមានកូនប្រុសម្នាក់និងកូនស្រីម្នាក់បានស្លាប់ក្នុងរបបខ្មែរក្រហម។

នៅឆ្នាំ១៩៧០ លន់ នល់បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋ។ បន្ទាប់ពីរដ្ឋប្រហារ ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ហើយប្តីរបស់មិចបានឈប់ធ្វើជាប៉ូលីស រួចនាំប្រពន្ធ និងកូន៣នាក់ មករស់នៅថ្មក្រែ ខេត្តក្រចេះ។ នៅខេត្តក្រចេះមិចរកស៊ីលក់ដូរ ដោយគាត់ប្រើប្រាស់កង់ ដឹកអង្ករ, បន្លែ, ផ្លែឈើ និងសត្វចិញ្ចឹម យកទៅ លក់ដូរនៅក្នុងខេត្តមណ្ឌលគិរី។ ស្ថានភាពនៅក្នុងភូមិពេលនោះគឺធម្មតា មានការធ្វើបុណ្យផ្សេងៗ ប៉ុន្តែចាប់ពីមានការទម្លាក់គ្រាប់បែកទើបកម្មវិធីផ្សេងៗត្រូវបានបញ្ឈប់។

នៅក្នុងរបបខ្មែរក្រហម អង្គការបានជម្លៀសប្រជាជនចំនួន៧០០គ្រួសារ ទៅរស់នៅ ខ្ទាន់ពីរ។ នៅទីនោះ ខ្មែរក្រហមបែកចែកប្រជាជនទាំងអស់ទៅរស់នៅតាភូមិ គឺចាប់ពីភូមិ១០១ រហូតដល់ភូមិ១០៧ ហើយ គ្រួសាររបស់មិចរស់នៅភូមិ១០១។ ខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ រួចចាត់តាំងប្រជាជន



លី មិច សព្វថ្ងៃរស់នៅភូមិតានប់ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាំងអស់ទៅធ្វើការកាប់ដីថ្មី រៀបចំជាភូមិ និងចាប់ផ្តើមធ្វើស្រែ, ជីកព្រែក, លើកទំនប់ និងជីកប្រឡាយរួមគ្នា និងហូបអាហាររួម។ បន្ទាប់ពីបង្កើតជាសហករណ៍រួចរាល់ កូនរបស់មិច ២នាក់បានស្លាប់ ដោយសារអត់អាហារ។ មុនពេលកូនស្លាប់ មិច បានសុំអង្ករមួយប៉ុងក្នុងមួយថ្ងៃពីចុងភៅ ដើម្បីដាំបាយឱ្យកូន ព្រោះកូនរបស់គាត់មិនហូបបបរលាយជាមួយពោត ដែលចុងភៅចែកឱ្យ ប៉ុន្តែចុងភៅមិនឱ្យ ទើបកូនប្រុសរបស់គាត់អត់អាហាររហូតដល់ស្លាប់។ ចំណែកកូនស្រីរបស់មិច មានជំងឺរាគធ្ងន់ធ្ងររយៈពេល៣ថ្ងៃទើបស្លាប់។ មុនពេលស្លាប់ អង្គការបានយករទេះដឹក

គាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែបានតែថ្នាំរាងមូលដូចអាចម៍ទន្សាយលេប ទើបមិនបានជាសះស្បើយ។

ចំពោះ ម៉ិច បន្ទាប់ពីកូនស្លាប់ គឺត្រូវទៅធ្វើការឱ្យអង្គការធម្មតា ដោយម៉ោង៤ព្រឹកគាត់ត្រូវចេញទៅធ្វើការងារសង្គមនិយម រហូតដល់មេឃភ្លឺទើបអាចឈប់សម្រាកហូបដំឡូង, ត្រសក់, អំពៅ ឬផ្លែឈើផ្សេងៗទៀតដែលអង្គការផ្ដល់ឱ្យ រួចចាប់ផ្ដើមធ្វើការងារស្នូលរបស់អង្គការរហូតដល់ពេលសម្រាកហូបអាហារថ្ងៃត្រង់។ នៅពេលរសៀល ម៉ិច ចូលធ្វើការងារវិញរហូតដល់ពេលល្ងាច។ ម៉ិច បានបន្តថា ខ្លួនមិនដែលហ៊ានឈប់សម្រាកពីការងារនៅពេលមានជំងឺ ឬលួចអាហារហូបទេ ព្រោះគាត់ខ្លាចមានទោស ឬឈ្លបយកទៅសម្លាប់។

នៅសហករណ៍ ប្រសិនបើមានប្រជាជនប្រព្រឹត្តកំហុស ឈ្លបនឹងចាប់ចងយកទៅសម្លាប់។ ជាក់ស្ដែងនៅពេលដែល ម៉ិច កំពុងជីកប្រឡាយជាមួយមិត្តភក្តិនៅក្នុងក្រុមឈ្មោះ ផន, សុទ្ធ, នាង, សែម និងតែម ស្រាប់តែកងឈ្លបបានកាន់ខ្សែគោមក និងស្រែកប្រាប់ឈ្មោះដែលបានរៀបរាប់ លើកដៃទាំងពីរឡើងលើ រួចយកខ្សែចងហើយបណ្ដើរចូលព្រៃបាត់។ ពេលដែលបណ្ដើរមនុស្សយកទៅ ប្រសិនបើមានអ្នកដើរមិនរួច គឺត្រូវចាប់អូសទៅតែម្ដង និងមិនមានការលើកលែងទេ។ នៅក្នុងព្រៃឈ្លបបានឱ្យអ្នកទោសទាំងអស់យកចបកាប់ដែលខ្លួនកាន់ទៅជាមួយជីករណ្ដៅ។ បន្ទាប់ពីជីករណ្ដៅរួច កងឈ្លបបានឱ្យអ្នកទោសទៅអង្គុយមុខរណ្ដៅ រួចចាប់ដងចបវាយពីក្រោយសម្លាប់ម្ដងម្នាក់ៗ។ ចំពោះស្ត្រីដែលមានកូនតូច ឈ្លបបានចាប់ជើងក្មេងនោះឡើងលើបម្រុងបោកទៅលើគល់ឈើឱ្យស្លាប់មុនម្ដាយ ប៉ុន្តែត្រូវបានម្ដាយដែលអង្គុយក្បែរនោះឡើងមកប្រតាយដណ្ដើមកូន ទើបសម្លាប់ទាំងពីរនាក់ក្នុងពេលជាមួយគ្នា។

ហេតុការណ៍ខាងលើនេះ ម៉ិច បានឃើញដោយផ្ទាល់ភ្នែក នៅពេលដែលប្រធានកងចាត់តាំងឱ្យគាត់និងមិត្តនារីម្នាក់ទៀតទៅកាត់ទងដំឡូង។ នៅពេលដែលឃើញបែបនេះ ម៉ិចមិនហ៊ាននៅលួចមើលរហូតដល់បញ្ចប់ការសម្លាប់មនុស្សទេ គឺគាត់បានដើរលបៗចេញពីដើមឈើធំដែលគាត់បានលាក់ខ្លួនកុំឱ្យកងឈ្លបឃើញ រួចដើរទៅកាត់ទងដំឡូងបន្ត ដោយក្នុងចិត្តមានការតក់ស្លុតស្មារតីខ្លាំង រហូតដល់ញ័រញាក់ពេញខ្លួន។ ម៉ិចឱ្យដឹងទៀតថា ខ្លួនរក្សាសុខខ្លាំងណាស់ មិនហ៊ានលួចខ្ជិលច្រអូស, មិនហ៊ានទិតៀនអ្នកដទៃ និងខិតខំធ្វើការងារ។ មួយវិញទៀតម៉ិចមិនហ៊ាននិយាយផ្ដេសផ្ដាស និងសួរនាំអ្វីទាំងអស់ បើទោះបីជាឈ្លបមកចាប់អ្នកធ្វើការងារនៅចំពោះមុខ។

នៅខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដួលរលំ ហើយម៉ិច និងគ្រួសារចាប់ផ្ដើមប្រកបរបបចិញ្ចឹមជីវិតនៅខេត្តក្រចេះធម្មតា ប៉ុន្តែកូនប្រុសច្បងដែលមានអាយុប្រមាណ១៣ឆ្នាំ បន្តរស់នៅជាមួយខ្មែរក្រហមក្នុងព្រៃ។ នៅក្នុងព្រៃ កូនរបស់ ម៉ិច មាននាទីជាអ្នកមើលសត្វជ្រូក ហើយការហូបអាហារក្នុងមួយពេលបានបាយត្រឹមតែមួយចានចង្កឹះតែប៉ុណ្ណោះ។ នៅពេលដែលអស់ស្បៀង កូនរបស់ម៉ិច បានចេញមកសុំអង្ករប្រជាជនរហូតដល់ថ្ងៃមួយបានជួបជាមួយកងឈ្លបម្នាក់ដែលម៉ិចបានផ្ដាំផ្ញើឱ្យហៅកូនរបស់គាត់ត្រឡប់មកផ្ទះវិញ។ កូនប្រុសរបស់ម៉ិចបានត្រឡប់មករស់នៅផ្ទះរយៈពេល២ខែ ទើប ម៉ិច នាំគ្រួសារមករស់នៅខេត្តតាកែវ។



អដ្ឋិធាតុជនរងគ្រោះដែលឆ្នាំគុកសម្លាប់ រួចកប់ក្នុងរណ្ដៅសាកសពរួម នៅអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ អដ្ឋិធាតុជនរងគ្រោះទាំងនោះត្រូវបានរដ្ឋអំណាច គាស់យកមករក្សាទុកនៅស្តូបតម្កល់អដ្ឋិធាតុក្រាំងតាចាន់ ក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រដេញតាមមហិច្ឆតាជាតិនិយមថៃ ក្រោមឥទ្ធិពលគោលនយោបាយការបរទេសអាមេរិក៖ អតីតកាល និងបច្ចុប្បន្ន

ឆាំង យុ




*ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ ផ្តល់សច្ចាប័នលើក្រុមប្រឹក្សាសន្តិភាពក្នុងពិធីជាប្រវត្តិសាស្ត្រ ដែលបើកផ្លូវឆ្ពោះទៅរកក្តីសង្ឃឹម និងសេចក្តីថ្លៃថ្នូរសម្រាប់ប្រជាជនហ្គាហ្សា ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦។ (ប្រភព៖ សេតវិមាន)*

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ មានព័ត៌មានថា ប្រទេសកម្ពុជាបានទទួលយកការអញ្ជើញជាផ្លូវការពីរដ្ឋបាលលោកប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ ដើម្បីចូលរួម «ក្រុមប្រឹក្សាសន្តិភាព» ដែលនេះគឺជាការបង្ហាញអំពីឆន្ទៈដ៏ប្រពៃនិងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសន្តិភាពជាសកល។ នេះគឺជាឱកាសជាប្រវត្តិសាស្ត្រ និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់កម្ពុជា។ នេះគឺជាឱកាសមួយសម្រាប់ពិភពលោកក្នុងការឈ្វេងយល់អំពីគំនិតផ្តួចផ្តើមប្រកបដោយថាមពល និងយុទ្ធសាស្ត្រច្នៃប្រឌិតថ្មីៗរបស់រដ្ឋបាលលោកប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ។ មិនតែប៉ុណ្ណោះ នេះគឺជាកិត្តិយសសម្រាប់កម្ពុជា ក្នុងការដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងចំពោះសន្តិភាពសកលលោក។

ដោយឡែកពីការលើកឡើងខាងលើ នៅមានបញ្ហាដ៏សំខាន់មួយទៀត គឺជម្លោះព្រំដែនរវាងប្រទេសថៃនិងប្រទេសកម្ពុជា ដែលកំពុងបន្តកើតមាន និងកំពុងបង្កជាផលប៉ះពាល់ដល់សន្តិភាពក្នុងតំបន់ និងសកលលោក។ បញ្ហានេះ កើតមានដោយសារតែភាពព្រងើយកន្តើយ និងការបំពារបំពានរបស់ប្រទេស




ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ ផ្តល់សច្ចាប័នលើក្រុមប្រឹក្សាសន្តិភាពក្នុងពិធីជាប្រវត្តិសាស្ត្រ ដែលបើកផ្លូវឆ្ពោះទៅរកក្តីសង្ឃឹម និងសេចក្តីថ្លៃថ្នូរសម្រាប់ប្រជាជនហ្គាហ្សា ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦។
(ប្រភព៖ សេតវិមាន)

ថៃ ទៅលើកិច្ចព្រមព្រៀងឈប់បាញ់ដែលជ្រោមជ្រែងដោយសហរដ្ឋអាមេរិក។ យោធាថៃបានកាន់កាប់តំបន់ចំនួន ១៤ ទីតាំងដែលស្ថិតក្នុងដែនអធិបតេយ្យភាពកម្ពុជា ហើយសកម្មភាពនេះគឺផ្ទុយស្រឡះពីកិច្ចព្រមព្រៀងឈប់បាញ់ ដែលជ្រោមជ្រែងដោយសហរដ្ឋអាមេរិក។

ជម្លោះព្រំដែនកម្ពុជា-ថៃ និងតួនាទីរបស់សហរដ្ឋអាមេរិកចំពោះសន្តិភាពក្នុងតំបន់ និងពិភពលោក គឺជាប់ពាក់ព័ន្ធជាមួយនឹងកិច្ចព្រមព្រៀងសន្តិភាពដែលសម្របសម្រួលដោយសហរដ្ឋអាមេរិកតាំងពីខែវិច្ឆិកា ឆ្នាំ១៩៤៦មកម្ល៉េះ។ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ទោះបីជាថៃបានអះអាងពី«អព្យាក្រឹតភាព» របស់ខ្លួនយ៉ាងណាក៏ដោយ រដ្ឋអាយ៉ងរបស់ខ្លួននៅទីបំផុតបានចងសម្ព័ន្ធភាពជាមួយជប៉ុន និងបានប្រកាសសង្គ្រាមជាមួយសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។ យោធាថៃបានចូលរួមប្រយុទ្ធជាមួយជប៉ុននៅក្នុងប្រទេសភូមា ហើយថៃបានដណ្តើមយកទឹកដីកម្ពុជា (ដែលកាលនោះ ស្ថិតនៅក្រោមអាណាព្យាបាលបារាំង)។ ក្រោយសង្គ្រាមលោកលើកទី២បានបញ្ចប់ទៅ ដោយភាពភិតភ័យរបស់ភាគីថៃ រដ្ឋាភិបាលថៃត្រូវបានតម្រូវឱ្យប្រគល់ទឹកដីកម្ពុជា ដែលខ្លួនបានដណ្តើមយកពីអាណាព្យាបាលបារាំង ត្រឡប់មកឱ្យកម្ពុជាវិញ។ ជំពូកនៃប្រវត្តិសាស្ត្រនេះមានសារសំខាន់ណាស់ ព្រោះវាមានចំណុចស្រដៀងគ្នាច្រើនជាមួយនឹងបរិបទបច្ចុប្បន្ន។ ប្រទេសថៃបានដណ្តើមកាន់កាប់ យ៉ាងហោចណាស់ជាបណ្តោះអាសន្នលើទឹកដីកម្ពុជាដោយប្រើប្រាស់កម្លាំងយោធា ដោយសកម្មភាពនេះ បានរំលោភលើស្មារតីនៃកិច្ចព្រមព្រៀងឈប់បាញ់ ដែលជ្រោមជ្រែងដោយសហរដ្ឋអាមេរិក។ សកម្មភាពនេះមិនមែនធ្វើឡើងដើម្បីផលប្រយោជន៍សន្តិភាពនោះទេ ប៉ុន្តែគឺដើម្បីមហិច្ឆតាជាតិនិយមថៃទៅវិញទេ។

ទន្ទឹមនឹងនេះដែរ ខណៈពេលដែលប្រទេសថៃត្រូវបានអញ្ជើញឱ្យចូលរួមក្នុង «ក្រុមប្រឹក្សាសន្តិភាព» ពីរដ្ឋបាលលោកប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ នាយករដ្ឋមន្ត្រីថៃ លោក អានុទីន ឆានវីរ៉ាកុល បែរជាបន្ទុះបន្អាបគំនិតផ្តួចផ្តើមនេះថា គ្រាន់តែជារឿង «មិនសូវចាំបាច់» ផូវផង់មួយ ហើយរដ្ឋាភិបាលថ្មីរបស់ថៃអាចទទួលយកសំណើនេះបាន លុះត្រាតែក្រុមប្រឹក្សានេះអាចនាំមកនូវផលប្រយោជន៍ ប្រសើរបំផុតសម្រាប់ប្រជាជាតិថៃ។

មានចំណុចស្រដៀងគ្នាជាច្រើនរវាងឥរិយាបថរបស់រដ្ឋាភិបាលថៃនាពេលបច្ចុប្បន្ន និងនាពេលអតីតកាលដែលហាក់ដូចជាបានកន្លងទៅជាយូរមកហើយនេះ។ ក្នុងអំឡុងពេល និងក្រោយសង្គ្រាមលោកលើកទី២ ប្រទេសថៃបានព្យាយាមជំរុញផលប្រយោជន៍ជាតិរបស់ខ្លួន ដោយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ក្នុងតំបន់ និងពិភពលោក ហើយក្នុងអំឡុងពេលសព្វថ្ងៃនេះ ទង្វើរបស់ប្រទេសថៃក៏មិនខុសប្លែកគ្នាពីទង្វើពីអតីតកាលដែរ។ រដ្ឋបាលលោកប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ គួរតែទាមទារឱ្យប្រទេសថៃទទួលខុសត្រូវនូវអ្វីដែលខ្លួនបានយល់ស្របក្នុងកិច្ចព្រមព្រៀងឈប់បាញ់ ដូចទៅនឹងការដែលសហរដ្ឋអាមេរិក តម្រូវឱ្យភាគីថៃអនុវត្តទៅតាមការយល់ស្របរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងរដ្ឋធានីវ៉ាស៊ីនតោន ឆ្នាំ១៩៤៦។

# សិស្សវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ
## មកអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទស្សនាខ្សែភាពយន្តឯកសារ «កុំស្អានបងក្មេច»

**មឿង ស្រីណុច**



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនកិច្ចសិក្សា និងអានសៀវភៅប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅវេលាព្រឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែន ប្រម៉ោយចំនួន ១០នាក់បានមកទស្សនកិច្ចសិក្សា និងអានសៀវភៅប្រវត្តិសាស្ត្រ ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែងដើម្បីជាជំនួយដល់ការសិក្សារៀនសូត្រនៅក្នុងសាលារៀន។ ក្នុងឱកាសនោះ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងក៏បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមានចំណងជើងថា «កុំស្អានបងក្មេច» ឱ្យសិស្សទស្សនា។ ខ្សែភាពយន្តឯកសារនេះ បានផ្សាភ្ជាប់ទៅនឹងរឿងរ៉ាវប្រវត្តិសាស្ត្រប្រទេសកម្ពុជាអំឡុងសតវត្សរ៍ទី២០ អំពីការរីកចម្រើនសង្គ្រាម និងការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហមលើគ្រប់វិស័យ រួមទាំង សិល្បៈករ និងតន្ត្រីករ ដែលការចាក់បញ្ចាំងនេះក្នុងគោលបំណង៖

១) ចង់ឱ្យសិស្សានុសិស្សបានយល់ដឹងអំពីការបាត់បង់តន្ត្រី និងអ្នកចម្រៀងជើងចាស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

២) ចង់ឱ្យសិស្សានុសិស្សយល់អំពីសម័យកាលនីមួយៗនៅក្នុងខ្សែភាពយន្តឯកសារ «កុំស្អានបងភ្លេច»។

៣) ចង់ឱ្យសិស្សានុសិស្សបានដឹងអំពីផលវិបាកនៃការកើតមានសង្គ្រាម។

៤) ការដោះស្រាយបញ្ហាដោយសន្តិវិធី និងការទប់ស្កាត់ជម្លោះនានា។

បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» រួច សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**ឆោម គីមមួយ** ភេទស្រី គឺជាសិស្សថ្នាក់ទី៩ មកពីវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ រៀបរាប់ថា៖ ខ្ញុំបានដឹងថា ខ្សែភាពយន្តខាងលើបានឆ្លុះបញ្ចាំងពីសម័យកាល។ ក្នុងសម័យសង្គមរាស្ត្រនិយមដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ ខ្ញុំដឹងពីភាពរីកចម្រើនរបស់ប្រទេសកម្ពុជាលើគ្រប់វិស័យទាំងអស់។ ខ្ញុំពិតជាសប្បាយរីករាយ ប៉ុន្តែក៏មានអារម្មណ៍សោកស្តាយចំពោះការបាត់បង់តន្ត្រីករនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានចិត្តអាណិតអាសូរដល់ប្រជាជន រួមទាំងអ្នកចម្រៀងល្បីៗមួយចំនួនដែលត្រូវបានបាត់បង់ជីវិត។ ខ្ញុំមានអារម្មណ៍រីករាយណាស់ដែលបានចូលមកទស្សនា និងអានសៀវភៅនៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ ខ្ញុំបានដឹងពីទុក្ខលំបាក និងការបាត់បង់របស់ប្រជាជនកម្ពុជានៅក្រោយរបបខ្មែរក្រហមដួលរលំ ហើយខ្ញុំកាន់តែយល់ដឹងច្បាស់អំពីប្រវត្តិរបស់ប្រទេសកម្ពុជាបន្ថែមបានមួយកម្រិតទៀត។

**លី សៀវហេង** ភេទស្រី គឺជាសិស្សថ្នាក់ទី៩ មកពីវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ បានលើកឡើងថា៖ នៅពេលខ្ញុំបានទស្សនាខ្សែភាពយន្តនេះរួច ខ្ញុំបានឃើញទិដ្ឋភាពប្លែកៗដែលខ្ញុំមិនធ្លាប់បានឃើញ ឬដឹងពីមុនមក។ ខ្ញុំមានអារម្មណ៍សោកសៅជាខ្លាំងចំពោះប្រជាជន និងសិល្បៈករមួយចំនួនដែលបានបាត់បង់ជីវិត រួមទាំងការបាត់បង់សិល្បៈតន្ត្រី។ រូបភាពដែលខ្ញុំបានឃើញបានដិតជាប់ក្នុងអារម្មណ៍របស់ខ្ញុំ ហើយធ្វើឱ្យខ្ញុំឈឺចាប់ ហើយវាក៏ជាការឈឺចាប់សម្រាប់កូនខ្មែរគ្រប់រូបដែរ។ ខ្ញុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រច្រើន ហើយខ្ញុំចង់ឱ្យកូនខ្មែរគ្រប់រូបដឹងរឿងរ៉ាវប្រវត្តិសាស្ត្រប្រទេសកម្ពុជា។



សិស្សមកពីវិទ្យាល័យ ហ៊ុនសែន ប្រម៉ោយ មកទស្សនកិច្ចសិក្សា និងអានសៀវភៅប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ស៊ុន ដេវីត** ភេទប្រុស គឺជាសិស្សថ្នាក់ទី៩ មកពីវិទ្យាល័យហ៊ុនសែនប្រម៉ោយ ប្រាប់ថា៖ ក្រោយទស្សនាខ្សែភាពយន្ត «កុំស្មានបងភ្លេច» ខ្ញុំពិតជាមានអារម្មណ៍សោកសៅ ក្តុកក្តួល និងឈឺចាប់ខ្លាំងណាស់។ ខ្ញុំបានយល់ច្បាស់ពីទុក្ខលំបាករបស់ប្រជាជនខ្មែរ ដែលបានឆ្លងកាត់ភាពសាហាវឃោរឃៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានការសោកស្តាយចំពោះការបាត់បង់តន្ត្រីសិល្បៈ និងអ្នកចម្រៀង ព្រោះទាំងអស់នេះក៏ជាផ្នែកមួយនៃការផ្សព្វផ្សាយ និងធ្វើឱ្យប្រទេសរបស់យើងកាន់តែមានការរីកចម្រើន។

**ឈុន ឡៃហ៊ាង** ភេទស្រី គឺជាសិស្សថ្នាក់ទី៩ មកពីវិទ្យាល័យ ហ៊ុនសែន ប្រម៉ោយ ឱ្យដឹងថា៖ បន្ទាប់ពីបានទស្សនាខ្សែភាពយន្ត «កុំស្មានបងភ្លេច» ខ្ញុំមានការសោកស្តាយចំពោះការបាត់បង់សិល្បៈករ និងសិល្បៈការិនីដែលមានភាពល្បីល្បាញ និងមានសមត្ថភាព។ ខ្ញុំអាណិតអាសូរចំពោះប្រជាជនគ្រប់រូបដែលត្រូវខ្មែរក្រហមចាប់យកទៅធ្វើទារុណកម្ម និងសម្លាប់យ៉ាងឃោរឃៅ។ ប្រសិនមានឱកាសខ្ញុំចង់



*សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនកិច្ចសិក្សា និងអានសៀវភៅប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មកអានសៀវភៅ និងចូលរួមរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្តទៀត។

**សុគុន លីហ៊ារ** *ភេទប្រុស ថ្នាក់ទី៩ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ លើកឡើងថា បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» រួច ខ្ញុំសង្កេតឃើញមានបីជំនាន់ ដោយជំនាន់មុនខ្ញុំ ឃើញប្រជាជនកម្ពុជាភាគច្រើនផ្តោតលើវិស័យកសិកម្ម និងវិស័យឧស្សាហកម្ម។ បន្ទាប់មកខ្ញុំបានស្តាប់ចម្រៀង ដែលច្រៀងដោយតារាចម្រៀងល្បីជំនាន់ដើមដែលមានទឹកដមសំនៀងពិរោះ។ លុះដល់របបខ្មែរក្រហម តារាចម្រៀងជំនាន់ដើមភាគច្រើនត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការពលកម្មធ្ងន់ធ្ងរ និងខ្លះទៀតត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។*



*សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនកិច្ចសិក្សា និងអានសៀវភៅប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

## រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីវិទ្យាល័យ ជា ស៊ីម

ឌីម សុខគា







មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ«គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សានុសិស្សចំនួន២៥នាក់ មកពីវិទ្យាល័យ ជា ស៊ីម តាកែវ។ គោលបំណងសំខាន់នៃវេទិកានេះ គឺដើម្បីបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាពិសេសស្វែងយល់ស៊ីជម្រៅពីគោលការណ៍៨ចំណុចរបស់ខ្មែរក្រហម ដែលឈានដល់ការបាត់បង់ជីវិតមនុស្សរាប់លាននាក់។

វេទិកាបានចាប់ផ្តើមដោយលោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងជាគ្រូឧទ្ទេសបានសាកសួរអំពីចំណេះដឹងមូលដ្ឋានរបស់សិស្ស ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។

បន្ទាប់មកលោកដេង ពង្សរ៉ាស៊ីបានធ្វើបទបង្ហាញលើចំណុចសំខាន់ៗមួយចំនួនដូចជា ការពន្យល់ពាក្យ (ខ្មែរក្រហម និងបដិវត្តន៍) និងគោលការណ៍៨ចំណុចរបស់ខ្មែរក្រហមរួមមានការជម្លៀសដោយបង្ខំ, ការលុបបំបាត់ទីផ្សារ, ការលុបបំបាត់រូបិយប័ណ្ណ, ការផ្សឹកព្រះសង្ឃ, ការប្រហារជីវិតមេដឹកនាំ និងមន្ត្រីជំនាន់លន់នល់, ការបង្កើតសហករណ៍, ការបណ្តេញជនជាតិវៀតណាម និងការបញ្ជូនទ័ពទៅព្រំដែន។

លើសពីនេះ លោក ដេង ពង្សរ៉ាស៊ី បានផ្សាភ្ជាប់



មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀន ក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រឹត្តិការណ៍នៃការជម្លៀសដោយបង្ខំ ជាមួយនឹងព្រឹត្តិការណ៍នៃការភៀសខ្លួនរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន ដោយបុព្វហេតុសង្គ្រាមឈ្លានពានទឹកដីពីសំណាក់យោធាថៃ និងបានអនុញ្ញាតឱ្យសិស្សលើកជាសំណួរផ្សេងទាក់ទងនឹងប្រធានបទថ្ងៃនេះ។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**ខ្ញុំឈ្មោះ សួនស្រីពេជ្រ ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សមកពីវិទ្យាល័យ ជា ស៊ីមតាកែវ៖**

ខ្ញុំគិតថាការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានផ្តល់នូវសារសំខាន់ជាច្រើនដូចជាឈ្វេងយល់ពីរយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏ខ្មៅងងឹត យល់ពីរបបផ្តាច់ការខ្មែរក្រហម យល់ពីការបំផ្លិចបំផ្លាញការអប់រំដើម្បីផលប្រយោជន៍របស់ខ្លួន និងបានបណ្តុះបណ្តាលគោលដៅចម្បងដើម្បីអប់រំយុវជនជំនាន់ក្រោយកុំឱ្យភ្លេចពីប្រវត្តិសាស្ត្រ ហើយចូលរួមការពារសន្តិភាព និងទប់ស្កាត់កុំឱ្យអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មី។ ខ្ញុំគិតថា នៅពេលប្រទេសយើងកើតមានសង្គ្រាមបែបនេះ វាបានផ្តល់ផលប៉ះពាល់ជាច្រើនដូចជា៖ ប្រទេសគ្មានការរីកចម្រើន បាត់បង់ជីវិតប្រជាជន ខូចខាតហេដ្ឋារចនាសម្ព័ន្ធ បែកបាក់គ្រួសារ និងបន្សល់នូវស្លាកស្នាមរបួសផ្លូវចិត្តធ្ងន់ធ្ងរច្រើនជំនាន់។

**ខ្ញុំឈ្មោះ ថាន់ ថុនា អាយុ១៧ឆ្នាំ គឺជាសិស្សរៀននៅថ្នាក់ទី១២ មកពីវិទ្យាល័យ ជា ស៊ីមតាកែវ៖**



មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀន ក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានផ្តល់សារសំខាន់ដូចជា៖ ខ្ញុំបានដឹងពីតថភាពនាសម័យនោះ និងសោកនាដកម្មរបស់ប្រជាជនកម្ពុជា, បេះការពារមិនឱ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត, លើកតម្កើងសិទ្ធិសេរីភាពមនុស្សគ្រប់គ្នា, មើលឃើញពីគំរូមិនល្អ និងចងចាំជានិច្ចនូវអំពើអមនុស្សធម៌មកលើប្រជាជនកម្ពុជា និងដឹងពីមូលហេតុសំខាន់នៃការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលប្រជាជនកម្ពុជាបានធ្លាក់ចូលទៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបានបង្ខំឱ្យជម្លៀសចេញពីផ្ទះសម្បែង បាត់បង់ផ្ទះសម្បែង បែកបាក់ពីគ្រួសារបន្សល់ទុកនូវស្ត្រីមេម៉ាយកុមារកំព្រា និងចាស់ជរា។ ហេដ្ឋារចនាសម្ព័ន្ធ សាលារៀន មន្ទីរពេទ្យ និងវត្តអារាមត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ខ្មែរក្រហមបានធ្វើឱ្យមនុស្សស្លាប់ជាង ២លាននាក់ បាត់បង់ធនធានមនុស្ស ហើយប្រទេសជាតិបាត់បង់កិត្តិយសលើឆាកអន្តរជាតិ។ ប្រជាជនរស់នៅក្នុងភាពលំបាក ខ្វះខាតស្បៀងអាហារ និងកើតមានជំងឺផ្សេងៗ។ របបនេះបានបន្សល់ទុកនូវការចងចាំដ៏តក់ស្លុត និងភ័យខ្លាចដល់ប្រជាជនកម្ពុជារហូតមកដល់សព្វថ្ងៃ។



មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយពីបានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួច ខ្ញុំបានដឹងអំពីការដែលមានមនុស្សស្លាប់យ៉ាងរង្គាល។ ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំពិតជាមានអារម្មណ៍តក់ស្លុត និងស្រណោះដល់បងប្អូនខ្មែរដែលបានស្លាប់នៅក្នុងរបបដ៏ឃោរឃៅអមនុស្សធម៌គ្មានហេតុផលនេះ។ ខ្ញុំនឹងចងចាំព្រឹត្តិការណ៍ដ៏អាក្រក់ និង ការបាត់បង់នេះ ហើយក្រើនរំឭកដល់អ្នកជំនាន់ក្រោយឱ្យចៀសវាង និងការពារមិនឱ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។

**ខ្ញុំឈ្មោះ សុង មករា អាយុ១៨ឆ្នាំគឺជាសិស្សមកពីវិទ្យាល័យជាស៊ីមតាកែវ**

ខ្ញុំគិតថាការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់១៩៧៩) បានផ្តល់សារសំខាន់ជាច្រើន៖ ធ្វើឱ្យខ្ញុំបានដឹងពីសោកនាដកម្មនៅសម័យខ្មែរក្រហម បានដឹងពីជីវិតរស់នៅយ៉ាងវេទនារបស់ប្រជាជន បានដឹងពីការបំបិទសិទ្ធិសេរីភាព ធ្វើការគ្មានពេលឈប់សម្រាក និង ហូបចុកមិនបានគ្រប់គ្រាន់។ ប្រជាជនមួយចំនួនទៀតដែលគ្រាន់តែលួចលាក់ក្តាម ខ្យង ទុកហូបចម្អែតក្រពះ ក៏ខ្មែរក្រហមហៅទៅកសាង ធ្វើទារុណកម្ម ឬឈានដល់ការសម្លាប់ដោយគ្មានក្តីអាណិត។ ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជួយដាស់តឿន



មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្មារតីឱ្យខ្ញុំបានដឹងពីតម្លៃសន្តិភាព ជីវិតមនុស្ស និងស្ថិរភាពសង្គម។ ប្រជាជនកម្ពុជាត្រូវនាំគ្នាទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឱ្យកើតមានឡើងម្តងទៀត ព្រោះនៅពេលដែលខ្ញុំបានសិក្សាពីរបបខ្មែរក្រហម ហើយ ជីវិតមនុស្សហាក់ដូចជាគ្មានតម្លៃ ព្រោះខ្មែរក្រហមចង់យកទៅសម្លាប់ពេលណាក៏បាន។ ប្រជាជនត្រូវទទួលរងនូវការឈឺចាប់ ព្រាត់ប្រាសគ្រួសារ និង បាត់បង់សាច់ញាតិបងប្អូន។ ខ្មែរក្រហមបានបំផ្លិចបំផ្លាញសេដ្ឋកិច្ចសង្គម ស្ទើរតែទាំងស្រុង មានដូចជា សាលារៀន វត្តអារាម មន្ទីរពេទ្យ និងរូបិយប័ណ្ណ ថែមទាំងបំផ្លាញដល់វប្បធម៌ សាសនា ហើយព្រះសង្ឃត្រូវបានចាប់ផ្សឹក អ្នកប្រាជ្ញបញ្ញវន្តត្រូវបានសម្លាប់ និងបំបិទសិទ្ធិមិនឱ្យមានការគោរពប្រពៃណីទំនៀមទម្លាប់។

ទោះបីជាខ្ញុំមិនបានកើតទាន់សម័យនោះក៏ដោយ ប៉ុន្តែខ្ញុំបានដឹងតាមរយៈការសិក្សា និងបានដឹងពីចាស់ព្រឹទ្ធាចារ្យដែលរស់នៅក្នុងសហគមន៍។ ខ្ញុំពិតជាមិនចង់ឱ្យរបបនេះកើតឡើងវិញម្តងទៀតទេ។ ទាក់ទិងការជម្លៀសក្នុងរបបខ្មែរក្រហម មានមូលហេតុបីគឺ ទីមួយ) ខ្លាចអាមេរិកទម្លាក់គ្រាប់បែកដោយខ្មែរក្រហមឱ្យប្រជាជនជម្លៀសត្រឹមតែ៣ថ្ងៃ នឹងឱ្យត្រឡប់មកផ្ទះវិញ។ ទីពីរ) បោសសម្អាតទីក្រុង។ ចំពោះជនណាដែលរឹងរូសមិនព្រមចាកចេញត្រូវខ្មែរក្រហមចោទថាជាខ្មាំង ហើយបញ្ជូនយកទៅសម្លាប់ដោយគ្មានក្តីអាណិត និងទីបី) មិនឱ្យប្រជាជនទៅយកស្បៀងអាហារនៅទីជនបទ។ ខ្មែរក្រហមប្រើលេសទាំងនេះដើម្បីឱ្យប្រជាជនចេញពីទីក្រុង ដោយនិយាយថាមិនអាចដឹកស្បៀងមកបានទេ ព្រោះផ្លូវ ស្ពាន ត្រូវបានកាត់ផ្តាច់អស់ហើយ។




មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «គោលការណ៍៨ចំណុចរបស់ខ្មែរក្រហម» និងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់សិស្សវិទ្យាល័យ ជា ស៊ីម តាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បើប្រៀបធៀបពីការជម្លៀសក្នុងរបបខ្មែរក្រហម និងការភៀសខ្លួនបច្ចុប្បន្នខុសគ្នាត្រង់ថា៖ ការជម្លៀសនាពេលបច្ចុប្បន្ន យើងអាចយកអ្វីៗដែលជារបស់ផ្ទាល់ខ្លួនទៅតាមបានដោយសេរី មិនមានការបង្ខិតបង្ខំ។ ជាពិសេសយើងអាចទៅជួបជុំគ្រួសារ និងមានស្បៀងអាហារគ្រប់គ្រាន់ក្នុងពេលធ្វើដំណើរ។ រីឯការជម្លៀសក្នុងរបបខ្មែរក្រហមវិញ យើងមិនអាចយករបស់របរតាមខ្លួនបានទេ ព្រោះមានការត្រួតពិនិត្យពីក្រុមខ្មែរក្រហម។ ប្រជាជនត្រូវឃ្លាតឆ្ងាយពីសាច់ញាតិបងប្អូន ព្រមទាំងត្រូវធ្វើដំណើរផ្លូវឆ្ងាយគ្មានពេលឈប់សម្រាក ជាពិសេសទទួលរងនូវការបង្ខិតបង្ខំពីក្រុមខ្មែរក្រហម។



# វេទិកាថ្នាក់រៀនស្តីពី «ផលប៉ះពាល់ និងតម្រូវការចាំបាច់សម្រាប់ប្រជាជនភៀសសឹក»

## នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

**ជាវ៉រដ្ឋ មេត្តា**








មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «ផលប៉ះពាល់និងតម្រូវការចាំបាច់សម្រាប់ប្រជាជនភៀសសឹក» ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន១៨នាក់មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ បានចូលរួមវេទិកាថ្នាក់រៀនរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ប្រធានបទដែលត្រូវបានលើកយកមកពិភាក្សា និងបង្ហាញ គឺ «ផលប៉ះពាល់ និងតម្រូវការចាំបាច់របស់ប្រជាជនកម្ពុជាក្នុងការចាកចេញពីផ្ទះសម្បែង (១៩៧៥-២០២៥) ក្រោមហេតុផលនយោបាយ សេដ្ឋកិច្ច សុវត្ថិភាព និងជម្លោះប្រដាប់អាវុធបង្កដោយទាហានឈ្លានពានថៃ»។ ប្រធានបទបន្ទាប់បន្សំគឺ «ព្រឹត្តិការណ៍ជម្លៀសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ក៏ត្រូវបានលើកយកមកពិភាក្សាជាមួយសិស្សានុសិស្សដែរ។

វេទិកាថ្នាក់រៀននេះ មានគោលបំណងសំខាន់ៗចំនួនបីគឺ៖ ១) ផ្តល់ដល់សិស្សានុសិស្សនូវចំណេះដឹងស្តីពីផលប៉ះពាល់ និងតម្រូវការចាំបាច់ដើម្បីរស់របស់ប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍ជម្លៀស និងជម្លោះព្រំដែនរវាងកម្ពុជា-ថៃ។ ២) ការសិក្សាឈ្វេងយល់បន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម និង ៣) ការត្រិះរិះពិចារណាទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងសង្គ្រាមនៅកម្ពុជានាពេលអនាគត។




មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «ផលប៉ះពាល់និងតម្រូវការចាំបាច់សម្រាប់ប្រជាជនភៀសសឹក» ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មក លោក ផេង ពង្សរ៉ាស៊ី បានលើកជាសំណួរទៅកាន់សិស្សានុសិស្សថា «តើប្រជាជនកម្ពុជាធ្លាប់ទទួលរងការចាកចេញពីផ្ទះសម្បែងប៉ុន្មានដងចាប់តាំងពីឆ្នាំ១៩៧៥-២០២៥? បន្ទាប់ពីសិស្សពិភាក្សានៅក្នុងក្រុមរួច លោក ផេង ពង្សរ៉ាស៊ី បានសង្ខេបថា ប្រជាជនកម្ពុជាធ្លាប់បានចាកចេញពីផ្ទះសម្បែងរបស់ខ្លួនចំនួនបីលើកគឺ ការចាកចេញពីផ្ទះសម្បែងក្រោមព្រឹត្តិការណ៍នៃការជម្លៀសដោយបង្ខំរបស់ខ្មែរក្រហម ការភៀសខ្លួនទៅកាន់ជំរំស្ថិតនៅតាមព្រំដែនក្នុងគោលបំណងស្វែងរកការជ្រកកោនពីប្រទេសមួយចំនួន និងការភៀសសឹកដែលបង្កដោយជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងថៃ។

បន្ទាប់ពីបញ្ចប់ការពិភាក្សាពីប្រធានបទខាងលើរួចមក វាគ្មិនបានបន្តពន្យល់ពីប្រធានបទសំខាន់មួយទៀតគឺ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ នៅផ្នែកនេះ វាគ្មិនបានលើកឡើងពី «ទុក្ខវេទនារបស់ប្រជាជនក្នុងរបបខ្មែរក្រហម» ដើម្បីឱ្យសិស្សប្រៀបធៀប ដូចជា ៖ ១) ការធ្វើដំណើរយ៉ាងលំបាក ដោយពុំមានការត្រៀមខ្លួនជាមុន ពុំមានអាហារហូបគ្រប់គ្រាន់ និងការបាត់បង់ជីវិតនៅតាមផ្លូវ)។ ២) ការធ្វើទារុណកម្មលើកាយសម្បទា ដោយបង្ខំឱ្យប្រជាជនកម្ពុជាធ្វើការចំនួន១២ទៅ១៥ម៉ោងក្នុងមួយថ្ងៃ។ ៣) ការអត់ឃ្លាន និងកង្វះជីវជាតិ។ ៤) ការបាត់បង់សិទ្ធិជាមូលដ្ឋានរួមមានបំបែកសមាជិកគ្រួសារឱ្យទៅនៅតាមកងចល័ត លុបបំបាត់សាសនា និងបំបិទការអប់រំ។ ៥) ការសម្លាប់រង្គាល និង ៦) កង្វះប្រព័ន្ធសុខាភិបាលបណ្ដាលឱ្យប្រជាជនស្លាប់ដោយសារជំងឺ។ ក្នុងអំឡុងពេលធ្វើបទបង្ហាញ លោក ផេង ពង្សរ៉ាស៊ី បានផ្ដល់ឱកាសដល់សិស្សានុសិស្សបានលើកជាសំណួរទាក់ទងនឹងប្រធានបទដំបូងនិងប្រធានបទបន្តបន្ទាប់។

ចុងក្រោយ លោក ផេង ពង្សរ៉ាស៊ី បានបង្ហាញពី





មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «ផលប៉ះពាល់និងតម្រូវការចាំបាច់សម្រាប់ប្រជាជនភៀសសឹក» ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«តម្រូវការចាំបាច់សម្រាប់ប្រជាជនជម្លៀស ប្រជាជនភៀសខ្លួន និង ភៀសសឹក ដើម្បីការរស់រានមានជីវិតពីហេតុការណ៍ជាប្រវត្តិសាស្ត្រ ទាំងនោះ។ គ្រូខេមរេស បានសង្កត់ធ្ងន់លើតម្រូវការខុសៗគ្នារបស់ប្រជាជនសម្រាប់ព្រឹត្តិការណ៍ខុសៗគ្នា។ តម្រូវការរបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម គឺត្រូវការហូបចុកគ្រប់គ្រាន់ និងរកវិធីសាស្ត្រដើម្បីបានហូបឆ្អែត។ តម្រូវការរបស់ប្រជាជនភៀសខ្លួនគឺ សុខសុវត្ថិភាព និងសន្តិភាព ដែលជាមូលហេតុនាំឱ្យអ្នកទាំងនោះភៀសខ្លួនទៅកាន់ប្រទេសទី៣ ដើម្បីអាចមានជីវិតរស់នៅប្រសើរជាងមុន។ ចំណែកតម្រូវការប្រជាជនភៀសសឹកវិញ គឺសន្តិភាព ស្ថិរភាពសង្គម និងគ្មានសង្រ្គាម។ វាគ្មិនក៏បានរំឭកដល់សិស្សានុសិស្សអំពីមូលដ្ឋានគ្រឹះក្នុងការថែរក្សាសន្តិភាពបាន គឺទប់ស្កាត់កុំឱ្យមានសង្រ្គាម រៀនពីសង្រ្គាម និងត្រៀមខ្លួនដើម្បីធ្វើសង្រ្គាម។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

ខ្ញុំឈ្មោះ **ឈួន សាន់ដាខាន់** អាយុ១៦ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ បន្ទាប់ពីខ្ញុំបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀននៅក្នុងថ្ងៃនេះ ខ្ញុំបានដឹងពីព្រឹត្តិការណ៍សង្រ្គាមទាំងពីររបប លន់ នល់ របបខ្មែរក្រហម និងសង្រ្គាមរហូតមកដល់សម័យបច្ចុប្បន្ន។ កាលពីអតីតកាលយើងក៏មានសង្រ្គាមដែរ ប៉ុន្តែគឺជាសង្រ្គាមស៊ីវិលដែលកើតមានក្នុងប្រទេស។ ចូលមកដល់របបខ្មែរក្រហម ប្រជាជនភៀសខ្លួនពុំមានសិទ្ធិគ្រប់គ្រាន់នៅក្នុងការសម្រេចចិត្ត ដោយគាត់ត្រូវទៅរស់នៅតាមសហករណ៍ដែលគ្មានអាហារហូបចុកគ្រប់គ្រាន់ និងត្រូវបង្ខំឱ្យធ្វើការងារជាទម្ងន់ជូនអង្គការ។ នៅពេលដែលប្រជាជនមានជំងឺគឺពុំមានថ្នាំសង្កូវដើម្បីព្យាបាលតាមផ្នែកវេជ្ជសាស្ត្រទេ។ បច្ចុប្បន្ននៅពេលប្រទេសមានសង្រ្គាម ប្រជាជនដែលរស់នៅតាមព្រំដែនត្រូវភៀសខ្លួនទៅកាន់ទីកន្លែងដែលមានសុវត្ថិភាព។ ប្រជាជនត្រូវឃ្លាតឆ្ងាយពីស្រែចម្ការផ្ទះសម្បែង។ ខ្ញុំពិបាកចិត្ត និងអាណិតដល់ប្រជាជនខ្មែរភៀសសឹកណាស់ ព្រោះមិនមានកន្លែង រស់នៅស្រួលបួល ជាពិសេសប្រជាជនដែលធ្លាប់រស់នៅក្នុងតំបន់ចំនួន១៨កន្លែង ដែលថៃប្លន់យក។ តំបន់ទាំងនោះគឺជាកន្លែងដែលប្រជាជនខ្មែរធ្លាប់រស់នៅពីមុន ហើយក៏ជាតំបន់ទេសចរណ៍របស់ប្រទេសកម្ពុជា។ ទោះបីខ្ញុំមិនអាចជួយជាកម្លាំងដល់ពូៗនិងបងៗកងទ័ព ប៉ុន្តែខ្ញុំមានកម្លាំងចិត្ត ស្បៀងអាហាររបស់របរប្រើប្រាស់ និង ថវិកាបន្តិចបន្តួចខបត្តម្ភជូនដល់គាត់។



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនក្រោមប្រធានបទ «ផលប៉ះពាល់និងតម្រូវការចាំបាច់សម្រាប់ប្រជាជនភៀសសឹក» ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ **ត្រី ប៉េងហុង** អាយុ១៨ឆ្នាំ រៀននៅថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ ខ្ញុំបានសិក្សាពីរបបខ្មែរក្រហម (រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ) ដែលធ្វើឱ្យប្រជាជនជួបនូវការលំបាកជាច្រើន។ ខ្មែរក្រហមបានជម្លៀសប្រជាជន និងធ្វើឱ្យប្រជាជនបែកបាក់ក្រុមគ្រួសារ។ ខ្មែរក្រហមបានបង្អត់អាហារដល់ប្រជាជន និងបង្ខំប្រជាជនឱ្យធ្វើការលើសកម្លាំង។ ក្រៅពីរបបខ្មែរក្រហម ខ្ញុំមានការចាប់អារម្មណ៍អំពីសង្គ្រាមរវាងកម្ពុជា និងថៃ ដែលធ្វើឱ្យប្រជាជន និងកងទ័ពកម្ពុជាស្លាប់បាត់បង់ជីវិត និងរបួសអស់ជាច្រើននាក់។ ប្រជាជនខ្លះត្រូវភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ។ ខ្ញុំអាណិតប្រជាជនភៀសសឹកនៅតាមជំរំ ដែលបាត់បង់ដីធ្លី និងផ្ទះសម្បែង។ ខ្ញុំសោកស្តាយតំបន់ចំនួន១៨កន្លែងរបស់កម្ពុជា ដែលថៃចូលមកគ្រប់គ្រងដោយខុសច្បាប់។ ដើម្បីទទួលបានតំបន់ទាំង១៨កន្លែងមកវិញ យើងត្រូវធ្វើការងារការទូតឱ្យខ្លាំង ហើយបើនៅតែមិនទទួលបានលទ្ធផល យើងអាចនឹងឈានទៅដល់ការធ្វើសង្គ្រាម។ យើងគួររៀនសូត្រពីសង្គ្រាមឱ្យបានច្បាស់ ថាសង្គ្រាមបានផ្តល់ផលអវិជ្ជមានអ្វីខ្លះមកដល់ប្រទេសជាតិ។



សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

**លី សុខឃាង**







មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ដល់សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៦ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចាប់ផ្តើមសារថ្មីជាមួយនឹងសិស្សានុសិស្សឈ្មោះ ថន យឿនភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី៨ នៃអនុវិទ្យាល័យត្រពាំងប្រិយ៍បានរៀបរាប់ពីរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលខ្លួនបានដឹងតាមរយៈឪពុកម្តាយយាយតាថា៖ «លោកយាយលោកតាខ្ញុំ តែងតែនិយាយរៀបរាប់ប្រាប់ពីការលំបាកនៅក្នុងជំនាន់ខ្មែរក្រហម ទាក់ទងនឹងការរស់នៅបែកបាក់គ្រួសារ ការអត់អាហារ ហូបចុក ការធ្វើការហួសកម្លាំង ជាពិសេសការវាយធ្វើបាបមនុស្សគ្មានកំហុស។ តាមការនិយាយរបស់តាយាយខ្ញុំ គឺខ្ញុំមិនទាន់ជឿទាំងស្រុងទេ ព្រោះខ្ញុំគិតថាប្រទេសមួយមិនអាចបង្អត់អាហារ បង្ខំឱ្យប្រជាជនធ្វើការហួសកម្លាំង វាយធ្វើបាបសម្លាប់ ប្រជាជនបានស្រួលៗនោះទេ។ រហូតដល់ខ្ញុំបានសិក្សារៀនសូត្រតាមសៀវភៅប្រវត្តិសាស្ត្របន្ថែម ទើបដឹងថារឿងរ៉ាវដែលយាយតាខ្ញុំប្រាប់សុទ្ធតែជាការពិត និងបានឆ្លងកាត់។ ទន្ទឹមនឹងនេះ ខ្ញុំក៏បានឆ្លងកាត់ក្នុងសង្គ្រាមការប៉ះទង្គិចគ្នារវាងកងទ័ពថៃឈ្លានពានមកលើទឹកដីកម្ពុជា ទើបខ្ញុំដឹងថា ប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់

គឺសុទ្ធតែជួបនូវផលលំបាក ភាពខ្វះខាតស្បៀងអាហារ តាមរយៈការកើតមានសង្គ្រាម។

បទឧក្រិដ្ឋកម្មសង្គ្រាមជាទូទៅត្រូវបានឱ្យនិយមន័យថាជាការរំលោភធ្ងន់ធ្ងរលើច្បាប់ និងទំនៀមទម្លាប់ស្តីពីសឹកសង្គ្រាម។ ឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងឧបករណ៍គតិយុត្តិអន្តរជាតិជាច្រើន ដូចជាអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមទី១ឆ្នាំ១៩៧៧។

លក្ខន្តិកៈទីក្រុងរ៉ូមបានឱ្យនិយមន័យឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងមាត្រា៨ ហើយបានចែងថាឧក្រិដ្ឋកម្មនេះស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងសមត្ថកិច្ចរបស់តុលាការនៃបណ្តាប្រទេសជាសមាជិកលក្ខន្តិកៈស្របទៅតាមគោលការណ៍នៃការបំពេញបន្ថែម។ ដូចគ្នានឹងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ នីតិកម្មជាតិនៃប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យតុលាការជាតិអាចជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមដើម្បីឱ្យស្របទៅនឹងកាតព្វកិច្ចអន្តរជាតិដែលកម្ពុជាបានព្រមព្រៀង។

ចាប់តាំងពីមានជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥មក ការទទួលព័ត៌មាន និងការយល់ដឹងអំពីសង្គ្រាម ការបំផ្លិចបំផ្លាញ និងឧក្រិដ្ឋកម្មនានានៃសង្គ្រាមត្រូវបានពិភាក្សាទូទៅ ជាពិសេស គឺយុវជនទាំងនេះបានជួបហេតុការណ៍ផ្ទាល់ភ្នែក និងស្តាប់ឮផ្ទាល់ត្រចៀក ក្នុងពេលថ្មីៗ។ ការរៀនសូត្រដោយភ្ជាប់នឹងព្រឹត្តិការណ៍ជាក់ស្តែងបែបនេះ ធ្វើឱ្យយុវជនងាយយល់ និងចងចាំ ជាពិសេសបង្កើនការចង់ចេះចង់ដឹងបន្ថែមទៀតទៅតាមការវិវត្តន៍ស្ថានការណ៍ជាក់ស្តែង។

វេទិកាថ្នាក់រៀននេះមានគោលបំណងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនេះ វេទិកាថ្នាក់រៀនបានផ្តោតលើការពិភាក្សាជុំវិញប្រធានបទស្តីពី «ទំនាក់ទំនងការបរទេសកម្ពុជាប្រជាធិបតេយ្យ, ការអត់ឃ្លាន និងសាលាក្តីខ្មែរក្រហម»។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កម្ពុជាមានទំនាក់ទំនងការទូតល្អជាមួយប្រទេសចិន, កូរ៉េខាងជើង, វៀតណាម, ឡាវ, រ៉ូម៉ានី, យូហ្គោស្លាវី, អាល់បានី និងអេហ្ស៊ីប។ ហេតុដូចនេះ ការមានទំនាក់ទំនងការទូតល្អជាមួយបណ្តាប្រទេសផ្សេងៗគឺជាការបង្ហាញពីមិត្តភាពរវាងប្រទេសនឹងប្រទេស ក្នុងការប្រាស្រ័យទាក់ទងគ្នាធ្វើកិច្ចការអ្វីមួយ។ កម្ពុជាប្រជាធិបតេយ្យខិតខំពង្រីកទំនាក់ទំនងការទូតរបស់ខ្លួន និងពាណិជ្ជកម្មក្រៅប្រទេសជាមួយៈ ចិន កូរ៉េខាងជើង ថៃ ជប៉ុន ហុងកុង ម៉ាដាហ្គាស្កា បង់ក្លាដែស សឹង្ហបុរី។ ក្នុងការ



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ដល់សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទំនាក់ទំនងនេះ កម្ពុជាបាននាំចេញទំនិញមួយចំនួនមាន ស្រូវ ជ័រកៅស៊ូ ឈើ និងសរីរាង្គសត្វដ៏កម្រៗ។ ចំណែកឯទំនិញនាំចូលត្រឡប់មកវិញមានគ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ ម៉ាស៊ីនសម្រាប់កសិកម្ម ផលិតផលគីមី និងក្រណាត់។

ស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ទើរតែគ្មាននរណាម្នាក់អាចទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ ប្រជាជនភាគច្រើនហូបតែបបរលាយពោត

លាយដើមចេក និងលាយគល់ល្ហុង ហើយទទួលបានរបបអង្ករតិចជាងកន្ទះកំប៉ុងទឹកដោះគោក្នុងមួយថ្ងៃ។ មានតែកម្មាភិបាល និងកងទ័ពខ្មែរក្រហមប៉ុណ្ណោះដែលមានបាយហូបគ្រប់គ្រាន់។ អ្នកដែលរស់រានមានជីវិតពីរបបនេះ បានយល់ស្របថាអ្វីដែលគាត់ចងចាំបំផុតក្រៅពីការបង្ខំឱ្យធ្វើការហួសកម្លាំង និងការកាប់សម្លាប់នោះ គឺការខ្វះខាតអាហារយ៉ាងខ្លាំង។ យោងតាមបទសម្ភាសន៍ អ៊ុំ សារ៉េត ស្ត្រីវ័យ៥៧ឆ្នាំរស់នៅក្នុងទីក្រុងភ្នំពេញបានរៀបរាប់ពីជីវិតឈឺចាប់របស់គ្រួសារខ្លួន ដែលបន្តមកពីការហូបមិនគ្រប់គ្រាន់ថា៖ «នៅឆ្នាំ១៩៧៦ ដោយទ្រាំមិនបាននឹងការស្រេកឃ្លានឪពុកខ្ញុំបានដួសកូនក្អែកមកស្ងោរហូបដោយគាត់គិតថានោះគឺជាកូនត្រី។ ថ្ងៃមួយ កម្មាភិបាលខ្មែរក្រហមម្នាក់បានសម្លាប់ពស់មានពិសមួយ ហើយយកមកទុកចោលនៅលើរបង។ ឪពុកខ្ញុំបានដឹងថាពស់នោះមានពិស ប៉ុន្តែគាត់នៅតែហូបរហូតធ្វើឱ្យស្លាប់។ ប្អូនស្រី និងកូនៗខ្ញុំបានស្លាប់ដោយសារតែការអត់ឃ្លាន»។

**នៅផ្នែកចុងក្រោយសិស្សានុសិស្សបានបង្ហាញនូវចំណាប់អារម្មណ៍ដូចតទៅ៖**

**នួ ដានី** ភេទស្រី វ័យ១៨ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍និងការចងចាំបន្ទាប់ពីខ្លួនបានចូលរួមក្នុងវេទិកាដូចតទៅ «ការសិក្សានេះបានធ្វើឱ្យខ្ញុំបានយល់ដឹងបន្ថែមពីការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពោរពេញទៅដោយទុក្ខលំបាក ប្រទេសកើតមានសង្គ្រាម ប្រជាជនជួបនូវការអត់ឃ្លានដោយសារខ្វះខាតស្បៀងអាហារ។ បញ្ហាសង្គ្រាមដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រទេសកម្ពុជានាពេលថ្មីៗនេះ គឺមិនខុសគ្នាប៉ុន្មានទេ ពីព្រោះការកើតមានសង្គ្រាមនៅក្នុងប្រទេសមួយ សុទ្ធសឹងតែជួបផលវិបាក ទាំងអស់ ជាពិសេសកើតលើប្រជាជន។ ប៉ុន្តែការកើតមានសង្គ្រាមរវាងកម្ពុជា-ថៃ គឺកើតឡើងមកពីការឈ្លានពានចង់បានទឹកដីរបស់កម្ពុជា។ ប្រសិនបើខ្ញុំជាអ្នកដឹកនាំ ខ្ញុំនឹងបង្កើតទំនាក់ទំនងល្អជាប្រទេស ចិន ឡាវ មីយ៉ាន់ម៉ា វៀតណាម និងម៉ាឡេស៊ី។ ខ្ញុំគិតថាទំនាក់ទំនងការបរទេសសំខាន់ណាស់ ពីព្រោះវាជាមធ្យោបាយមួយងាយស្រួលក្នុងការពឹងពាក់គ្នាទៅវិញទៅមក។ ការបញ្ចប់ជម្លោះព្រំដែន កម្ពុជា-ថៃ គឺត្រូវចរចាសម្របសម្រួលគ្នាដោះស្រាយតាមសន្តិវិធីដោយគ្មានល្បិចកល»។

**ធឿន គីមលាង** អាយុ១៥ឆ្នាំ ភេទស្រី រៀនថ្នាក់ទី៩ បានលើកឡើងថា «ខ្ញុំចងចាំពីមេរៀនក្នុងវេទិកានេះអំពីការកើតមានសង្គ្រាមនៅក្នុងប្រទេសកម្ពុជា និងមេរៀននិយាយពីទំនាក់ទំនងការបរទេសកម្ពុជាប្រជាធិបតេយ្យ។ ការកើតមានសង្គ្រាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងប្រទេសកម្ពុជា គឺបានធ្វើឱ្យកើតមានជនភៀសសឹក ដោយបាត់បង់ផ្ទះសម្បែង ការព្រាត់ប្រាសក្រុមគ្រួសារ។ ប្រសិនបើខ្ញុំជាថ្នាក់ដឹកនាំ ខ្ញុំនឹងបង្កើតទំនាក់ទំនងល្អជាមួយប្រទេសមហាអំណាចដូចជា ចិន អង់គ្លេស។ ខ្ញុំយល់ថាទំនាក់ទំនងការបរទេសពិតជាល្អខ្លាំងណាស់ពីព្រោះវាបានបង្កើតឱ្យមានការគាំទ្រ និងគំនិតផ្តួចផ្តើមជាមួយគ្នា កាន់តែមានទំនាក់ទំនងការបរទេសច្រើនកាន់តែល្អ។ ចំពោះវិធីសាស្ត្របញ្ចប់សង្គ្រាមព្រំដែនកម្ពុជា-ថៃ គឺមានតែអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់ឱ្យមានប្រសិទ្ធភាពកុំឱ្យមានការវាយប្រហារមកលើកម្ពុជាជាលើកទីបី ពីព្រោះកម្ពុជាត្រូវការសន្តិភាពមិនត្រូវការសង្គ្រាមឡើយ»។

**ថន យឿន** ភេទស្រី អាយុ១៨ឆ្នាំ បានលើកឡើងថា«ខ្ញុំចាប់អារម្មណ៍លើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងទំនាក់ទំនងការបរទេសល្អជាមួយប្រទេសជិតខាង ដូចជា ប្រទេសចិន ឡាវ វៀតណាម កូរ៉េខាងជើង យូហ្គោស្លាវី, អាល់បានី និង អេហ្ស៊ីប។ បន្ថែមពីនេះ ខ្ញុំបានដឹងថាប្រទេសចិន ក៏ធ្លាប់បានជួយគាំទ្រជាគ្រឿងសភាវុធមកកម្ពុជាតាំងពីរបបកម្ពុជាប្រធិបតេយ្យមកម្ល៉េះ។ ប្រសិនបើខ្ញុំជាអ្នកដឹកនាំ ខ្ញុំនឹងមានទំនាក់ទំនងល្អជាមួយប្រទេសមហាអំណាចដូចជា ចិន កូរ៉េ និងវៀតណាម ពីព្រោះសុទ្ធតែជាប្រទេសដែលធ្លាប់បានជួយគាំទ្រដល់កម្ពុជា»។





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ដល់សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**លឹម ចាន់ណាវ៉ាន់** ភេទស្រី អាយុ១៨ឆ្នាំ បានប្រាប់ថា «ក្នុងការសិក្សានេះ ខ្ញុំចាប់អារម្មណ៍ខ្លាំងទៅលើរបបកម្ពុជាប្រជាធិបតេយ្យក្នុងការខិតខំពង្រីកទំនាក់ទំនងការទូតរបស់ខ្លួន និងពាណិជ្ជកម្មក្រៅប្រទេសជាមួយ ចិន កូរ៉េខាងជើង ជប៉ុន ហុងកុង បង់ក្លាដែស និងស៊ីង្ហបុរី។ នៅក្នុងទំនាក់ទំនងនេះ គឺដើម្បីនាំចេញនាំចូលផលិតផលដែលប្រទេសនីមួយត្រូវការរៀងៗខ្លួន។ ប្រសិនបើខ្ញុំជាអ្នកដឹកនាំ ខ្ញុំនឹងជ្រើសរើសយកប្រទេសចិនជាមិត្តក្នុងការទំនាក់ទំនងការបរទេស។ ពិតណាស់ បញ្ហាសង្គ្រាមកើតឡើងនៅក្នុងប្រទេសគឺសុទ្ធតែមានផលវិបាកទាំងអស់ គិតចាប់តាំងពីការពលីជីវិត ពិការភាព ប្រជាជនភៀសសឹកគេចពីការទម្លាក់គ្រាប់ ការស្នាក់នៅ និងការហូបចុកមានភាពខ្វះខាត។

**សុន ដានី** ភេទស្រី អាយុ១៨ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍ដូចតទៅ «បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនមក ខ្ញុំបានយល់ដឹងបន្ថែមពីប្រវត្តិ- សាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទទួលបានចំណេះដឹងបន្ថែមអំពីទំនាក់ទំនងការបរទេសកម្ពុជាប្រជាធិបតេយ្យ ជាមួយប្រទេសដៃគូរជិតស្និទ្ធ។ ចំពោះបញ្ហាសង្គ្រាមដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រខ្មែរ និងប្រទេសកម្ពុជា គឺបានធ្វើឱ្យប្រជាជនរងទុក្ខលំបាក បែកបាក់ពីគ្រួសារ អ្នកខ្លះត្រូវបាត់បង់ជីវិត។ ប្រសិនបើខ្ញុំជាអ្នកដឹកនាំខ្ញុំនឹងបញ្ចប់ជម្លោះព្រំដែនកម្ពុជា ថៃ ដោយប្រើការចរចារវាងភាគីទាំងពីរ។ ខ្ញុំយល់ថាទំនាក់ទំនងការបរទេសពិតជាមានសារសំខាន់ណាស់រវាងប្រទេសនិងប្រទេស។ ប្រសិនជាខ្ញុំជាអ្នកដឹកនាំ ខ្ញុំប្រាកដជាបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេស ចិន វៀតណាម ឡាវ កូរ៉េ និងអង់គ្លេស»។

**ចរិយា** ភេទស្រី អាយុ១៥ឆ្នាំ បានលើកឡើងថា «ខ្ញុំចង់ចាំ និងបានរៀនសូត្រអំពីប្រវត្តិសាស្ត្រការកើតសង្គ្រាម និងរឿងរ៉ាវរបស់ប្រជាជនខ្មែរ។ ចំណែកឯសង្គ្រាមដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រទេសកម្ពុជា សុទ្ធសឹងតែធ្វើឱ្យប្រជាជនជួបនូវទុក្ខលំបាក ហេដ្ឋារចនាសម្ព័ន្ធត្រូវខូចខាតកងទ័ពត្រូវពលីជីវិត ជាពិសេសការខ្វះខាតស្បៀងអាហារហូបចុក។ ប្រាកដណាស់ ទំនាក់ទំនងការបរទេសពិតជាមធ្យោបាយមួយយ៉ាងល្អចំពោះប្រទេស និងប្រទេស ដែលជាកម្លាំងគាំទ្រគ្នាទៅវិញទៅមក។ កាលណាប្រទេសមួយមានទំនាក់ទំនងល្អជាមួយប្រទេសដទៃទៀតបានកាន់តែច្រើន នោះពិតណាស់ប្រទេសនោះនឹងមានការជឿនលឿនបានយ៉ាងឆាប់រហ័ស។ ដើម្បីបញ្ចប់ជម្លោះព្រំដែនកម្ពុជា ថៃ ខ្ញុំយល់ថាលុះត្រាតែភាគីទាំងសងខាងព្រមទទួលយកនូវកិច្ចព្រមព្រៀងគ្នាដែលបានចុះរួចរាល់ហើយ និងមិនត្រូវមានចិត្តលោភលន់ចង់បានទឹកដីរបស់ភាគីណាមួយ ហើយរស់នៅដោយសន្តិវិធីរវាងគ្នានឹងគ្នា។

# សេចក្តីប្រកាសរកយាយតា និង មីង ដែលបាត់ខ្លួន

សោម ប៊ុនថន



អ៊ាត ប៊ុនថេង នៅព្រលានយន្តហោះ ទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា ឆ្នាំ១៩៦៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ៊ាត ប៊ុនថេង និងប្រពន្ធ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ាត អាម៉ាន់ឌីន សូមប្រកាសរក១) ជីតាឈ្មោះអ៊ាតប៊ុនថេង កើតអំឡុងឆ្នាំ១៩១៨ ឬ១៩១៩ នៅទីក្រុងភ្នំពេញ ២) យាយឈ្មោះគាន់ អាងស៊ាក (ឬ អាងស៊ាង) កើតឆ្នាំ១៩៤២ នៅទីក្រុងភ្នំពេញ និង ៣) ម្តាយមីងឈ្មោះ អ៊ាតប៊ុនថារ៉ែត ឬ អ៊ាតប៊ុនថារិទ្ធិ កើតឆ្នាំ១៩៦៣។ តារបស់ខ្ញុំគឺជាអតីតឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅជប៉ុនក្នុងឆ្នាំ១៩៦៤, នៅប្រទេសភូមាក្នុងឆ្នាំ១៩៦៩ និងជាតំណាងបម្រុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ចូលរួមប្រជុំនៅមហាសន្និបាតអង្គការសហប្រជាជាតិលើកទី២៨ នៅក្នុងឆ្នាំ១៩៧៣។

នៅខែមករា ឆ្នាំ១៩៧៥ យាយតានិងមីងរបស់ខ្ញុំបានផ្លាស់មករស់នៅជាប់ព្រលានយន្តហោះ (ពោធិ៍ចិនតុង) ក្បែរមូលដ្ឋានយោធា។

យាយតា និងមីងរបស់ខ្ញុំបាត់ខ្លួនអំឡុងឆ្នាំ១៩៧៥ ពេលរៀបចំផែនការភៀសខ្លួនទៅនៅប្រទេសបារាំងប៉ុន្តែជាអកុសល ស្ត្រីមិនត្រូវបានអនុញ្ញាតឱ្យឡើងជិះលើយន្តហោះទេ។

ខ្ញុំចាំថា តារបស់ខ្ញុំមានហាងលក់គ្រឿងអលង្ការនៅជាប់រោងកុន ចំណែកមីងរបស់ខ្ញុំមានផ្ទះស្ថិតនៅខាងក្រោយវាំង លើផ្លូវលេខ២៤០។

បងប្អូនរបស់ខ្ញុំសន្មតថា ពួកគាត់បានស្លាប់ទៅហើយ ប៉ុន្តែគ្មាននរណាម្នាក់ដឹងព័ត៌មានច្បាស់លាស់ទេ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះដូចបានរៀបរាប់ខាងលើ សូមមេត្តាទំនាក់ទំនងមកខ្ញុំតាមរយៈ: អាសយដ្ឋាន៖ ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតេឡេក្រាម និងទូរសព្ទលេខ៖ ០១២ ៩៩៦ ៧៥០។ សូមអរគុណ!

រូបក្របមុខ៖
កងទ័ពអាកាសថៃទម្លាក់គ្រាប់បែកផ្ដាច់ស្ពានមេទឹក ឬស្ពានជ័យជម្នះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កងទ័ពអាកាសថៃទម្លាក់គ្រាប់បែកផ្ដាច់ស្ពានជ័យជម្នះ (ចាស់) ស្ថិតនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 314, February 2026

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.